ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

# របាយការណ៍
# បូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០១៥
# និង
# ទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ ២០១៦



ឆ្នាំ២០១៥

# មាតិកា

**ខ្លឹមសារ** **ទំព័រ**

I/ **សេចក្តីផ្តើម**
**១. កំណែទម្រង់**......1
**១.១ កំណែទម្រង់រដ្ឋបាលសាធារណៈ**......2
១.១.១ កំណែទម្រង់ធនធានមនុស្ស......2
១.១.២ កំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈ......3
១.១.២.១ កំណែទម្រង់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ......3
១.១.២.២ កំណែទម្រង់ការចុះបញ្ជីពាណិជ្ជកម្ម......3
១.១.២.៣ កំណែទម្រង់ការចុះបញ្ជីកម្មសិទ្ធិបញ្ញា......3
**១.២ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**......4
១.២.១ ការរៀបចំផែនការ......4
១.២.២ ការត្រៀមខ្លួនសម្រាប់ការងារថវិកាកម្មវិធី......4
**១.៣ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**......5
១.៣.១ ការធ្វើតាកងមុខងារ......5
១.៣.២ ការផ្ទេរមុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ......5
II/ **សកម្មភាពពាណិជ្ជកម្មដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**
**២ លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**......6
**២.១ ការបម្រើសេវាសាធារណៈ**......6
២.១.១ ការងារកម្មសិទ្ធិបញ្ញា......6
២.១.២ ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ......9
២.១.៣ ការផ្តល់សេវានាំចេញ-នាំចូល......10
**២.២ ការងារជំរុញពាណិជ្ជកម្ម**......11
២.២.១ ការរៀបចំព័ត៌មានពាណិជ្ជកម្ម......11
២.២.២ ការអភិវឌ្ឍទីផ្សារ......12
២.២.២.១ ការស្វែងរក និងអភិវឌ្ឍន៍ទីផ្សារ......12
២.២.២.២ ការពង្រឹងដៃគូពាណិជ្ជកម្ម......12
២.២.២.៣ ការងារស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស......13
២.២.៣ ការងារអភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្ម......13
**២.៣ ការងារកសាងបញ្ញត្តិច្បាប់ពាណិជ្ជកម្ម**......15
**២.៤ ការងារអភិវឌ្ឍន៍វិស័យឯកជន**......17

២.៤.១ ការងារអភិវឌ្ឍន៍ផលិតផល ..... 17

២.៤.២ ការអភិវឌ្ឍស្ថាប័នពាណិជ្ជកម្ម ..... 17

២.៤.៣ ការងារពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម ..... 18

**២.៥ ការចងក្រង និងផ្តល់ព័ត៌មានពាណិជ្ជកម្ម ..... 18**

**២.៦ ការងារសមាហរណកម្មសេដ្ឋកិច្ចតំបន់ អនុតំបន់ និងដៃគូ ..... 21**

២.៦.១ អាស៊ាន-ចិន ..... 21

២.៦.២ អាស៊ាន-កូរ៉េ ..... 22

២.៦.៣ អាស៊ាន-ជប៉ុន ..... 22

២.៦.៤ អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ..... 23

២.៦.៥ អាស៊ាន-ហុងកុង ..... 23

២.៦.៦ ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) ..... 24

២.៦.៧ ការងារអនុតំបន់ ..... 26

២.៦.៨ ការងារទ្វេភាគី ..... 28

២.៦.៩ សហគមន៍សេដ្ឋកិច្ចអាស៊ាន ..... 29

២.៦.១០ ពាណិជ្ជកម្មសេវា ..... 29

**២.៧ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក ..... 30**

**២.៨ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាមេរិក ..... 35**

**២.៩ ការងារសមាហរណកម្មសាកល ..... 40**

**២.១០ ការងារសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ ..... 43**

២.១០.១ ការអនុវត្តអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម ..... 43

២.១០.២ ការអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម ..... 43

២.១០.៣ ការអនុវត្តកម្មវិធីពង្រឹងសមាហរណកម្ម ..... 44

២.១០.៤ ការងាររៀបចំផែនការរយៈពេលមធ្យម ..... 44

**២.១១ ការងារត្រួតពិនិត្យ បង្ក្រាបការក្លែងបន្លំ និងការពារអ្នកប្រើប្រាស់ ..... 44**

២.១១.១ ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យការនាំចេញ-នាំចូល តាមច្រកព្រំដែន ..... 44

២.១១.២ ពង្រឹងប្រសិទ្ធភាពនៃការឃ្លាំពិនិត្យទីផ្សារ ទប់ស្កាត់គ្រោះថ្នាក់សុខមាលភាព សុវត្ថិភាពអ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងផលិតផល ..... 45

២.១១.៣ ពង្រឹងស្ថាប័ន ធ្វើឱ្យប្រសើរ និងមានប្រសិទ្ធភាពចំពោះកិច្ចការពារអ្នកប្រើប្រាស់ ..... 45

២.១១.៤ លើកកម្ពស់ការយល់ដឹងសាធារណៈ ..... 45

២.១១.៥ ទប់ស្កាត់ការក្លែងបន្លំ ..... 46

២.១១.៦ បញ្ជរទំនាក់ទំនងអំពីអនាម័យ និងភូតគាមអនាម័យ (SPS Enquiry Points) ..... 46

២.១១.៧ ការងារពាក់ព័ន្ធ ACCSQ, ATFC, ARASFF, ARASCP, ACOST, ACCP ..... 47

២.១១.៨ ការងារគណៈកម្មាធិការ Codex ជាតិ ..... 48

២.១១.៩ ការកសាងច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ការងារកាំកុងត្រូល ..... 48

២.១១.១០ ការងារមន្ទីរពិសោធន៍ ..... 48

២.១២ ការងារមន្ត្រី បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 49
២.១៣ ហេរិញ្ញវត្ថុ និងហិរញ្ញវត្ថុ ........ 53
២.១៤ ការងារសន្តិសុខសង្គម និងសន្តិធិអាស៊ាន ........ 55
២.១៥ ការងារអធិការកិច្ច និងសវនកម្ម ........ 56
២.១៥.១ ការងារអធិការកិច្ច ........ 56
២.១៥.២ ការងារសវនកម្មផ្ទៃក្នុង ........ 57
២.១៦ ការងារសង្គមកិច្ច និងសមិទ្ធភាព ........ 57
២.១៧ ការងារយេនឌ័រ ........ 58
២.១៨ សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ........ 59
២.១៨.១ ការងារអាជីវកម្ម ........ 59
២.១៨.២ ការងារជំរុញពាណិជ្ជកម្ម ........ 59
III/ ទិសដៅការងារ
៣. ទិសដៅការងារពាណិជ្ជកម្មឆ្នាំបន្ត ........ 60
ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

# របាយការណ៍
# បូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១៥
# និង
# ទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ២០១៦

## សេចក្តីផ្តើម

អាស្រ័យដោយមានមាគ៌ាគោលនយោបាយដឹកនាំ ឆន្ទៈមោះមុត និងការអនុវត្តដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយមានការចូលរួមចំណែកគាំទ្រ ពីកម្លាំងសាមគ្គីជាតិជាធ្លុងមួយរបស់ប្រជាជន រួមជាមួយនឹងការជួយជ្រោមជ្រែងឧបត្ថម្ភគាំទ្រ ពីបណ្តាប្រទេសជាមិត្ត និងដៃគូអភិវឌ្ឍន៍នានា រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំប្រទេសឲ្យចាកផុត ពីស្ថានភាពដ៏លំបាកលំបិនបំផុត ឈានទៅមុខជាជំហានៗ ឆ្លងកាត់ពីដំណាក់កាលរីកចម្រើនមួយ ទៅកាន់ដំណាក់កាលរីកចម្រើនមួយទៀត ប្រកបដោយមោទនភាព និងក្តីសង្ឃឹម ទោះបីជាត្រូវប្រឈមនឹងឧបសគ្គដ៏ស្មុគស្មាញធំធេង និងរាប់សែនជំពូកនៅចំពោះមុខយ៉ាងណាក៏ដោយ។

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា គោរពប្រតិបត្តិខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ដើម្បីថែរក្សា និងពង្រីករាល់សមិទ្ធផលដែលសម្រេចបានតាំងពីថ្ងៃ **ជ័យជំនះ ៧ មករា** បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ។ សមិទ្ធផលនៃកិច្ចអភិវឌ្ឍរបស់កម្ពុជាក្នុងរយៈពេលកន្លងទៅនេះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជាឆ្ពោះទៅរកសន្តិភាពយូរអង្វែង និងការអភិវឌ្ឍប្រកបដោយចីរភាពដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ និងការពង្រឹងស្ថាប័នប្រជាធិបតេយ្យ ការធានាបាននូវអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ព្រមទាំងកែលម្អជីវភាពប្រជាជន។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដែលបានដាក់បញ្ចូលនូវចំណុចគន្លឹះសំខាន់ៗដូចជា អភិបាលកិច្ចល្អ នីតិរដ្ឋ ការច្បាប់ និងការពង្រឹងសមត្ថភាពស្ថាប័ន ដោយអនុវត្តតាមគំរូប្រទេសជឿនលឿន ដែលមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ធនធានមនុស្ស និងការគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានធម្មជាតិ ដែលចំណុចទាំងអស់នេះបានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ៤ យ៉ាង តាមរយៈបាវចនា "**កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព**" និងសម្រាប់បន្តជំរុញដំណើរការអភិវឌ្ឍ។

ដើម្បីសម្រេចបានតាមគោលដៅទាំង ៤ ខាងលើ ដោយឡែកវិស័យពាណិជ្ជកម្ម នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា បានយកចិត្តទុកដាក់អភិវឌ្ឍន៍វិស័យនេះតាមរយៈ ការធ្វើពិពិធកម្មទីផ្សារនាំចេញ ការបង្កើនល្បឿនសមាហរណកម្ម ទៅក្នុងក្របខ័ណ្ឌពាណិជ្ជកម្មសេរី ការពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពផលិត និងផ្គត់ផ្គង់ យកចិត្តទុកដាក់ជាប្រចាំ លើការរក្សាស្ថេរភាពថ្លៃទំនិញនៅលើទីផ្សារ បង្កលក្ខណៈងាយស្រួលឲ្យផលិតផល និងទំនិញ ធ្វើចរាចរបានដោយសេរី នៅគ្រប់ទីកន្លែង ដោយឈរលើគោលការណ៍ប្រកួតប្រជែងស្មើភាព ការពារ និងលើកតម្កើងកម្មសិទ្ធិបញ្ញា បន្តលើកស្ទួយទំនិញសម្គាល់ភូមិសាស្ត្រ ពង្រឹងការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ទប់ស្កាត់សកម្មភាពប្រកួតប្រជែង មិនស្មោះត្រង់ រាំងស្កាត់ការផលិត និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ឬខូចគុណភាព។

ឆ្លើយតបទៅនឹងយន្តការ អភិវឌ្ឍវិស័យពាណិជ្ជកម្ម ដែលព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងធ្វើសកលភាវូបនីយកម្មក្នុងតំបន់ និងពិភពលោក ហើយក៏បានកំពុងត្រៀមខ្លួនចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ឆ្នាំ២០១៦ នេះផងដែរ កត្តាទាំងនេះតម្រូវឲ្យកម្ពុជាខិតខំធ្វើការប្រកួតប្រជែងដំខ្លាំងក្លាក្នុងវិស័យពាណិជ្ជកម្ម និងវិនិយោគជាមួយបណ្តាប្រទេសសមាជិកដទៃទៀត។ ផ្តើមចេញពីមូលហេតុខាងលើក្រសួងពាណិជ្ជកម្ម បានខិតខំពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់ខ្លួនតាមរយៈការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ រួមមាន ៖ ចេនាសម្ព័ន្ធ ការអភិវឌ្ឍស្ថាប័ន ការពង្រឹងធនធានមនុស្ស ការកែលម្អសេវាសាធារណៈ។ ជាក់ស្តែងនៅឆ្នាំ២០១៦ ក្រសួងមានទិសដៅពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ននៅថ្នាក់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដើម្បីឲ្យការអភិវឌ្ឍវិស័យពាណិជ្ជកម្មនៅមូលដ្ឋានបានរឹងមាំ ជាសេនាធិការឲ្យក្រសួង ក្នុងការគ្រប់គ្រងវិស័យនេះបានទូលំទូលាយ ក្នុងគោលដៅអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញវិស័យពាណិជ្ជកម្មទៅជាឧបករណ៍ដ៏មានសារៈសំខាន់នៅក្នុងចំណោមវិស័យសំខាន់ៗ នៃសេដ្ឋកិច្ចជាតិ រួមចំណែកអភិវឌ្ឍន៍ និងធានាបានការរីកចម្រើនជាបន្តបន្ទាប់ឥតឈប់ឈរ។

## I. **កំណែទម្រង់**

### ១.១ កំណែទម្រង់រដ្ឋបាលសាធារណៈ

#### ១.១.១ កំណែទម្រង់ធនធានមនុស្ស

- ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្ម ផ្ទេរការបើកបៀវត្សតាមប្រព័ន្ធធនាគារ ក្នុងនោះនៅថ្នាក់ជាតិមានចំនួន ១.២២២នាក់ ថ្នាក់ក្រោមជាតិមានចំនួន ៤៨២នាក់។ មិនទាន់បានបើកគណនីបៀវត្សតាមប្រព័ន្ធធនាគារមានចំនួន ៦៧នាក់ មន្ត្រីកម្មសិក្សាចំនួន ៦០នាក់ និងសិក្សាក្រៅប្រទេសចំនួន ១នាក់
- បានរៀបចំកែសម្រួលប្រាក់បំណាច់មុខងារ ជូនមន្ត្រីរាជការចំនួន ៥០នាក់ (ចាប់ពីថ្នាក់អគ្គនាយករហូតដល់មន្ត្រី) ឲ្យសមស្របតាមអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៥

### ១.១.២ កំណែទម្រង់ក្នុងការផ្តល់សេវាសាធារណៈ

#### ១.១.២.១ កំណែទម្រង់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ

- រៀបចំ និងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការដាក់ពាក្យ និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) ដើម្បីកាត់បន្ថយពេលវេលា និងការចំណាយផ្សេងៗ
- ត្រៀមអនុវត្តការទូទាត់ដោយស្វ័យប្រវត្តិ ជាមួយធនាគារពាណិជ្ជ ដែលបានចុះអនុស្សរណៈរួចហើយជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើការពិភាក្សាវាយតម្លៃជាមួយនឹង គណៈកម្មាធិការអនុវត្តគម្រោងប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ប្រភពដើមទំនិញ (គ.គ.វ.ប) ដើម្បីពិនិត្យលក្ខណៈសម្បត្តិឲ្យស្របតាមលក្ខណៈវិនិច្ឆ័យ នៃវិធានក្នុងការចេញវិញ្ញាបនបត្រស្វ័យបញ្ជាក់ប្រភពដើមទំនិញ របស់ក្រុមហ៊ុន Denso (Cambodia) Co.,Ltd និងក្រុមហ៊ុន Golden Rice (Cambodia) Co.,Ltd
- រៀបចំគណៈកម្មការគ្រប់គ្រងការប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ប្រភពដើមទំនិញ និងបានចុះធ្វើអធិការកិច្ចវាយតម្លៃ ដោយចេញលិខិតទទួលស្គាល់ជានីតិបុគ្គលឲ្យចូលរួមអនុវត្តគ្រប់គ្រងការប្រើប្រាស់វិក្កយបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ប្រភពដើមទំនិញសម្រាប់ក្រុមហ៊ុនទាំងពីរនេះ
- ជូនដំណឹងទៅសហភាពអឺរ៉ុប ស្តីពីការស្ម័គ្រចិត្តចូលរួមការអនុវត្តសាកល្បងនូវប្រព័ន្ធអ្នកនាំចេញដែលបានចុះបញ្ជីសម្រាប់ការនាំចេញទៅសហភាពអឺរ៉ុប (Registered Exporter REX) និងបានទទួលយកការរំលែកបទពិសោធន៍ ពីមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានសហភាពពន្ធដារ និងគយរបស់គណៈកម្មការអឺរ៉ុប ដើម្បីទទួលចំណេះដឹង ស្តីពីការអនុវត្តគម្រោងនេះ
- ជាលទ្ធផលក្នុងឆ្នាំ២០១៥នេះ មានក្រុមហ៊ុននាំចេញចំនួន ៥៨១ បានមកចុះបញ្ជីសុំអនុវត្តការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (C/O Online Application)។

#### ១.១.២.២ កំណែទម្រង់ការចុះបញ្ជីពាណិជ្ជកម្ម

- ពាក្យស្នើសុំ (Form) កាត់បន្ថយព័ត៌មានតម្រូវពី ៨ទំព័រ មកនៅសល់តែ ៤ទំព័រ
- លុបចោលការតម្រូវឲ្យមានលិខិតបញ្ជាក់ពីការតម្កល់ដើមទុនពីធនាគារនៅមុនពេលបង្កើតក្រុមហ៊ុន
- លុបចោលការតម្រូវឲ្យចំណាយលើការចុះផ្សាយក្រុមហ៊ុនក្នុងព្រឹត្តិបត្រក្រសួងពាណិជ្ជកម្ម
- លុបចោលការតម្រូវឲ្យប្រធានក្រុមហ៊ុនមកបង្ហាញខ្លួនដោយគ្រាន់តែទាមទារលិខិតបញ្ជាក់ពីមេធាវីឬសារការី
- បែងចែកតួនាទីថ្នាក់ដឹកនាំ និងធ្វើប្រតិភូកម្មជូនថ្នាក់ក្រោមឲ្យត្រួតពិនិត្យឯកសារ និងចុះហត្ថលេខាលើឯកសារ
- រៀបចំ និងដំណើរការស្វ័យប្រវត្តិកម្មពេញលេញ ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ដែលបានប្រកាសឲ្យប្រើប្រាស់កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីកាត់បន្ថយនូវពេលវេលា តម្រូវការឯកសារ និងការចំណាយ ។

#### ១.១.២.៣ កំណែទម្រង់ការចុះបញ្ជីកម្មសិទ្ធិបញ្ញា

- កំពុងដំណើរការរៀបចំស្នើ "កែសម្រួលកម្រៃសេវាសាធារណៈពាក់ព័ន្ធនឹងការងារកម្មសិទ្ធិបញ្ញា" និង "នីតិវិធីលម្អិតក្នុងការចុះបញ្ជីម៉ាក និងគ្រប់គ្រងម៉ាក"

- រៀបចំការចុះបញ្ជីម៉ាកតាមប្រព័ន្ធអនឡាញ (Online) និងកំពុងដាក់ឲ្យដំណើរការ ការចេញលិខិតទទួលស្គាល់ការដាក់ពាក្យដោយស្វ័យប្រវត្តិ ដែលតាមរយៈនេះ អ្នកស្នើសុំចុះបញ្ជីម៉ាកអាចតាមដានដំណើរការចុះបញ្ជីម៉ាករបស់ខ្លួន តាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសអាចដឹងពីព័ត៌មានពីការចេញវិញ្ញាបនបត្រចុះបញ្ជីម៉ាក ទន្ទឹមនឹងនេះក៏បានរៀបចំនីតិវិធី និងកំណត់ពេលវេលាក្នុងការត្រួតពិនិត្យម៉ាកឲ្យបានច្បាស់លាស់ និងឆាប់រហ័សជាងមុន
- បញ្ចប់គម្រោងនីដីថលភាវូបនីយកម្មឯកសារកម្មសិទ្ធិបញ្ញា (Digitization) និងបានដាក់ដំណើរការគ្រប់គ្រងឯកសារតាមប្រព័ន្ធអេឡិចត្រូនិក (EDMS) ដែលបង្កលក្ខណៈងាយស្រួលដល់ការសិក្សាស្រាវជ្រាវ និងការប្រើប្រាស់ផ្សេងៗ
- ចូលជាសមាជិកនៃពិធីសារទីក្រុងម៉ាឌ្រីដ ស្តីពី "ការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ" និងរៀបចំប្រកាស ស្តីពី "នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ" ដែលបើកទូលាយដល់ការស្នើសុំចុះបញ្ជីម៉ាកនៅកម្ពុជា ឲ្យកាន់តែមានលក្ខណៈងាយស្រួល និងទូលំទូលាយ
- កែសម្រួលទម្រង់លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខ និងរៀបចំប្រកាស ស្តីពី "ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ"។

## ១.២ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ១.២.១ ការរៀបចំផែនការ

- ក្រុមការងារកំណែទម្រង់ហិរញ្ញវត្ថុក្រសួង បានចូលរួមប្រជុំ និងតាមដានវឌ្ឍនភាព ជាមួយអគ្គលេខាធិការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អន្តរក្រសួង និងដៃគូអភិវឌ្ឍន៍ប្រចាំខែ ត្រីមាស និងឆមាស
- ចូលរួមសិក្ខាសាលាស្តីពីបទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធី ដើម្បីពង្រឹង និងទទួលបានបទពិសោធន៍ពីការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ទទួលគណៈប្រតិភូរបស់ PEFA Council ដែលបានមកក្រសួងក្នុងគោលបំណងស្វែងរកព័ត៌មានបន្ថែមទាក់ទងនឹងសូចនាករ (ពាក់ព័ន្ធនឹងការងារចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដារ)
- ចូលរួមកែសម្រួលផែនការសកម្មភាពដំណាក់កាលទី២ ថ្មី (MAP2 new)
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី២ថ្មី ជារៀងរាល់ត្រីមាសនីមួយៗ ផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) សម្រាប់អនុវត្តពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨
- រៀបចំសំណុំឯកសារវាយតម្លៃបង្កើតអង្គភាពថវិកា និងអង្គភាពលទ្ធកម្ម សម្រាប់ការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៦។

### ១.២.២ ការត្រៀមខ្លួនសម្រាប់ការងារថវិកាកម្មវិធី

ដើម្បីត្រៀមខ្លួនបានល្អសម្រាប់អនុវត្តការងារថវិកាកម្មវិធីក្រសួងបានដំណើរការ៖

- រៀបចំក្រុមការងារថវិកា (ជ្រើសរើសមន្ត្រីដែលមានសមត្ថភាព និងជំនាញខាងហិរញ្ញវត្ថុ ដើម្បីធានាបានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការរៀបចំថវិកា)

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា (ផែនការថវិការយៈពេលមធ្យម ០៣ឆ្នាំ ដែលឆ្លុះបញ្ចាំងពីគោលបំណង គោលនយោបាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត កសាងកម្មវិធីអនុកម្មវិធី ដើម្បីអនុវត្ត និងកំណត់សូចនាករ និងគោលដៅសូចនាករដើម្បីវាស់វែងការអនុវត្ត)
- បង្កើតអង្គភាពថវិកា (ដែលត្រូវទទួលអាណត្តិកិច្ចច្បាស់លាស់ ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ ហើយដែលលទ្ធផលទាំងនោះរួមចំណែកក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង
- បង្កើតក្រុមការងារលេទ្ធកម្ម នៃអង្គភាពថវិកា (ដើម្បីឲ្យសមស្របនឹងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងដើម្បីឲ្យអង្គភាពថវិកាអនុវត្តថវិកាបានលឿន និងទាន់ពេលវេលា ក្នុងការអនុវត្តសកម្មភាព ចង្កោមសកម្មភាព
- បើកវគ្គបណ្តុះបណ្តាលថវិកាកម្មវិធី (ពង្រឹងមន្ត្រីក្នុងក្រសួងបន្ថែមក្នុងការអនុវត្តថវិកាកម្មវិធី)។

## ១.៣ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ១.៣.១ ការធ្វើភាពមុខងារ

- ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម បានចុះហត្ថលេខាលើសេចក្តីសម្រេចរួម ជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) រៀបចំបញ្ជីភាគមុខងាររបស់ក្រសួងយ៉ាងយូរត្រឹមខែធ្នូ ឆ្នាំ២០១៥
- ការងារនេះដឹកនាំដោយក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ របស់ក្រសួងពាណិជ្ជកម្ម និងជាត់ចែងអនុវត្តដោយក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមការងារបានដំណើរការទៅតាម ផែនការសកម្មភាព ដើម្បីអនុវត្តការងាររៀបចំបញ្ជីភាគមុខងាររបស់ក្រសួង ដែលមានចំនួន ១០ជំហាន និងធ្វើសិក្ខាសាលាវាយតម្លៃ និងផ្សព្វផ្សាយបញ្ចប់នៅក្នុងខែធ្នូនេះ
- ដើម្បីសម្រេចឲ្យបានតាមកម្មវិធីដែលបានគ្រោងទុកទាំង ១០ជំហាន សម្រាប់ការរៀបចំបញ្ជីភាគមុខងាររបស់ក្រសួងពាណិជ្ជកម្មមានដូចខាងក្រោម៖

  1. រៀបចំ និងឯកភាពលើផែនការការងារសម្រាប់រៀបចំបញ្ជីភាគមុខងារ
  2. ស្រង់មុខងារដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា
  3. ពិនិត្យផ្ទៀងផ្ទាត់មុខងារដែលបានស្រង់ក្នុងជំហាន២ ជាមួយការអនុវត្តជាក់ស្តែង
  4. ពិនិត្យផ្ទៀងផ្ទាត់បន្ថែមលើមុខងារ ដែលមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ជាមួយនឹងផែនការ និងយុទ្ធសាស្ត្រសំខាន់ៗ រយៈពេលមធ្យម
  5. ប្រមូលសរុបព័ត៌មានដែលប្រមូលបាននៅក្នុងជំហានទី២ ដល់ទី៤
  6. ប្រមូលព័ត៌មានអំពីការប្រមូលបុគ្គលិកទាំងនេះជាមួយ នឹងមុខងារដែលកំណត់នៅជំហានទី៥
  7. ប្រមូលព័ត៌មានអំពីការប្រមូលហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងផ្គូផ្គងធនធានហិរញ្ញវត្ថុទាំងនេះ ជាមួយនឹងមុខងារតន្លឹះដែលកំណត់ក្នុងជំហានទី៥
  8. ប្រមូលព័ត៌មានអំពីការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងផ្គូផ្គងធនធានហិរញ្ញវត្ថុទាំងនេះជាមួយនឹងមុខងារដែលកំណត់នៅក្នុងជំហានទី៥
  9. ចងក្រងជាឯកសារនូវបទពិសោធន៍ពាក់ព័ន្ធនឹងវិមជ្ឈការ និងវិសហមជ្ឈការមុខងារ និងការចុះកិច្ចសន្យាជាមួយវិស័យឯកជន និងអង្គការសង្គមស៊ីវិល

១០. រៀបចំនិងឯកភាពលើរបាយការណ៍ដែលត្រូវបានដាក់ជូន លេខាធិការដ្ឋាន គ.ជ.អ.ប សរុបពីជំហានទី១ ដល់ជំហានទី៩។

- បច្ចុប្បន្នក្រុមការងារបានរៀបចំបញ្ចប់បញ្ជីវិភាគមុខងាររបស់ក្រសួងពាណិជ្ជកម្មរួចរាល់និងដាក់ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងសម្រេចបន្ទាប់ពីរៀបចំសិក្ខាសាលាផ្សព្វផ្សាយបញ្ចប់។

### ១.៣.២ ការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីឆ្លើយតបឲ្យបានតាមគោលដៅកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការដែលតម្រូវឲ្យគ្រប់ក្រសួង ស្ថាប័ន ត្រូវផ្ទេរមុខងារ ធនធាន ព្រមទាំងថវិកា យ៉ាងតិចចំនួន ០១ ទៅថ្នាក់ក្រោមជាតិសម្រាប់អនុវត្តក្នុងឆ្នាំ២០១៥ ក្រសួងពាណិជ្ជកម្ម ក៏បានគ្រោងរៀបចំផ្ទេរមុខងារយ៉ាងតិចចំនួន ០១ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ទៅឲ្យថ្នាក់ក្រោមជាតិ ក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តរួមមាន៖

- ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម
- ដើម្បីពង្រឹងសមត្ថភាពមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ក្នុងទិសដៅឆ្នាំ២០១៦ នេះ ក្រសួងគ្រោងធ្វើប្រតិភូកម្ម ការងារចេញលិខិតអនុញ្ញាតបិទស្លាកថ្លៃជាប្រិយប័ណ្ណបរទេស ទៅមន្ទីរពាណិជ្ជកម្មរាជធានីខេត្តដើម្បីគ្រប់គ្រង និងអនុវត្ត។

## II. សកម្មភាពពាណិជ្ជកម្មដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

### ២.១ លទ្ធផលនៃការបម្រើសេវាសាធារណៈ

### ២.១.១ ការងារកម្មសិទ្ធិបញ្ញា

លទ្ធផលនៃការបម្រើសេវាកម្មសិទ្ធិបញ្ញាជូនសាធារណជនមានដូចខាងក្រោម៖

- សេវាទាក់ទងការចុះបញ្ជីម៉ាក និងការទទួលស្គាល់សិទ្ធិផ្តាច់មុខ:

| ល.រ | បរិយាយមុខចំណូល | ម៉ាក | ២០១៤ | ២០១៥ | ភាគរយ |
|---|---|---|---|---|---|
| ១ | ដាក់ពាក្យ | ក្នុងស្រុក | ១.០៧៣ | ១.៣២៥ | ២៣,៤៩% |
| | | ក្រៅស្រុក | ៤.៩៧៣ | ៤.៣៥៤ | -១២,៤៥% |
| | | សរុប | ៦.០៤៦ | ៥.៦៧៩ | -៦,០៧% |
| ២ | ចុះបញ្ជីម៉ាក | ក្នុងស្រុក | ៧៥៤ | ៨១៦ | ៨,២២% |
| | | ក្រៅស្រុក | ៣.៧១១ | ៤.៣៧៧ | ១៧,៩៥% |
| | | សរុប | ៤.៤៦៥ | ៥.១៩៣ | ១៦,៣០% |
| ៣ | ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ | | ២.០៨៧ | ២.១៥៤ | ៣,២១% |
| ៤ | ការផ្លាស់ប្តូរផ្សេងៗ | | ១.៣៣៧ | ២.០៨០ | ៥៥,៥៧% |
| ៥ | ការដាក់ពាក្យ និងការចុះបញ្ជីសាជាថ្មី | | ១.៥៦៤ | ១.៤៩១ | -៤,៦៧% |
| ៦ | ការទទួលស្គាល់សិទ្ធិផ្តាច់មុខ | | ៤៥ | ១០១ | ១២៤,៤៤% |
| ៧ | ការស្នើសុំកត់ត្រាអាជ្ញាប័ណ្ណ | | ២៤ | ៣៦ | ៥០% |
| ៨ | ការស្វែងរកម៉ាក | | ៩១៥ | ១២១៥ | ៣២,៧៩% |
| ៩ | ការធ្វើវិញ្ញាបនបត្រ | | ៤៧៨ | ៣៨៧ | -១៩,០៤% |
| ១០ | ការដាកពិន័យមកបង់ប្រាក់ចុះបញ្ជីយឺត | | ០ | ១២៣ | ១០០% |
| ១១ | ការដាកពិន័យមកបង់ប្រាក់ចុះបញ្ជីសារជាថ្មីយឺតយ៉ាវ | | ០ | ២៩ | ១០០% |

កំណត់សម្គាល់: ការចុះបញ្ជីពាណិជ្ជសញ្ញាក្នុងឆ្នាំ២០១៥ មានចំនួន ៥.១៩៣ម៉ាក ប្រៀបធៀបទៅឆ្នាំ ២០១៤ ដែលមានចំនួន ៤.៤៦៥ម៉ាក ឃើញថាមានការកើនឡើង ១៦,៣០%។

- សេវាទាក់ទងនឹងវិវាទកម្មសិទ្ធិបញ្ញា:

**បណ្តឹង និងដំណោះស្រាយវិវាទ ២០១៥**

| | | ដំណោះស្រាយ | | |
|---|---|---|---|---|
| | | ដោះស្រាយរួច | | កំពុងបន្តពិនិត្យ |
| **បណ្តឹង**<br>ឆ្នាំ២០១៥: ២២ករណី=២២ម៉ាក<br>សល់ពីឆ្នាំ២០១៤: ២០ករណី | សុំទប់ស្កាត់ការរំលោភបំពាន<br>ឆ្នាំ២០១៥ (១២ករណី=១២ម៉ាក)<br>សល់ពីឆ្នាំ២០១៤(២០ករណី) | សម្រុលមានកំណត់ហេតុ | ១៤ករណី | ១១ករណី |
| | | ចេញលិខិតបញ្ជាក់ភាពស្រដៀង និងសុពលភាពប្រើប្រាស់ | ៧ករណី | |
| | សុំលុបចេញពីបញ្ជីម៉ាក<br>ឆ្នាំ២០១៥ (១០ករណី=១០ម៉ាក)<br>សល់ពីឆ្នាំ២០១៤<br>(៣៩ករណី=៥១ម៉ាក) | បដិសេធពាក្យបណ្តឹង | ២ករណី=២ម៉ាក | ៣២ករណី=៤៤ម៉ាក |
| | | លុបចេញពីបញ្ជី | ៥ករណី=៥ម៉ាក | |
| | | ជួរជំនួញទំនិញ | ១ករណី=១ម៉ាក | |
| | | កែតម្រូវ | ១ករណី=១ | |
| | | រក្សាសុពលភាព | ៤ករណី=៤ម៉ាក | |

កំណត់សម្គាល់: បើប្រៀបធៀបឆ្នាំ២០១៥ ធៀបនឹងឆ្នាំ២០១៤៖

- ការទទួលពាក្យស្នើសុំទប់ស្កាត់ការរំលោភបំពាន មានការថយចុះ ១៣ករណី ឬ៥៤%
- ការទទួលពាក្យស្នើសុំលុបម៉ាកចេញពីបញ្ជីមានការថយចុះចំនួន ១១ករណី ឬ៥០%
- ការដោះស្រាយការរំលោភបំពានមានការកើនឡើងចំនួន ៧ករណី ឬ៧៥%
- ការលុបម៉ាកចេញពីបញ្ជីក្នុងឆ្នាំ២០១៥ មានការថយចុះចំនួន ៤ម៉ាក ឬ៩១%។

- សហប្រតិបត្តិការកម្មសិទ្ធិបញ្ញា និងការងារផ្សេងៗ:
  - ឆ្លើយតបទៅអង្គការពាណិជ្ជកម្មពិភពលោក (WTO) ពាក់ព័ន្ធនឹងពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀង ស្តីពី "ទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPs)" សម្រាប់សុខភាពសាធារណៈ
  - ធ្វើលិខិតចាត់តាំងឈ្មោះមន្ត្រីទំនាក់ទំនង (Contact Points) ដើម្បីផ្លាស់ប្តូរព័ត៌មានអំពីពាណិជ្ជកម្មទំនិញដែលរំលោភកម្មសិទ្ធិបញ្ញា ដែលជាកាតព្វកិច្ចក្រោមមាត្រា៦៩ នៃកិច្ចព្រមព្រៀង TRIPs
  - រៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពី "ការបង្កើតអនុគណៈកម្មាធិការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងអនុគណៈកម្មាធិការអប់រំ និងផ្សព្វផ្សាយ"

- ដាក់តម្កល់លិខិតុបករណ៍ចូលជាសមាជិកពិធីសារទីក្រុងម៉ាឌ្រីដ ស្តីពី "ការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ" នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ នៅអង្គការ WIPO
- បញ្ចប់សេចក្តីព្រាងប្រកាស ស្តីពី "នីតិវិធីចុះបញ្ជី និងការពារម៉ាកបញ្ជាក់អំពីចរិតលក្ខណៈទំនិញ និងសេវា"
- បញ្ចប់សេចក្តីព្រាងប្រកាស ស្តីពី "នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"
- ធ្វើការជាមួយជំនាញការ WIPO ទាក់ទងនឹងយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញា និងការដាក់ម៉ាកយីហោសម្រាប់ផលិតផលក្នុងស្រុកមួយចំនួន នៅខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងរាជធានីភ្នំពេញ
- ទទួលបេសកកម្មជំនាញការ WIPO ដើម្បីពិនិត្យបន្តលើលំហូរការងារដែលបានផ្លាស់ប្តូរក្នុងប្រព័ន្ធ IPAS និងដើម្បីត្រៀមអនុវត្តសាកល្បងការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ
- ធ្វើការជាមួយជំនាញការ WIPO ដើម្បីត្រួតពិនិត្យលំហូរការងារនៃដំណើរការចុះបញ្ជីម៉ាក "Business Process Review (BPR)"
- ទទួលបេសកកម្មជំនាញការ WIPO ស្តីពី នីតិវិធីផ្ទៃក្នុងសម្រាប់ម៉ាឌ្រីដ ច្បាប់ និងបទប្បញ្ញត្តិនានា
- ទទួលបេសកកម្មជំនាញការ KIPO ស្តីពីកិច្ចសហប្រតិបត្តិការប្រព័ន្ធស្វ័យប្រវត្តិកម្មកម្មសិទ្ធិបញ្ញា
- ទទួលជំនាញការ ECAP III ដើម្បីប្រជុំពិភាក្សាលើបញ្ហាសំខាន់ៗ ដូចជា៖ ១) លំហូរការងារកម្មសិទ្ធិបញ្ញា និងការធ្វើសមាហរណកម្មប្រព័ន្ធ (IPAS) ២) ត្រួតពិនិត្យប្រព័ន្ធការដាក់ពាក្យចុះបញ្ជីម៉ាកតាមអេឡិចត្រូនិច (E-Filing) ៣) ការធ្វើសមាហរណកម្មគ្រប់គ្រងឯកសារតាមអេឡិចត្រូនិច ៤) បណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានផ្នែក IT និងក្រុមការងារទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកតាម Online
- ពិភាក្សាជាមួយ JETRO/JPO អំពីផែនការអនុវត្តគម្រោងកម្មសិទ្ធិបញ្ញា និងកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញារវាងស្ថាប័នទាំងពីរនាពេលអនាគត
- ទទួលជួបប្រជុំជាមួយមន្ត្រីជាន់ខ្ពស់សមាគមម៉ាកអន្តរជាតិ (INTA) ស្តីពី "ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា"
- ទទួលជួបពិភាក្សាជាមួយMr.VAN DOORN SETH អនុព័ន្ធកម្មសិទ្ធិបញ្ញាថ្នាក់តំបន់តែងតាំងថ្មីរបស់សហភាពអឺរ៉ុប អំពីស្ថានភាព និងវឌ្ឍនភាពវិស័យកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា
- ទទួលបេសកកម្មជំនាញការ EU ស្តីពីលទ្ធភាពបង្កើតគម្រោងថ្មីៗសម្រាប់បណ្តាឆ្នាំខាងមុខ
- ទទួលបេសកកម្មរបស់ជំនាញការ UNDP ក្នុងប្រទេសកម្ពុជា ដើម្បីពិនិត្យមើល Roadmap ដែលបានបង្កើតឡើង ថាតើអ្វីដែលបានធ្វើ អ្វីមិនបានធ្វើ សេចក្តីត្រូវការជំនួយបច្ចេកទេស និងស្ថានភាពបច្ចុប្បន្ន
- ទទួលបេសកកម្មរបស់ជំនាញការ EPO ដើម្បីតាមដានអំពីកិច្ចសហប្រតិបត្តិការដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំ AWGIPC លើកទី ៤៣ នៅខេត្តសៀមរាប
- ទីប្រឹក្សាជាតិ និងអន្តរជាតិ បានបញ្ចប់សេចក្តីព្រាង "Enforcement Manual និង Sub-decree on Enforcement Procedures"
- កំពុងអនុវត្តគម្រោងថ្នាក់តំបន់ (កម្ពុជា វៀតណាម ឡាវ និងថៃឡង់ដ៍) ស្តីពី "ការចុះបញ្ជីម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ" ក្រោមកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារបារាំងដើម្បី

ការអភិវឌ្ឍ (AFD) និងអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (Food and Agriculture of the United Nation - FAO)

- ECAP III បានជួយគាំទ្រផ្នែកច្បាប់ ដល់ការចុះបញ្ជីម្រេចកំពត នៅសហភាពអឺរ៉ុប។ បច្ចុប្បន្ន ពាក្យស្នើសុំម្រេចកំពត ត្រូវបានបោះពុម្ពផ្សាយ ដោយបើកឱកាសឲ្យភាគីដែលមានផលប្រយោជន៍ ដើម្បីប្តឹងជំទាស់
- សហការជាមួយអង្គការ WIPO ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលកម្មសិទ្ធិបញ្ញា (IP Academy on Training for Trainers)
- ជួយសម្របសម្រួលលើការស្នើសុំសិទ្ធិគ្រប់គ្រងមរតកសាសន៍លើបទចម្រៀង ដែលមានចំណងជើងថា "ឈាមខ្មៅ" ពីលោកស្រី រស់ សារឿន ដែលជាបងស្រីបង្កើតរបស់តារាចម្រៀងពជនីសម្លេងមាសលោកស្រី រស់ សេរីសុទ្ធា។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានចេញលិខិតប្រគល់សិទ្ធិគ្រប់គ្រងនេះជូនដល់ លោកស្រី រស់ សារឿន រួចហើយ
- ជួយសម្របសម្រួលរៀបចំការប្រគុំតន្ត្រី "ពេលវេលាដែលត្រូវតបស្នង" និងប្រមូលថវិកាជូនសិល្បៈករជំនាន់ដើម
- រៀបចំសិក្ខាសាលាក្នុងស្រុកចំនួន ១០លើក ដែលមានចំនួនអ្នកចូលរួមសរុប ១.៣២០ នាក់ និងបានបញ្ជូនមន្ត្រីទាក់ទងកម្មសិទ្ធិបញ្ញា ចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលចំនួន ៦៨លើក ដែលមានចំនួនសរុប ១៣១រូប
- បោះពុម្ពព្រឹត្តិបត្រផ្លូវការ (Official Gazette) ប្រចាំខែពីខែមករា ដល់ខែកញ្ញា បានសរុបចំនួន ៩លេខ គឺចាប់ពីលេខ ១៧៨ ដល់ ១៨៦ និងចាប់ផ្តើមបោះពុម្ពប្រចាំសប្តាហ៍ចាប់ពីខែតុលាតទៅ បានចំនួន ១៣លេខទៀត ដើម្បីផ្សព្វផ្សាយជាសាធារណៈ។

## ២.១.២ ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់សេវាពាក់ព័ន្ធ

- ចុះបញ្ជីក្រុមហ៊ុនថ្មី ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនបរទេសបានចំនួន ៣.៧៩៨ក្រុមហ៊ុន មានកំណើន ១១,៩៤% ធៀបនឹងឆ្នាំ២០១៤
- ចុះបញ្ជីថ្មីសហគ្រាសឯកបុគ្គលមានចំនួន ១.២១៧សហគ្រាស មានកំណើន ៧១,៦៥% ធៀបនឹងឆ្នាំ២០១៤
- ចុះបញ្ជីការកែប្រែក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម សាខាក្រុមហ៊ុនបរទេសមានចំនួន ៣.៨៥៣ក្រុមហ៊ុន មានកំណើន ៣៩,២០% ធៀបនឹងឆ្នាំ២០១៤
- ចុះបញ្ជីកែប្រែរបស់សហគ្រាសឯកបុគ្គលចំនួន ៦១២សហគ្រាស មានកំណើន ៩៣,៦៧% ធៀបនឹងឆ្នាំ២០១៤
- លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ការិយាល័យតំណាងពាណិជ្ជកម្ម សាខាក្រុមហ៊ុនបរទេសចំនួន ៣៧ក្រុមហ៊ុន ឃើញថាមានការថយចុះ ២៨,៨៥% ធៀបនឹងឆ្នាំ២០១៤
- លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មរបស់សហគ្រាសឯកបុគ្គលមានចំនួន ៥សហគ្រាស ឃើញថាមានការកើនឡើង ១៥០%
- ប្តូរវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចំនួន ២.៣២១ក្រុមហ៊ុនមានកំណើន ២០,៨២% ធៀបនឹងឆ្នាំ២០១៤
- តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចំនួន ៥.៦៦២ក្រុមហ៊ុន មានកំណើន ២៨,៧៧% ធៀបនឹងឆ្នាំ២០១៤
- ថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្មបានចំនួន ២៩៦ច្បាប់ មានកំណើន ៥៥,៩៧% ធៀបនឹងឆ្នាំ២០១៤។

### ២.១.៣ ការផ្តល់សេវានាំចេញ-នាំចូល

- ចុះបញ្ជីផ្តល់សិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធដូចតទៅ៖
  - រោងចក្រ ឬក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ ចំនួន : ៨៩២ ក្រុមហ៊ុន
  - រោងចក្រផលិតស្បែកជើង ចំនួន : ៩០ ក្រុមហ៊ុន
  - រោងចក្រផ្សេងៗ ចំនួន : ១៦៤ ក្រុមហ៊ុន

  ក្នុងឆ្នាំ ២០១៥ តួលេខរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតទំនិញនាំចេញផ្សេងៗទៀតមានដូចខាងក្រោម៖
  - រោងចក្រកាត់ដេរសម្លៀកបំពាក់ ចំនួន ៨៩២ មានកម្មករ ៦៩៣.៨៧៣នាក់ (ប្រាក់ខែជាមធ្យម ១១៣.៨៦៨.៧០៤ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ) ក្នុងនោះដំណើរការពេញលេញ ៥៩៨ រោងចក្រ មានកម្មករ ៥៣៩.៣១៨នាក់ (ប្រាក់ខែជាមធ្យម ១០១.៩៧៥.៩៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ) គ្រោងបិទទ្វារចំនួន ១៥៦ បិទទ្វារបណ្តោះអាសន្ន ៨ បិទទ្វារជាស្ថាពរ ១៣០
  - រោងចក្រកាត់ដេរស្បែកជើង ចំនួន ៩០ មានកម្មករ ១០៩.៩៧៥នាក់ (ប្រាក់ខែជាមធ្យម ១៧.៨២៧.៩៥៨ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ) ក្នុងនោះដំណើរការពេញលេញ ៧៣ មានកម្មករ ១០៣.៨៦៦នាក់ (ប្រាក់ខែជាមធ្យម ១៧.២៣២.៩៥០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ) បិទទ្វារបណ្តោះអាសន្ន ៣ បិទទ្វារជាស្ថាពរ ១៤
  - រោងចក្រផ្សេងៗ ចំនួន ១៦៤ មានកម្មករ ៩១.៥៩០នាក់ (ប្រាក់ខែជាមធ្យម ៨.៥៦២.៩១៨ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ) ក្នុងនោះដំណើរការពេញលេញ ១៥៦ មានកម្មករ ៩០.០៦៦នាក់ (ប្រាក់ខែជាមធ្យម ៨.៩៧២.៣០៥ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ) មានរោងចក្របិទទ្វារបណ្តោះអាសន្ន ៨ បិទទ្វារជាស្ថាពរ ៩។
- ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងអាជ្ញាប័ណ្ណសម្រាប់នាំចេញលើមុខទំនិញសំខាន់ៗ រួមមាន៖ សម្លៀកបំពាក់, ស្បែកជើង, អង្ករ, កសិផល, ទោចក្រយាន, និងផលិតផលផ្សេងៗទៀតក្នុងឆ្នាំ២០១៥៖
  - ទីផ្សារទ្វីបអាមេរិក៖ មានទឹកប្រាក់សរុបចំនួន ២.០៧៣,១៧លានដុល្លារសហរដ្ឋអាមេរិក
  - នាំចេញទៅសហគមន៍អឺរ៉ុប(EU)៖ មានទឹកប្រាក់សរុបប្រមាណ ២.៣២១,៦៥លានដុល្លារសហរដ្ឋអាមេរិក
  - នាំចេញទៅក្រៅសហគមន៍អឺរ៉ុប (NON-EU)៖ មានទឹកប្រាក់សរុបប្រមាណ ៥៩,១៣លានដុល្លារសហរដ្ឋអាមេរិក
  - នាំចេញទៅទ្វីបអាហ្វ្រិក៖ មានទឹកប្រាក់សរុបប្រមាណ ១៥,៩៥ លានដុល្លារសហរដ្ឋអាមេរិក
  - ការនាំចេញទៅទ្វីបអាស៊ីនិងអូសេអានី៖ មានទឹកប្រាក់សរុបចំនួន ១.១៧៨,២៦លានដុល្លារសហរដ្ឋអាមេរិក
  - ចេញអាជ្ញាប័ណ្ណនាំចេញ មានទឹកប្រាក់សរុបប្រមាណ ១៨,២៥ លានដុល្លារសហរដ្ឋអាមេរិក
  - ចេញអាជ្ញាប័ណ្ណនាំចូល មានទឹកប្រាក់សរុបប្រមាណ ០,៣៨ លានដុល្លារសហរដ្ឋអាមេរិក
  - ការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ មានទឹកប្រាក់សរុបប្រមាណ ១៤,៧៥លានដុល្លារសហរដ្ឋអាមេរិក

- ការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ មានទឹកប្រាក់សរុបប្រមាណ ០,៨៩ លានដុល្លារសហរដ្ឋអាមេរិក

- ការងារធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការនាំចេញៈ បានបញ្ចូល និងធ្វើការកាត់សន្និធិវត្ថុធាតុដើមជូនរោងចក្រផលិតទំនិញទាំងអស់ សម្រាប់ការនាំចេញទៅកាន់ទីផ្សារពិភពលោក
- សហការឆ្លើយបំភ្លឺជាប្រចាំនូវរាល់បញ្ហា ឬចម្ងល់នានារបស់មន្ត្រីគយនៃប្រទេសនាំចូលពីសហភាពអឺរ៉ុប ក្រៅសហភាពអឺរ៉ុប និងប្រទេសនាំចូលដទៃទៀត ចំពោះវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញចេញដោយក្រសួងពាណិជ្ជកម្ម។

## ២.២ ការទាញយកជំរុញពាណិជ្ជកម្ម

### ២.២.១ ការរៀបចំពិព័រណ៍ពាណិជ្ជកម្ម

នៅក្នុងឆ្នាំ២០១៥ ក្រសួងបានរៀបចំ និងចូលរួមពិព័រណ៍ក្រៅប្រទេសបានចំនួន ៣៣លើក និងរៀបចំសម្របសម្រួលឲ្យមានព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសបានចំនួន ១២០លើក ដែលមានព្រឹត្តិការណ៍សំខាន់ៗ ដូចជាៈ

- ពិព័រណ៍ពិភពលោកឆ្នាំ២០១៥ នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី មានរយៈពេល ៦ខែ បានទទួលភ្ញៀវអន្តរជាតិចូលទស្សនាពន្លាជាតិកម្ពុជាចំនួន២.២២២.៨៣១នាក់ និងទទួលបានពានរង្វាន់ប្រាក់មួយគ្រឿង (Silver Award) ពីគណៈកម្មការពិព័រណ៍ពិភពលោកនៃប្រទេសអ៊ីតាលី និងការិយាល័យពិព័រណ៍អន្តរជាតិ (BIE)
- ពិព័រណ៍ចិន-អាស៊ាន លើកទី១២ ក្រុមហ៊ុនកម្ពុជា និងចិនបានចាប់ដៃគូវិនិយោគចុះអនុស្សរណៈយោគយល់គ្នាលើគម្រោងចំនួន ៧ ដើម្បីវិនិយោគនៅកម្ពុជា។

*__លទ្ធផល ការរៀបចំពិព័រណ៍ និងព្រឹត្តិការណ៍ពិព័រណ៍:__*

- ធ្វើឲ្យសាធារណជនបានស្គាល់អំពីទិដ្ឋភាពទូទៅ នៃប្រទេសកម្ពុជា ជាពិសេសពីសក្ដានុពលផ្នែកវិនិយោគ និងពាណិជ្ជកម្ម បានបង្ហាញពីវប្បធម៌ និងសិល្បៈខ្មែរ
- យកផលិតផលមួយចំនួនរបស់កម្ពុជាទៅផ្សព្វផ្សាយ តាំងពិព័រណ៍ និងលក់ជូនភ្ញៀវបរទេស
- បង្កើតវេទិកាពាណិជ្ជកម្ម និងវិនិយោគកម្រិតអន្តរជាតិ និងឈានទៅចុះអនុស្សរណៈលើគម្រោងដៃគូពាណិជ្ជកម្ម និងវិនិយោគនានា
- បង្កលក្ខណៈឲ្យប្រជាជន និងផលិតករមានឱកាសរៀនសូត្រ និងដកបទពិសោធន៍អំពីផលិតផលថ្មីៗ និងរបៀបធ្វើសេវាកម្មដូចជាការធ្វើពាណិជ្ជកម្មជាមួយបរទេស និងជំរុញឲ្យមានការកសាងដៃគូពាណិជ្ជកម្ម និងវិនិយោគ រវាងពាណិជ្ជករក្នុងស្រុក និងបរទេស ក្នុងគោលបំណងបើកទូលាយទីផ្សារក្នុងក្របខ័ណ្ឌសមាហរណកម្មតំបន់ និងពិភពលោក
- បង្កើតទីផ្សារលក់ដុំ ដែលជាកន្លែងផ្លោះប្ដូរពាណិជ្ជកម្មដ៏មានប្រសិទ្ធភាព តាមរយៈការផ្ដល់ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្មទីផ្សារសំខាន់ៗ សម្រាប់ផលិតករ ពាណិជ្ជករក្នុងស្រុក ដោយជំរុញឲ្យប្រជាពលរដ្ឋទទួលស្គាល់ និងគាំទ្រផលិតផលក្នុងស្រុក
- ជំរុញសកម្មភាពពាណិជ្ជកម្មក្នុងស្រុក រវាងបណ្ដាខេត្ត និងខេត្ត-ក្រុង ក្នុងយុទ្ធសាស្ត្រស្វែងរកទីផ្សារតាមរបៀបនាំចេញនៅនឹងកន្លែង។

### ២.២.២ ការទារទីផ្សារ

#### ២.២.២.១ ការស្វែងរក និងអភិវឌ្ឍន៍ទីផ្សារ

- បង្កើតផ្សារព្រំដែនកម្ពុជា-វៀតណាម ដើម្បីជំរុញពាណិជ្ជកម្ម និងការដោះដូរទំនិញជាប់តាមព្រំដែន។ គម្រោងនេះកំពុងអនុវត្តនៅខេត្តត្បូងឃ្មុំ និងខេត្តកែប
- ចរចាការងារ អនាម័យនិងភូតគាមអនាម័យ ឲ្យកសិផលកម្ពុជាអាចនាំចូលទីផ្សារចិន ដោយសហការជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ជាលទ្ធផលទទួលបាន៖
    - អង្ករស ដំឡូងមី និងគ្រាប់ពោត (បានចុះពិធីសាររួច)
    - កញ្ចុងអង្ករ ផ្លែចេក ផ្លែស្វាយ (បានឯកភាពគ្នាលើសេចក្តីព្រាងពិធីសារ)
    - សណ្តែកសៀង (បានដាក់ចូលក្នុងរបៀបវារៈនៃការចរចា)
    - គ្រាប់ស្វាយចន្ទី កាហ្វេ កៅស៊ូ និងផ្លែមៀន (កំពុងធ្វើការស្នើសុំ)
    - រៀបចំបញ្ជីឈ្មោះអ្នកនាំចេញអង្ករដែលមានសក្តានុពល ទៅប្រទេសចិន
- រៀបចំជំរុញផលិតផលសម្រេចកម្ពុជា ចូលទីផ្សារទំនើបចិន ដោយសហការជាមួយសមាគមពាណិជ្ជកម្មចិន និងក្រុមហ៊ុនចែកចាយផលិតផលចិន (P&T Investment Co.ltd)
- សម្របសម្រួលរក្សាទីផ្សារ និងប្រពៃណីផលិតអំបិលនៅកែប និងកំពតដោយទទួលបាន៖
    - ការលើកលែងសួយសារពើ សម្រាប់ការផលិតអំបិលពីទឹកសមុទ្រ ចាប់ពីឆ្នាំ២០១៥
    - ការអនុញ្ញាតដាក់អាករលើតម្លៃបន្ថែម (VAT) ជាបន្ទុករបស់រដ្ឋ ដល់ឆ្នាំ២០១៨
- ធ្វើបច្ចុប្បន្នភាពសៀវភៅនីតិវិធីនាំចេញ ដើម្បីជាឯកសារគ្រឹះក្នុងការណែនាំ និងបង្ហាញដល់ពាណិជ្ជករ និងអ្នកវិនិយោគ ដែលមកធ្វើអាជីវកម្មនៅកម្ពុជា
- ចងក្រងឲ្យផ្សព្វផ្សាយ "ទស្សនាវដ្តីទីផ្សារ" ដើម្បីបង្ហាញផែនទីទីផ្សារ ការផ្គត់ផ្គង់ និងតម្រូវការ
- ដឹកនាំពាណិជ្ជករកម្ពុជា ទៅចុះអនុស្សរណៈ (MOU) ចំនួន ៧គម្រោង ជាមួយក្រុមហ៊ុនចិន នៅក្នុងសិក្ខាសាលា "China –ASEAN Convention 2015"
- សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ដោយពិភាក្សាជាមួយក្រុមហ៊ុនប្រេងឥន្ធនៈធំៗនៅកម្ពុជា ក្នុងការកំណត់រូបមន្តថ្លៃដើមប្រេងឥន្ធនៈ ដើម្បីធានាថ្លៃលក់រាយសមស្របទៅតាមទីផ្សារអន្តរជាតិ។

#### ២.២.២.២ ការពង្រីកដៃគូពាណិជ្ជកម្ម

- សហការជាមួយមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មអាស៊ាន-ជប៉ុន អាស៊ាន-ចិន អាស៊ាន-កូរ៉េ វេទិកាជំរុញពាណិជ្ជកម្មអាស៊ី ដើម្បីជំរុញផលិតផលកម្ពុជាចូលទីផ្សារទាំងនោះ
- រៀបចំជំនួបពាណិជ្ជកម្មរវាងធុរជនកម្ពុជា ជាមួយធុរជននៃបណ្តាប្រទេស ដែលមានទីផ្សារសក្តានុពលដូចជា ចិន ជប៉ុន កូរ៉េ អឺរ៉ុប រុស្ស៊ី និងតួកគី ចំនួន១៦លើក ក្នុងប្រទេស និង ០៨លើកនៅក្រៅប្រទេស និងផ្តល់ប្រឹក្សាយោបល់ដល់ក្រុមហ៊ុនបរទេស ចំនួន ១៨ក្រុមហ៊ុន
- រៀបចំឯកសារ និងព័ត៌មានផលិតផលចាំបាច់សម្រាប់ចុះអនុស្សរណៈជាមួយហុងកុង ដើម្បីជំរុញផលិតផលកម្ពុជាចូលទីផ្សារហុងកុង។

### ២.២.២.៣ ការងារស្ថានតំណាងពាណិជ្ជកម្មក្រៅប្រទេស

- ស្រាវជ្រាវ និងចងក្រងព័ត៌មានសក្តានុពលពាណិជ្ជកម្ម ដើម្បីនាំចេញផលិតផលកម្ពុជា និងទាក់ទាញធុរជនសំខាន់ៗ ឲ្យមកទិញទំនិញ និងវិនិយោគនៅកម្ពុជា
- ផ្តល់ព័ត៌មានជាប្រចាំអំពីសន្ទុស្សន៍ថ្លៃទំនិញសំខាន់ៗ របាំងពាណិជ្ជកម្ម និងគោលនយោបាយពាណិជ្ជកម្មនានាដែលប្រទេសសាមីកំពុងអនុវត្ត
- សម្របសម្រួលបេសកកម្មពាណិជ្ជកម្ម និងជំនួបធុរជនកម្ពុជាដែលធ្វើឡើងនៅក្នុងប្រទេសសាមី
- ចូលរួមក្នុងកិច្ចប្រជុំ និងព្រឹត្តិការណ៍ពាណិជ្ជកម្មនានាដែលរៀបចំនៅប្រទេសសាមី
- ផ្តល់ប្រឹក្សាយោបល់ ការងារពាណិជ្ជកម្ម-វិនិយោគ ដល់ធុរជនវិនិយោគិនបរទេស ដែលមានបំណងមកធ្វើអាជីវកម្មនៅកម្ពុជា។

### ២.២.៣ ការងារអភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្ម

- **ការងារគោលនយោបាយអភិវឌ្ឍន៍ផលិតផលហាឡាល់នៅកម្ពុជា**
  - រៀបចំប្រកាសបង្កើតក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តលើផលិតផលហាឡាល់កម្ពុជា ដែលក្រុមការងារបច្ចេកទេសនេះមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈចាងហ្វាងជាន់ខ្ពស់ឥស្លាមកម្ពុជា
  - ដោយមានជំនួយពីក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពី "ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាល់កម្ពុជា" ដោយបានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងជាបន្តបន្ទាប់ចំនួន ៨លើក រួចមកហើយ ដើម្បីពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យនេះ
  - សេចក្តីព្រាងអនុក្រឹត្យ ស្តីពី "ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាល់កម្ពុជា" ត្រូវបានធ្វើបញ្ចប់នាកិច្ចប្រជុំក្រុមការងារបច្ចេកទេសកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ កន្លងទៅនេះ និងកំពុងរៀបចំនីតិវិធី និងឯកសារគតិយុត្តិផ្សេងៗ ទៀតដើម្បីបញ្ជូនអនុក្រឹត្យទៅកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត។

- **ការងារពិនិត្យតាមដានលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥**
  - រៀបចំកិច្ចប្រជុំផ្ទៃក្នុងក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើការអនុវត្តផែនការលម្អិត របស់ក្រសួងពាណិជ្ជកម្ម ដែលមានចែងក្រោមក្របខ័ណ្ឌអភិវឌ្ឍន៍គោលនយោបាយឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ មន្ត្រីថ្នាក់នាយកដ្ឋានបានចូលរួមកិច្ចប្រជុំប្រចាំខែ ជាបន្តបន្ទាប់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធ្វើបច្ចុប្បន្នភាពលើការងារអនុវត្តផែនការលម្អិតរបស់ក្រសួងពាណិជ្ជកម្មផងដែរ
  - បានរៀបចំប្រកាស ស្តីពី "ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់តាមដានការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥"
  - ធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពនៃការអនុវត្តការងាររបស់ក្រសួងពាណិជ្ជកម្ម ក្រោមក្របខ័ណ្ឌអភិវឌ្ឍន៍គោលនយោបាយអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា តាមរយៈការរៀបចំចងក្រងជារបាយការណ៍ជារៀងរាល់ ៣ខែម្តង សម្រាប់រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពនៃ

ការអនុវត្តភារកិច្ចរបស់ក្រសួង ដែលមានចែងលម្អិត ក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥។

- **គោលនយោបាយអភិវឌ្ឍន៍ផលិតផលម្រេច**

  រៀបចំកម្មវិធីចុះសិក្សា និងធ្វើបច្ចុប្បន្នភាពលើផលិតផលម្រេចនៅកម្ពុជា តាមបណ្តាខេត្តគោលដៅមួយចំនួនរួមមាន៖ ខេត្តត្បូងឃ្មុំ ក្រចេះ រតនគិរី និងមណ្ឌលគិរី

  - រៀបចំផែនការចុះស្រាវជ្រាវផលិតផលម្រេចនេះ នៅបណ្តាខេត្តគោលដៅមួយចំនួនទៀត ដើម្បីក្តាប់ឲ្យបានពីទិន្នន័យ ចង្វាក់ផលិតកម្ម និងតម្លៃបន្ថែម ដើម្បីរៀបចំជាធាតុចូលសម្រាប់កសាងយុទ្ធសាស្ត្រ និងគោលនយោបាយជំរុញផលិតផលម្រេចនៅកម្ពុជាទៅតាមទីផ្សារអន្តរជាតិ
  - ចាត់បញ្ជូនមន្ត្រីជំនាញចុះសិក្សា និងប្រមូលទិន្នន័យដំណាំម្រេច នៅខេត្តពោធិ៍សាត់ និងខេត្តព្រះវិហារ និងត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយផលិតផលម្រេច នៅខេត្តកំពត បាត់ដំបង ត្បូងឃ្មុំ និងភ្នំពេញ
  - រៀបចំសេចក្តីព្រាងផែនការសកម្មភាពសម្រាប់រៀបចំសិក្ខាសាលា ស្តីពី "ការផ្សព្វផ្សាយផលិតផលម្រេចនៅកម្ពុជា" ដែលនឹងគ្រោងរៀបចំឡើងនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

- **ជំនួបទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍លើការងារពាណិជ្ជកម្ម**

  - ចូលរួមជំនួបជាបន្តបន្ទាប់ជាមួយដៃគូអភិវឌ្ឍន៍ លើការងារសហប្រតិបត្តិការពាណិជ្ជកម្មរួមមាន៖ ជំនួបជាមួយតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ជំនួបជាមួយប្រតិភូសភាពាណិជ្ជកម្មមកពីខេត្តណាននីង និងខេត្តហ្វូជៀន ប្រទេសចិន ជំនួបរវាងសភាពាណិជ្ជកម្មតួគី និងក្រសួងពាណិជ្ជកម្ម និងជំនួបជាមួយអង្គការអន្តរជាតិផ្សេងៗទៀត
  - ចូលរួមជួបពិភាក្សាជាមួយ តំណាងសហភាពអឺរ៉ុប ដើម្បីពិនិត្យមើលលទ្ធភាពជំនួយបច្ចេកទេស ដែលសហភាពអឺរ៉ុបគ្រោងផ្តល់ជូនក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសក្រសួងពាណិជ្ជកម្ម តាមរយៈនាយកដ្ឋានDICO
  - រៀបចំគម្រោងស្នើសុំជំនួយបច្ចេកទេស លើការកសាងគោលនយោបាយពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០១៥- ២០២៥ ជូនសហភាពអឺរ៉ុប ដែលជាម្ចាស់ជំនួយសម្រាប់ឆ្នាំ ២០១៥-២០១៨
  - ជួបពិភាក្សាការងារជាមួយប្រធានការិយាល័យតំណាងរបស់អង្គការ JETRO នៅកម្ពុជា ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការបន្ថែមទៀត លើការងារកសាងយុទ្ធសាស្ត្រជំរុញពាណិជ្ជកម្មនៅកម្ពុជា
  - ជួបពិភាក្សាការងារជាមួយក្រុមចរចាពាណិជ្ជកម្មសេរី ពីប្រទេសអូស្ត្រាលី និងណូវែលសេឡង់ ដើម្បីពិនិត្យមើលលើលទ្ធភាពនៃការរៀបចំសិក្ខាសាលា ស្តីពី "ការពង្រឹងពាណិជ្ជកម្មរបស់ SMEs" ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី ប្តូកណូវែលសេឡង់។

- **ការចូលរួមចរចាលើកិច្ចព្រមព្រៀងអនុតំបន់ និងចូលរួមវេទិកាជំរុញពាណិជ្ជកម្មអាស៊ី**

  - ចូលរួមកិច្ចចរចាអនុតំបន់ ដើម្បីបង្កើតកិច្ចព្រមព្រៀងសហប្រតិបត្តិការជំរុញពាណិជ្ជកម្ម និងវិនិយោគ ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា ឡាវ និង វៀតណាម ក្នុងខេត្តក្រចេះ

- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី ២៨ នៃវេទិកាជំរុញពាណិជ្ជកម្មអាស៊ី នៅប្រទេសជប៉ុន ដើម្បីពិភាក្សាផ្លាស់ប្តូរ យោបល់បទពិសោធន៍ និងបន្តអនុវត្តគោលនយោបាយជំរុញពាណិជ្ជកម្ម ជាមួយប្រទេសជាសមាជិកចំនួន ២៨ប្រទេស
- ចូលរួមក្នុងសន្និសីទកំពូលស្តីពី "E-Commerce" នាទីក្រុង Nanning ប្រទេសចិនកាលពីខែកញ្ញា ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការលើវិស័យ E-Commerce រវាងអាស៊ាន-ចិន។

- **ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីបរិយាកាសធុរកិច្ច និងវិនិយោគ កំណែទម្រង់របស់រាជរដ្ឋាភិបាល និងការផ្សព្វផ្សាយជំរុញផលិតផល**

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយជំរុញពាណិជ្ជកម្ម និងវិនិយោគរបស់កម្ពុជាឱ្យបានទូលំទូលាយ និងដើម្បីបញ្ជ្រាបការយល់ដឹងអំពីកំណែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់របស់ក្រសួងពាណិជ្ជកម្មឱ្យដល់ភាគីពាក់ព័ន្ធនានា ជាពិសេសឱ្យដល់វិស័យឯកជនអ្នកនាំចេញ អ្នកផលិត និងសហគ្រាសខ្នាតតូច និងមធ្យម ក្រសួងបានរៀបចំសិក្ខាសាលា និងសន្និសីទដើម្បីផ្សព្វផ្សាយបានចំនួន ៥ លើករួមមាន៖

- សន្និសីទ ស្តីពី "សក្តានុពលអង្ករកម្ពុជា" ត្រូវបានរៀបចំឡើងនាថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៥ នាទីក្រុងមីឡង់ ប្រទេសអ៊ីតាលី នាពេលដែលកម្ពុជាប្រារព្ធទិវាជាតិនៃពិព័រណ៍ពិភពលោកដោយមានអ្នកចូលរួមប្រមាណ ៥០០ នាក់ មកពីវិស័យឯកជនរបស់ប្រទេសអ៊ីតាលី ចូលរួមក្នុងសន្និសីទនេះ
- សន្និសីទ ស្តីពី "សក្តានុពលនៃការធ្វើពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា" ត្រូវបានរៀបចំធ្វើឡើងនៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៥ នាទីក្រុងណាននីងនៃសាធារណរដ្ឋប្រជាមានិតចិន ដោយមានអ្នកចូលរួមពីវិស័យឯកជនចិនប្រមាណ ៥០០នាក់
- សិក្ខាសាលាផ្សព្វផ្សាយ "គោលនយោបាយកែទម្រង់របស់រាជរដ្ឋាភិបាលដើម្បីសម្របខ្លួនតាមរបត់សហគមន៍សេដ្ឋកិច្ចអាស៊ាន" ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណ ៦០៨នាក់ មកពីវិស័យឯកជន ក្រសួងស្ថាប័ននានា របស់រាជរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន
- សន្និសីទថ្នាក់ជាតិ "ការជំរុញកសិ-ពាណិជ្ជកម្ម" រៀបចំធ្វើឡើងនាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ នៅខេត្តសៀមរាប បានផ្តោតសំខាន់ទៅលើផលិតផលកសិកម្មរបស់កម្ពុជាសម្រាប់បម្រើទីផ្សារក្នុងស្រុក និងគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់ជំរុញកសិ-ពាណិជ្ជកម្ម។ សន្និសីទថ្នាក់ជាតិនេះមានការចូលរួមពីដៃគូពាក់ព័ន្ធប្រមាណ ១២០រូប ពីក្រសួងពាក់ព័ន្ធ វិស័យឯកជន និងអ្នកជាប់ពាក់ព័ន្ធផ្សេងៗ ទៀត ។
- រៀបចំសិក្ខាសាលា "សក្តានុពលនៃផលិតផលម្រេចនៅកម្ពុជា" នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ។ សិក្ខាសាលាខាងលើនឹងផ្សព្វផ្សាយអំពីសក្តានុពលម្រេចរបស់កម្ពុជា និងគោលនយោបាយជំរុញការនាំចេញម្រេច របស់រាជរដ្ឋាភិបាលឱ្យដល់អ្នកដាំដុះ និងអ្នកនាំចេញម្រេចចំនួន ១២០រូប។

## ២.៣ ការរៀបចំបទបញ្ញត្តិច្បាប់ពាណិជ្ជកម្ម

- សេចក្តីព្រាងច្បាប់ ស្តីពី "កិច្ចការពារអ្នកប្រើប្រាស់"

សេចក្តីព្រាងច្បាប់នេះត្រូវបានតាក់តែង ដោយមានកិច្ចសហការជាមួយជំនាញការអន្តរជាតិ ក្រោមការឧបត្ថម្ភរបស់ ADB ចាប់ពីឆ្នាំ ២០១៥។ សេចក្តីព្រាងច្បាប់នេះ ទើបនឹងបានបញ្ចប់ ហើយនឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីក្នុងពេលខាងមុខឆាប់ៗនេះ។

- **សេចក្តីព្រាងច្បាប់ ស្តីពី "កិច្ចសន្យាពាណិជ្ជកម្ម"**

  កិច្ចប្រជុំចង្អៀតថ្នាក់បច្ចេកទេស រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ ត្រូវបានរៀបចំឡើងជាច្រើនលើក ដើម្បីកែសម្រួលមាត្រាមួយចំនួន ដែលមិនទាន់ស្របគ្នានឹងច្បាប់ ស្តីពី "ការអនុវត្តក្រមរដ្ឋប្បវេណី" ពីព្រោះច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានធ្វើការកែប្រែ និងលុបចោលមាត្រាមួយចំនួន ដែលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់កិច្ចសន្យាពាណិជ្ជកម្ម។ ជាលទ្ធផល ក្រសួងបានធ្វើការកែសម្រួលមាត្រាមួយចំនួននៃសេចក្តីព្រាងច្បាប់នេះរួចហើយ។

- **ការតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពី "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"**

  សេចក្តីព្រាងច្បាប់ ស្តីពី "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)" ជាច្បាប់ដែលមានលក្ខណៈស្មុគស្មាញ និងលក្ខណៈបច្ចេកទេសច្រើន . ដែលកន្លងមកក្រសួង និងក្រុមការងារ បានធ្វើការយ៉ាងយកចិត្តទុកដាក់ពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់នេះ ដោយបានរៀបចំប្រកាសបង្កើតក្រុមការងារចម្រុះ ដើម្បីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឡើង ដែលមានសមាសភាពមកពី ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងយុត្តិធម៌ និងធនាគារជាតិនៃកម្ពុជា ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ ដែលបានធ្វើការបកប្រែដោយជំនាញការជាតិ។ ជាលទ្ធផលយើងបានបញ្ចប់សេចក្តីព្រាងច្បាប់ទាំងស្រុង និងបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីនាខែមីនា ឆ្នាំ២០១៥ ហើយបានរៀបចំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កាលពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៥។

- **ការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង**

  សេចក្តីព្រាងច្បាប់នេះត្រូវបានតាក់តែងឡើង ដោយក្រសួង និងក្រុមការងារសហការជាមួយជំនាញការអន្តរជាតិក្រោមការឧបត្ថម្ភរបស់ ADB ហើយជាលទ្ធផលទទួលបាន៖

  - ក្រុមការងារតាក់តែងច្បាប់ស្តីពីការប្រកួតប្រជែង បានបញ្ចប់លើខ្លឹមសាររួម និងបន្តពិភាក្សាលើការបង្កើតស្ថាប័នអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ដោយបានពិនិត្យលើគំរូនៃស្ថាប័នអនុវត្តច្បាប់ស្តីពីប្រកួតប្រជែងនេះ នៅតាមបណ្តាប្រទេសអាស៊ាន និងបណ្តាប្រទេសមួយចំនួននៅក្នុងសហភាពអឺរ៉ុបផងដែរ។ ទន្ទឹមនឹងនេះក្រុមការងារក៏កំពុងធ្វើការវាយតម្លៃ លើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តិនៃសេចក្តីព្រាងច្បាប់នេះជាមួយ ECOSSOC
  - ស្រាវជ្រាវលើគោលនយោបាយប្រកួតប្រជែង ដើម្បីធ្វើការសម្រេចក្នុងការដាក់បញ្ចូលធាតុឬគោលនយោបាយសំខាន់ៗ ដែលស្របនឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដូចនៅក្នុងសេចក្តីព្រាងច្បាប់នេះ
  - ធ្វើការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីដែលជាក្រុមការងារ តាមរយៈការបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលជំនាញក្នុងតំបន់ជាច្រើនលើក ដែលបានរៀបចំដោយ (The ASEAN Experts Group on Competition (AEGC)

- ដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់នេះ ជំនាញការអូស្ត្រាលី បានជួយពិនិត្យចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ ហើយក៏បានរៀបចំសិក្ខាសាលាមួយ ស្តីពី "ការអភិវឌ្ឍនៃសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង" នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥។

## ២.៤ ការលើកកម្ពស់វិស័យឯកជន

### ២.៤.១ ការលើកកម្ពស់ផលិតផល

- សហការជាមួយអង្គការ ITC រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសូត្រ និងសិក្ខាសាលា ស្តីពី "ការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន" ក្នុងខែតុលា ឆ្នាំ២០១៥
- រៀបចំសិក្ខាសាលា ស្តីពី "កិច្ចសន្យាផលិតកម្មកសិកម្ម (Contract Farming)" ដើម្បីបង្កើនសមត្ថភាពជូនដល់មន្ត្រីរាជការ អាជីវករ កសិករ និងអ្នកដាំដុះ ពីរបៀបធ្វើកិច្ចសន្យាដាំដុះ
- រៀបចំបង្កើតគណៈកម្មការរៀបចំយុទ្ធសាស្ត្រជំរុញវិស័យសូត្រនៅកម្ពុជា ដោយកែប្រែសមាសភាពថ្មីទៅតាមការចាំបាច់ និងតាមការចាត់តាំងរបស់ស្ថាប័ននានា
- រៀបចំកិច្ចប្រជុំបច្ចេកទេស ស្តីពី "ការអភិវឌ្ឍវិស័យដំឡូងមីនៅកម្ពុជា" ដើម្បីជំរុញការនាំចេញ និងដោះស្រាយបញ្ហាជាឧបសគ្គមួយចំនួនទាក់ទងនឹងផលិតកម្ម និងការនាំចេញ
- ចុះធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពផលិតកម្មសូត្រ នៅតាមមូលដ្ឋានផលិតកម្មសំខាន់ៗ ក្នុងខេត្តចំនួន ៦គឺ ខេត្តតាកែវ កំពត សៀមរាប បន្ទាយមានជ័យ បាត់ដំបង និងកំពង់ចាម
- កំពុងធ្វើបច្ចុប្បន្នភាពឯកសារផលិតផល សក្តានុពលរបស់រាជធានី-ខេត្ត ទាំង ២៥ និង បន្តការសិក្សាស្រាវជ្រាវសង្វាក់តម្លៃផលិតផលអាទិភាព ដោយសហការជាមួយមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ
- រៀបចំរបាយការណ៍ជូនគណៈរដ្ឋមន្ត្រី ស្តីពីការជួយអន្តរាគមន៍រកទីផ្សារលក់ផលិតផលកសិកម្មជូនប្រជាកសិករ។

### ២.៤.២ ការអភិវឌ្ឍស្ថាប័នពាណិជ្ជកម្ម

- បង្កើតសមាគមអាជីវកម្មចំនួន ១៥ រួមមាន៖ សមាគមដំឡូងមី ចំនួន១៣ សមាគមគ្រឿងពេជ្រសាត់ចំនួនមួយ និងសមាគមសូត្រចំនួនមួយ
- ចុះណែនាំពីការចុះឈ្មោះបោះឆ្នោត របៀបរបប និងការចាប់ឆ្នោតជ្រើសរើសលេខរៀងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្ត បានចំនួន ១៣មណ្ឌល និងបានរៀបចំបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម បានចំនួន ១២មណ្ឌល
- ចុះណែនាំ និងពង្រឹងការងារមណ្ឌលសភាពាណិជ្ជកម្ម បានចំនួន ១៣លើក ដើម្បីត្រៀមលក្ខណៈចូលរួមឲ្យមានប្រសិទ្ធភាពទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥នេះ
- រៀបចំកែសម្រួលមាត្រា១០ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពី "របៀបរបប និងការរៀបចំបោះឆ្នោតសភាពាណិជ្ជកម្ម" ដើម្បីផ្តល់សិទ្ធិដល់សហគ្រិនវ័យក្មេង បានចូលរួមក្នុងការបោះឆ្នោតសភាពាណិជ្ជកម្ម
- រៀបចំសេចក្តីជូនដំណឹងដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ស្តីពី "ការប្រមូលទិញកសិផលរបស់ប្រជាកសិករ និងអាជីវករ" នៅតាមបណ្តារាជធានីខេត្ត ដើម្បីជៀសវាងការប្រមូលទិញផ្តាច់មុខដែលធ្វើឲ្យប៉ះពាល់ដល់តម្លៃលក់កសិផលរបស់ប្រជាកសិករ

- រៀបចំវេទិកាពិគ្រោះយោបល់ឯកជន វេទិកាវិស័យឯកជនតាមបណ្តាខេត្ត សៀមរាប បាត់ដំបង និងខេត្តព្រះសីហនុ ដើម្បីផ្សព្វផ្សាយពីកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងពាណិជ្ជកម្ម និងសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន។

### ២.៤.៣ ការងារពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម

- តាមដានការវិវត្តថ្លៃប្រេងឥន្ធនៈនៅលើទីផ្សាររាជធានី-ខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយជាទូទៅ សំដៅបម្រើផលប្រយោជន៍សាធារណជន និងរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី "ថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍" រវាងក្រសួងពាណិជ្ជកម្មជាមួយក្រសួងពាក់ព័ន្ធ និងក្រុមហ៊ុននាំចូលប្រេងឥន្ធនៈដូចជា៖ ក្រុមហ៊ុនសូគីមិច ក្រុមហ៊ុនកម្ពុជាតេលា ក្រុមហ៊ុន PTT (Cambodia) Ltd ក្រុមហ៊ុន Chevron (Cambodia) Ltd ក្រុមហ៊ុន Bright Victory Mekong Petroleum ក្រុមហ៊ុន TOTAL Cambodge និងក្រុមហ៊ុន Savimex សរុបបានចំនួន ១១លើក ដើម្បីរក្សាថ្លៃលក់រាយឲ្យសមស្របតាមថ្លៃទីផ្សារអន្តរជាតិ
- បន្តរៀបចំកែសម្រួលឡើងវិញនូវលិខិតបទដ្ឋាននានា ដើម្បីសម្របតាមការងារជាក់ស្តែងរបស់នាយកដ្ឋានឲ្យកាន់តែមានភាពសុក្រឹតថែមទៀតដូចជា៖
    - រៀបចំឡើងវិញនូវប្រកាស ស្តីពី "ការប្រកាសសន្និធិ ប្រេងឥន្ធនៈ និងហ្គាស"
    - រៀបចំឡើងវិញនូវសេចក្តីណែនាំ ស្តីពី "ការអនុវត្តខ្លឹមសារ ប្រកាសលេខ០៤៥ពណ.ប្រក ចុះថ្ងៃទី៣១ខែមករា ឆ្នាំ២០១៥ ស្តីពីការធ្វើប្រតិភូកម្ម ការងារគ្រប់គ្រងសកម្មភាពអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ" ជូនមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- ចុះត្រួតពិនិត្យ និងវាយតម្លៃជាក់ស្តែងអំពីបរិមាណសន្និធិប្រេងឥន្ធនៈនិងហ្គាស ចំនួន ៧ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតឲ្យបិទស្លាកថ្លៃលើមុខទំនិញ និងសេវាបានចំនួន ១៨៦លិខិត
- ចងក្រងប្រមូលព័ត៌មាន និងរៀបចំរបាយការណ៍ប្រចាំថ្ងៃអំពីថ្លៃទំនិញចាំបាច់ ថ្លៃប្រេងឥន្ធនៈ និងស្តុកស្រូវ-អង្ករតាមបណ្តារាជធានី-ខេត្ត
- តាមដាន និងបូកសរុបរបាយការណ៍ នៃការអនុវត្តចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មពាណិជ្ជកម្ម និងសេវាកម្ម និងលិខិតអនុញ្ញាតធ្វើអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការរបស់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងការិយាល័យច្រកចេញចូលតែមួយ ដើម្បីធានាប្រសិទ្ធភាពនៃការធ្វើប្រតិភូកម្មពីថ្នាក់កណ្តាលទៅថ្នាក់ខេត្ត។

## ២.៥ ការចងក្រង និងផ្តល់ព័ត៌មានពាណិជ្ជកម្ម

- ការងារបូកសរុបព័ត៌មាន
    - រៀបចំឯកសាររបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស ៩ខែទៀងទាត់ជូនថ្នាក់ដឹកនាំក្រសួង និងផ្ញើជូនអគ្គលេខាធិការរាជរដ្ឋាភិបាលរៀងរាល់ប្រជុំសប្តាហ៍នៅទីស្តីការគណៈរដ្ឋមន្ត្រី
    - រៀបចំ និងបញ្ជូនរបាយការណ៍ ស្តីពីស្ថានភាពថ្លៃទំនិញនៅលើទីផ្សារក្នុងប្រទេស និងទីផ្សារអន្តរជាតិសំខាន់ៗ ប្រចាំសប្តាហ៍ ផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រីជាប្រចាំ
    - បូកសរុបរបាយការណ៍ស្ថិតិពាណិជ្ជកម្មរបស់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងបណ្តានាយកដ្ឋាននានាបានចំនួន ៣៥២ច្បាប់ ដើម្បីស្រង់ព័ត៌មានសំខាន់ៗ សម្រាប់ជាទិន្នន័យក្នុងការកសាងផែនការពាណិជ្ជកម្ម

- សហការពិភាក្សាការងារបច្ចេកទេស ក្នុងការរៀបចំបែបបទ ប្រមូលស្ថិតិពាណិជ្ជកម្មនាំចេញ-នាំចូលទំនិញកម្ពុជា ជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងផែនការ និងអង្គការអន្តរជាតិ
- សហការផ្តល់មតិយោបល់ចំពោះ ការវាយតម្លៃខ្សែសង្វាក់តម្លៃផលផលសមុទ្រ ជាមួយអង្គការ UNIDO
- ចូលរួមសហការក្នុងព្រឹត្តិការណ៍ពិព័រណ៍ព័ត៌មានវិទ្យា និងការងារស្ថិតិថ្នាក់តំបន់ប្រចាំឆ្នាំ២០១៥ នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ផងដែរ
- រៀបចំគម្រោងស្តីពី "មជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មកម្ពុជា Cambodia Trade Centre" ដើម្បីស្នើសុំជំនួយសម្រាប់អនុវត្តគម្រោងពីសហគមន៍អឺរ៉ុប
- រៀបចំ និងសហការកសាងផែនការសកម្មភាពពាណិជ្ជកម្មឆ្នាំ២០១៦ ដើម្បីឈានទៅចល់គោលដៅនៃការអនុវត្តផែនការថវិកាកម្មវិធី
- ត្រួតពិនិត្យ និងរៀបចំយន្តការការងារ ដើម្បីអាចវាយតម្លៃការអនុវត្ត ផែនការយុទ្ធសាស្ត្រថវិកា ធៀបទៅនឹងផែនការសកម្មភាពការងារពាណិជ្ជកម្មឆ្នាំ២០១៦
- រៀបចំ និងលើកគម្រោងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជំនាញផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ និងធ្វើការវិភាគមុខងាររបស់មន្ត្រីគ្រប់រូបនៅក្នុងនាយកដ្ឋាន។

- **ការងារបោះពុម្ព និងផ្សព្វផ្សាយឯកសារស្ថិតិព័ត៌មានពាណិជ្ជកម្ម**
    - បោះពុម្ពព្រឹត្តិបត្រពាណិជ្ជកម្មរៀងរាល់ពីរសប្តាហ៍ម្តងជាប្រចាំបានចំនួន ៧.២០០ក្បាល
    - បោះពុម្ពសៀវភៅស្ថិតិនាំចេញ-នាំចូលប្រចាំឆ្នាំចំនួន ៨០០ក្បាល
    - បោះពុម្ពសៀវភៅស្ថិតិក្រុមហ៊ុនចុះបញ្ជីក្រុមហ៊ុនប្រចាំឆ្នាំបានចំនួន ១០០ក្បាល

- **ការងារព័ត៌មានវិទ្យា (IT)**

***គេហទំព័រ (Website):***

ដាក់បញ្ចូលទិន្នន័យសំខាន់ៗមួយចំនួនទៅក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្មដូចជា៖

- សកម្មភាពរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មចំនួន ៣២៤លើក
- ស្ថិតិផលិតផលនាំចេញពីប្រទេសកម្ពុជាទៅកាន់ទីផ្សារក្នុងតំបន់ និងពិភពលោក
- ព័ត៌មានតម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ និងព័ត៌មានសេដ្ឋកិច្ចពិភពលោក
- តម្លៃមាស និងអត្រាប្តូរប្រាក់នៅលើទីផ្សារអន្តរជាតិ
- តម្លៃទំនិញកសិផល ផលិតផលនេសាទ ផលិតផលឧស្សាហកម្ម រ៉ែនិងលោហធាតុមួយចំនួន
- ព័ត៌មានអំពីការវិវត្តថ្លៃលក់ជុំសំខាន់ៗ តាមបណ្តាខេត្ត និងសន្ទស្សន៍ថ្លៃទំនិញចាំបាច់នៅទីផ្សារភ្នំពេញប្រចាំសប្តាហ៍ និងតម្លៃប្រេងឥន្ធនៈនៅតាមបណ្តាស្ថានីយ៍នៅរាជធានីភ្នំពេញ
- តម្លៃទំនិញសំខាន់ៗ លើទីផ្សារអន្តរជាតិ ប្រចាំសប្តាហ៍
- សេចក្តីប្រកាសជាភាសាខ្មែរ និងអង់គ្លេស ស្តីពីការបង្កើតក្រុមហ៊ុនការិយាល័យតំណាងសាខាក្រុមហ៊ុនក្នុងស្រុក កែប្រែលក្ខន្តិកៈ ការរំលាយក្រុមហ៊ុនមានចំនួនសរុប ៣.០៩០ក្រុមហ៊ុន
- ស្ថិតិក្រុមហ៊ុនសហគ្រាសឯកបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មមានចំនួន ២.៨៥៣ក្រុមហ៊ុន
- ស្ថិតិប្រចាំខែការចុះបញ្ជីម៉ាកក្នុងប្រទេស និងក្រៅប្រទេសចំនួន ៣.៦៨៦ម៉ាក

- ស្ថិតិប្រចាំខែការនាំចេញសម្លៀកបំពាក់និងស្បែកជើងរបស់រោងចក្រក្រៅតំបន់សេដ្ឋកិច្ចពិសេស
- របាយការណ៍ប្រចាំខែរបស់តំបន់សេដ្ឋកិច្ចពិសេសទូទាំងប្រទេស
- ច្បាប់ ព្រះរាជក្រម អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងសេចក្តីជូនដំណឹងចំនួន ២៦ច្បាប់។

*<u>ម៉ាស៊ីនផ្ទុកទិន្នន័យ (Server):</u>*

- គ្រប់គ្រងប្រព័ន្ធចែកចាយទិន្នន័យ ដែលតភ្ជាប់ទៅប្រព័ន្ធ C/O online និងបែងចែកឲ្យប្រើប្រាស់ទៅដល់ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់
- គ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត (Internet) ដើម្បីធានាឲ្យមាន WIFI ប្រើប្រាស់គ្រប់ទីកន្លែង នៅក្នុងបរិវេណទីស្តីការក្រសួង
- គ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ (Data Center) ដែលមានចំនួន ១៤ Servers ប្រើប្រាស់ជាមជ្ឈមណ្ឌលព័ត៌មានរួមរបស់ក្រសួង។

- ការងារផែនការពាណិជ្ជកម្ម

  *<u>ការកសាងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្ម៖</u>*

  - ចងក្រងធាតុចូលសម្រាប់ការកសាង "ផែនការយុទ្ធសាស្ត្រពាណិជ្ជកម្ម ឆ្នាំ២០១៥-២០២៣"
  - រៀបចំសេចក្តីព្រាងមាតិកា "ផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មឆ្នាំ២០១៥-២០២៣"
  - រៀបចំយន្តការប្រមូល និងវិភាគព័ត៌មានពាណិជ្ជកម្មសម្រាប់ចងក្រងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្ម។

*<u>តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការរួមវិស័យពាណិជ្ជកម្ម៖</u>*

- តាមដានទូវព័ត៌មានពាណិជ្ជកម្ម និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្មជាប្រចាំ
- សម្របសម្រួល និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងស្ថិតិផ្លូវការដែលបានចាត់តាំងរបស់ក្រសួងពាណិជ្ជកម្មទៅកាន់ក្រុមការងារ PARIS 21 ដែលមានគម្រោងអភិវឌ្ឍន៍លើផ្នែកស្ថិតិ
- ត្រួតពិនិត្យ និងសិក្សាពីយន្តការការងារ ដើម្បីអាចវាយតម្លៃការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការរួមរបស់វិស័យពាណិជ្ជកម្មឲ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ។

*<u>ការងារសហការជាមួយអង្គភាពពាក់ព័ន្ធ៖</u>*

- បានរៀបចំ "គំរូតារាងស្ថិតិ" ដែលទាញព័ត៌មានពីប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O Online) សម្រាប់ធ្វើជារបាយការណ៍ពាក់ព័ន្ធនឹងស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម
- សម្របសម្រួលការរៀបចំ "កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១៦-២០១៨" និង "ម៉េតាទិន្នន័យសម្រាប់ឆ្នាំ២០១៥" របស់ក្រសួងពាណិជ្ជកម្មដើម្បីផ្តល់ឲ្យក្រសួងផែនការបូកសរុបទិន្នន័យរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលការរៀបចំ "របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨" ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម

- សម្របសម្រួលផ្តល់ធាតុចូល របស់ក្រសួងពាណិជ្ជកម្មនៅក្នុង "គោលនយោបាយជាតិប្រជាជនកម្ពុជា" ដើម្បីផ្តល់ទៅឲ្យវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។

## ២.៦ ការចារសមាហរណកម្មសេដ្ឋកិច្ចតំបន់ អនុតំបន់ និងដៃគូ

### ២.៦.១ អាស៊ាន-ចិន

- ចូលរួមកិច្ចប្រជុំក្រុមការងារស្តីពីវិធានប្រភពដើមទំនិញអាស៊ាន-ចិន ពីថ្ងៃទី១៧-២០ ខែមីនា ឆ្នាំ២០១៥ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ កិច្ចប្រជុំបានពិនិត្យឡើងវិញនូវវិធានផលិតផលដោយឡែក និងឯកភាពលើបញ្ជីផលិតផលដោយឡែកនៅក្នុងជំពូកចំនួន ១៤។ សមាជិកអាស៊ាន ៧ និងកម្ពុជាបានឯកភាពលើជំពូកពី១-១៤ ជាមួយភាគីចិន និងរង់ចាំការបញ្ជាក់ពីប្រទេសហ្វីលីពីន និងមីយ៉ាន់ម៉ា។ បន្ទាត់ពន្ធតយមួយចំនួនទៀត នឹងបន្តពិភាក្សាបន្ថែម។ ជាគោលការណ៍ អាស៊ាន និងចិនបានឯកភាពរួមគ្នា ធ្វើឲ្យកាន់តែប្រសើរឡើងនូវវិធានប្រភពដើមទំនិញថ្មីនេះ ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន
- រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះ ស្តីពី "តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA)" លើកទី៧ និងកិច្ចប្រជុំពាក់ព័ន្ធ និងដឹកនាំចូលរួមកិច្ចប្រជុំក្រុមការងារសេវាអាស៊ាន-ចិន នៅទីក្រុងប៉េកាំង ប្រទេសចិន ពីថ្ងៃទី៤-៦ ខែកុម្ភៈ ឆ្នាំ២០១៥ ។ កិច្ចប្រជុំបានពិភាក្សាអំពីការបង្កើនកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA Upgrading) ពិសេសលើវិស័យសំខាន់ៗ បួនៈ ពាណិជ្ជកម្មទំនិញ, ពាណិជ្ជកម្មសេវា, វិនិយោគ, និងសហប្រតិបត្តិការសេដ្ឋកិច្ច-បច្ចេកទេស។ កិច្ចប្រជុំបានឯកភាពថា ការធ្វើសេរីភាវូបនីយកម្មសេវា ត្រូវផ្អែកលើគោលការណ៍ទទួលបានផលប្រយោជន៍ទៅវិញទៅមក និងបានឯកភាពពិភាក្សាកញ្ចប់សន្យាទី៣ នៅក្រោមការបង្កើនកម្រិត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-ចិន ដោយផ្អែកលើវិធីសាស្ត្របញ្ជីវិជ្ជមាន ហើយប្រទេសសមាជិកអាស៊ាននីមួយៗ នឹងត្រូវមានតារាងសន្យារៀងៗខ្លួន។ កិច្ចប្រជុំបានឯកភាពលើផែនទីវិធីសម្រាប់ចរចាបង្កើនកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-ចិន
- ចូលរួមកិច្ចប្រជុំលើកទី៩ នៃគណៈកម្មាធិការចម្រុះពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA-JC) ដែលបានធ្វើពីថ្ងៃទី២៦-៣០ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងប៉េកាំង ប្រទេសចិន។ កិច្ចប្រជុំបានពិភាក្សាលើសេចក្តីព្រាងអត្ថបទពិធីសារ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពី "កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតរវាងអាស៊ាន និងចិន" កិច្ចប្រជុំបានឯកភាពគ្នា ឲ្យភាគីចរចាទាំងអស់ពន្លឿននីតិវិធីក្នុងស្រុក សម្រាប់ការអនុម័តលើពិធីសារ ដើម្បីចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលអាស៊ាន-ចិននៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ ក្នុងកិច្ចប្រជុំក្រុមការងារពាណិជ្ជកម្មសេវា សមាជិកអាស៊ាន៩ និងចិនបានផ្តល់ជូនកញ្ចប់សន្យាទី៣ រួចហើយ លើកលែងតែប្រទេសហ្វីលីពីន។ សមាជិកអាស៊ានទាំងអស់បានទទួលយកការផ្តល់ជូនកញ្ចប់សន្យាទី៣ របស់ចិនដែលបានកែតម្រូវនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ជាកញ្ចប់សន្យាទី៣ ចុងក្រោយនឹងគ្មានការផ្លាស់ប្តូរ ហើយសមាជិកអាស៊ានទាំង៩ នឹងត្រូវផ្តល់ជូនកញ្ចប់សន្យាទី ៣ របស់ខ្លួន យ៉ាងយូរត្រឹមថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥។ ក្រសួងបានរៀបចំឯកសារស្នើសុំសិទ្ធិប្រធានពីរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ចុះហត្ថលេខាលើពិធីសារខាងលើ
- ចូលរួមកិច្ចប្រជុំលើកទី២៦ ក្រុមការងារពាណិជ្ជកម្មសេវាក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន នៅទីក្រុងបាងកក ពីថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ២០១៥។ កិច្ចប្រជុំបានផ្តល់នូវបញ្ជី

សំណើទៅវិញទៅមកសម្រាប់ផ្តល់ការសន្យាក្នុងកញ្ចប់សន្យាទី៣ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-ចិន។ កិច្ចប្រជុំក៏បានចាប់ផ្តើមពិភាក្សារៀបចំសេចក្តីព្រាងពិធីសារ ដើម្បីអនុវត្តកញ្ចប់សន្យាទី៣ ផងដែរ។

### ២.៦.២ អាស៊ាន-កូរ៉េ

- សម្របសម្រួល រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការអនុវត្តន៍កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA) លើកទី១១ និងកិច្ចប្រជុំពាក់ព័ន្ធនៅខេត្តភូកេត ប្រទេសថៃឡង់ដ៍ ពីថ្ងៃទី២៦-២៩ ខែមករា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សាលើការងារដែលបានដាក់ចុះដោយរដ្ឋមន្ត្រីសេដ្ឋកិច្ច និងប្រមុខរដ្ឋាភិបាលអាស៊ាន-កូរ៉េ និងបានឯកភាពលើការកំណត់ពេលធ្វើការកាត់បន្ថយពន្ធនាំចូលមួយបន្ទាត់ម្តងៗ និងការចាប់ផ្តើមរៀបចំពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងទំនិញអាស៊ាន-កូរ៉េ
- សម្របសម្រួល រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការអនុវត្តន៍កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA) លើកទី១២ និងកិច្ចប្រជុំពាក់ព័ន្ធនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ពីថ្ងៃទី១៣-១៤ ខែឧសភា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សាពីការបង្កើនកម្រិតកិច្ចព្រមព្រៀតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ រួមមានៈ កម្មវិធីកាត់បន្ថយពន្ធគយមួយបន្ទាត់ម្តងៗ ទំនិញក្នុងបញ្ជីលើកលែង និងបញ្ជីហាមឃាត់ ពិភាក្សាការធ្វើសេរីភាវូបនីយកម្មបន្ថែមលើទំនិញរសើប និងរសើបខ្ពស់ពី១-២% នៃបន្ទាត់ពន្ធគយ។ កិច្ចប្រជុំបានឯកភាពកែសម្រួលលើការកំណត់ពេលសម្រាប់ ធ្វើបញ្ចប់តារាងបញ្ចុះពន្ធគយមួយបន្ទាត់ម្តងៗ នៅចុងខែមិថុនា ឆ្នាំ២០១៥ និងបានស្នើឲ្យភាគីទាំងអស់ខិតខំបញ្ចប់នីតិវិធីផ្ទៃក្នុង ដើម្បីអាចឲ្យរដ្ឋមន្ត្រីចុះហត្ថលេខាលើពិធីសារនេះបាន នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-កូរ៉េ នៅក្នុងខែសីហា ឆ្នាំ២០១៥ ។ កិច្ចប្រជុំបានឯកភាពលើពិធីសារទី៣ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងទំនិញអាស៊ាន-កូរ៉េ
- ចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការវិធានប្រភពដើមទំនិញអាស៊ាន-កូរ៉េលើកទី ២១ ពីថ្ងៃទី ១២-១៤ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ។ កិច្ចប្រជុំបានពិភាក្សាចំណុចប្រឈមមួយចំនួនទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ និងវិធានប្រភពដើមទំនិញនៅក្រោមកិច្ចព្រមពៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ។ កិច្ចប្រជុំបានឯកភាពក្នុងការប្រើប្រាស់វិធានផលិតផលដោយឡែកតាមប្រព័ន្ធសុខដុមឆ្នាំ២០១២ ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៥ តទៅ។

### ២.៦.៣ អាស៊ាន-ជប៉ុន

- សម្របសម្រួល រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំលើកទី១៣ នៃគណៈកម្មាធិការចម្រុះ ស្តីពី "ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន (AJCEP) និងកិច្ចប្រជុំពាក់ព័ន្ធ" នៅទីក្រុងយ៉ូកយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី៨-១០ ខែមេសា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សាលើការផ្ទេរអត្រាពន្ធនាំចូលពីប្រព័ន្ធសុខដុមឆ្នាំ២០០២ មក ២០០៧ និងពី ២០០៧ ទៅ ២០១២ ពិភាក្សាអំពីគោលការណ៍សម្រាប់កាត់បន្ថយពន្ធនាំចូល និងបន្តការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងកិច្ចព្រមព្រៀងវិនិយោគ នៅក្រោមកិច្ចព្រមព្រៀង AJCEP។ កិច្ចប្រជុំបានឯកភាពបញ្ចប់ការចរចាជាជុំកំភួន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងបានចាប់ផ្តើមពិភាក្សាពិនិត្យលើវិជ្ជភាពច្បាប់។ ចំពោះកិច្ចព្រមព្រៀងវិនិយោគ កិច្ចប្រជុំបានឯកភាពខិតខំការចរចាបន្ថែមទៀត

- ដឹកនាំប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំក្រុមការងារពាណិជ្ជកម្មសេវា នៃគណៈកម្មាធិការចរចាពាណិជ្ជកម្ម ស្តីពី "ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់លើកទី១០" ពីថ្ងៃទី១០-១៧ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ។ កិច្ចប្រជុំបានបន្តពិភាក្សាលើការផ្ទេរអត្រាពន្ធនាំចូលពីប្រព័ន្ធសុខដុមឆ្នាំ២០០២ មក ២០០៧ និងពី ២០០៧ ទៅ ២០១២។ កិច្ចប្រជុំបានឯកភាពឲ្យប្រទេសជាសមាជិកខិតខំធ្វើការជាមួយភាគីជប៉ុន ដើម្បីបញ្ចប់ការងារបច្ចេកទេស នៃការផ្ទេរនេះតាមគោលការណ៍ណែនាំដែលបានអនុម័ត ឲ្យបានទាន់ពេលវេលា ដើម្បីចូលរួមអនុវត្តប្រព័ន្ធសុខដុមនេះ។ ប្រទេសកម្ពុជាកំពុងរៀបចំបញ្ចប់ការផ្ទេរអត្រាពន្ធនាំចូល នៅសេសសល់ចំនួន ៣៥ បន្ទាត់ពន្ធគយពីប្រព័ន្ធសុខដុមឆ្នាំ២០០២ មក ២០០៧ និងបំរុង បញ្ជូននៅពេលឆាប់ៗ ខាងមុខទៅភាគីជប៉ុនដើម្បីពិនិត្យនិងផ្តល់យោបល់។ កិច្ចប្រជុំបានពិភាក្សាលើ សេចក្តីព្រាងពិធីសារដើម្បីដាក់បញ្ចូលជំពូក ស្តីពីពាណិជ្ជកម្មសេវា និងជំពូកស្តីពីវិនិយោគទៅក្នុងកិច្ច ព្រមព្រៀង AJCEP។ ភាគីទាំងពីរនៅមិនទាន់ឯកភាព ថាតើត្រូវដាក់ពាណិជ្ជកម្មសេវា ដែលបានចរចាចប់រួចរាល់នៅដាច់ដោយឡែកជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា ឬរង់ចាំការចរចាបញ្ចប់ជំពូកស្តីពីវិនិយោគ ដើម្បីដាក់ជាកញ្ចប់នៅក្នុងពិធីសារតែមួយនៅឡើយ។ ភាគីទាំងពីរឯកភាពនឹងបន្តពិភាក្សាបន្ថែមទៀត។

### ២.៦.៤ អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

- រៀបចំឯកសារ និងចូលរួមកិច្ច ប្រជុំគណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់លើកទី៦ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការ ស្តីពីពាណិជ្ជកម្មសេវាអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ (AANZFTA) នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ីពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៣ កក្កដា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សាការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន AANZFTA ជាពិសេស ជំរុញការផ្លាស់ប្តូរបែបបទក្នុងស្រុក ដើម្បីចូលជាធរមានពិធីសារទី១ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀង AANZFTA នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥។ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ ក្រសួងពាណិជ្ជកម្ម បានចុះហត្ថលេខា និងបញ្ជូនលិខិតជូនរាជរដ្ឋាភិបាល ដើម្បីសុំចូលជាធរមាននៃពិធីសារនេះ។ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានឯកភាពការចូលជាធរមាននៃពិធីសារទី១ ដើម្បីធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងអាស៊ានអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ដោយសារកិច្ចព្រមព្រៀង AANZFTA ត្រូវបានសភាជាតិផ្តល់សច្ចាប័នរួចមកហើយ ហើយការធ្វើវិសោធនកម្មនេះ មិនមានប្រែប្រួលខ្លឹមសារសំខាន់ៗ នៃកិច្ចព្រមព្រៀងនេះឡើយ។

### ២.៦.៥ អាស៊ាន-ហុងកុង

- សម្របសម្រួលរៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្មស្តីពី "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង (AHKFTA) លើកទី៣ និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធនៅទីក្រុងហុងកុង ពីថ្ងៃទី១០-១២ ខែមីនា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សាលើនីតិវិធីនៃការកាត់បន្ថយពន្ធនាំចូល សម្រាប់សមាជិកអាស៊ានចាស់៦ សម្រាប់វៀតណាម និងសម្រាប់កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង។ កិច្ចប្រជុំបានឯកភាពលើអត្ថបទស្តីពីឧបាស្រ័យពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញា

(តាម WTO) សម្រាប់បញ្ចូលក្នុងកិច្ចព្រមព្រៀងនេះ។ កិច្ចប្រជុំបានឯកភាពលើគ្រោងផ្លូវសម្រាប់ការពិភាក្សាពាណិជ្ជកម្មសេវា នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង

- សម្របសម្រួលរៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្មស្តីពី "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងលើកទី៤ និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធ" នៅទីក្រុងសិង្ហបុរី ពីថ្ងៃទី២០-២៣ ខែកក្កដា ឆ្នាំ២០១៥។ កិច្ចប្រជុំបានបន្តចរចា និងឯកភាពលើជំពូក និងមាត្រាមួយចំនួននៅក្នុងពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវា វិនិយោគ ប្រភពដើមទំនិញ នីតិវិធីគយ និងសម្រួលពាណិជ្ជកម្មស្តង់ដារ បទបញ្ញត្តិបច្ចេកទេស និងភាពអនុលោមអនាម័យនិងភូតគាមអនាម័យ ច្បាប់និងស្ថាប័ន និងសហប្រតិបត្តិការសេដ្ឋកិច្ច-បច្ចេកទេស។ កិច្ចប្រជុំបានឯកភាពឲ្យប្រទេសឥណ្ឌូនេស៊ី ឆ្លើយតបជាផ្លូវការចំពោះកម្មវិធីកាត់បន្ថយពន្ធនាំចូលទំនិញ និងស្នើឲ្យប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បញ្ចប់ការពិភាក្សា និងសម្របសម្រួលដាក់ជូននូវការសន្យាកាត់បន្ថយពន្ធនាំចូលរួមនៅក្រោម AHKFTA នៅមុនកិច្ចប្រជុំលើកទី៥។ កិច្ចប្រជុំបានស្នើប្រទេសកម្ពុជាឲ្យទទួល វេនធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្ម ស្តីពី "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងលើកទី៦" ក្រុងសៀមរាប នៅដើមខែមីនាឆ្នាំ២០១៦។

### ២.៦.៦ ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP)

- រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំផ្ទៃក្នុងក្រុមការងារអាស៊ាន ស្តីពី "ពាណិជ្ជកម្មសេវាសម្រាប់ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP)" នៅថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ កិច្ចប្រជុំបានឯកភាពឲ្យក្រុមការងារពាណិជ្ជកម្មសេវានៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ ប្តូរពីការចរចាតាមវិធីសាស្ត្របញ្ជីអវិជ្ជមាន និងបញ្ជីកូនកាត់មកវិធីសាស្ត្របញ្ជីវិជ្ជមានតាមទម្លាប់អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកវិញ ដើម្បីជំរុញការចរចាទៅមុខ
- រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំប្រធាន+១ នៃគណៈកម្មាធិការចរចាពាណិជ្ជកម្ម ស្តីពី "ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់" នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី១-២ ខែ មេសា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សាឯកសារគោល សម្រាប់ផ្តល់ការសន្យាលើវិស័យពាណិជ្ជកម្មទំនិញ ឯកសារស្តីពីធាតុផ្សំដែលមានតម្លៃបន្ថែមសម្រាប់ការចរចាពាណិជ្ជកម្មសេវា និងវិនិយោគ។ កិច្ចប្រជុំបានឯកភាពណែនាំឲ្យ មន្ត្រីរបស់ប្រទេសចូលរួមនីមួយៗ ខិតខំពិភាក្សាឲ្យបានចេញជាលទ្ធផលលើវិស័យចម្បងទាំងបីខាងលើ ដើម្បីពន្លឿនការចរចាឆ្ពោះទៅសម្រេចបានតាមគោលដៅ
- រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំផ្ទៃក្នុងអាស៊ានពីពាណិជ្ជកម្មសេវានៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សារកវិធីដើម្បីពន្លឿននៃការចរចារពាណិជ្ជកម្មសេវានៅក្រោមកិច្ចព្រមព្រៀង RCEP ជាពិសេសលើធាតុផ្សំដែលមានតម្លៃបន្ថែមដែលភាគីដៃគូពាណិជ្ជកម្មសេរីអាស៊ានបានទទួលសំណើចំនួនបី៖ បញ្ជីតម្លាភាពចងជាផ្លូវច្បាប់ (Non-Binding Transparency List), ការផ្តល់ឲ្យជាស្វ័យប្រវត្តិនូវឋានៈជាជាតិអនុគ្រោះបំផុត (Automatic MFN), និងការផ្តល់ការសន្យាមិនអាចដកថយបាន (Ratchet)។ កិច្ចប្រជុំបានឯកភាពទទួលយកសំណើទាំងនេះ មកពិភាក្សាជាមួយភាគីដៃគូពាណិជ្ជកម្មសេរីអាស៊ាននៅកិច្ចប្រជុំបន្តបន្ទាប់ទៀត
- រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំលើកទី៧ នៃគណៈកម្មាធិការចរចាពាណិជ្ជកម្ម RCEP និងកិច្ចប្រជុំពាក់ព័ន្ធ និងបានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំក្រុមការងារពាណិជ្ជកម្មសេវា នៅ

ក្រោម RCEP នៅទីក្រុងក្យូតូ ប្រទេសជប៉ុន ពីថ្ងៃទី៥-១៣ ខែមិថុនាឆ្នាំ២០១៥។ កិច្ចប្រជុំបានចរចាលើការផ្តល់ការសន្យាបឋមផ្នែកពាណិជ្ជកម្មទំនិញ និងបន្តការចរចាពាណិជ្ជកម្មសេវាវិនិយោគ វិធានប្រភពដើមទំនិញ អនាម័យ-ភូតគាមអនាម័យ ស្តង់ដារនិងអនុលោមភាព នីតិវិធីគយនិងសម្រួលពាណិជ្ជកម្ម ច្បាប់និងស្ថាប័ន កម្មសិទ្ធិបញ្ញា គោលនយោបាយប្រកួតប្រជែង ឧបាស្រ័យពាណិជ្ជកម្ម ពាណិជ្ជកម្មតាមអេឡិចត្រូនិច និងសហប្រតិបត្តិការសេដ្ឋកិច្ច-បច្ចេកទេស។ កិច្ចប្រជុំបានឯកភាពជំរុញឲ្យក្រុមការងារពាក់ព័ន្ធ ខិតខំពិភាក្សាបន្ថែមទៀត ដើម្បីសម្រេចតាមទិសដៅដែលបានដាក់ចុះដោយប្រមុខរដ្ឋាភិបាលឲ្យបញ្ចប់កិច្ចព្រមព្រៀង RCEP នៅចុងឆ្នាំ២០១៥

- ចូលរួមវេទិកាសមាហរណកម្មពាណិជ្ជកម្មសេវាតំបន់នៅក្នុងប្រទេសអាស៊ាន: វឌ្ឍនភាព និងការប្រឈម នៅលេខាធិការដ្ឋានអាស៊ាន ទីក្រុងហ្សាកាតា ពីថ្ងៃទី១៨-១៩ ខែមិថុនា ឆ្នាំ២០១៥។ វេទិកាបានពិភាក្សាវិះគន់វិធីសាស្ត្រ បង្កើនសេរីភាវូបនីយកម្មបន្ថែមសម្រាប់តំបន់អាស៊ាន និងជាមួយដៃគូអាស៊ាន នៅក្នុងបរិបទថ្មីនៃពាណិជ្ជកម្មសេវាពិភពលោក ជាពិសេសបានពិចារណារកពិធីសាស្ត្រល្អៗ នៅក្នុងការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន និងការចរចាបន្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវានៅក្រោម RCEP
- រៀបចំឯកសារ ជំនួយស្មារតី និងចូលរួមកិច្ចប្រជុំត្រៀមគណៈកម្មាធិការចរចាពាណិជ្ជកម្ម RCEP និងអន្តរកិច្ចប្រជុំរដ្ឋមន្ត្រីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ នៅទីក្រុងកូឡាឡាំពួរ ពីថ្ងៃទី៨-១៣ ខែកក្កដា ឆ្នាំ២០១៥។ អន្តរកិច្ចប្រជុំរដ្ឋមន្ត្រី RCEP បានពិភាក្សាលើបញ្ហាលំបាកនៅក្នុងវិស័យសំខាន់ៗ ចំនួន ៣៖ ពាណិជ្ជកម្មទំនិញ, ពាណិជ្ជកម្មសេវា, និងវិនិយោគ។ រដ្ឋមន្ត្រីបានណែនាំលើបញ្ហាទាំងនេះ ដើម្បីឲ្យការចរចាមានដំណើរការទៅមុខ នៅឯកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្ម RCEP លើកទី៩ នៅខែសីហា ឆ្នាំ២០១៥ នៅទីក្រុងណៃពិដោរ ប្រទេសមីយ៉ាន់ម៉ា។ រដ្ឋមន្ត្រីបានឯកភាពបង្កើតអនុក្រុមការងារសេវាហិរញ្ញវត្ថុ និងអនុក្រុមការងារសេវាទូរគមនាគមន៍ នៅក្រោមក្រុមការងារពាណិជ្ជកម្មសេវា និងក្រុមជំនាញពាណិជ្ជកម្មតាមអេឡិចត្រូនិច RCEP។ រដ្ឋមន្ត្រីបានសន្យាជំរុញមន្ត្រីរបស់ខ្លួនខិតខំចរចា RCEP ឲ្យបានសម្រេចតាមទិសដៅនៅចុងឆ្នាំ២០១៥ ដោយទទួលស្គាល់កម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចផ្សេងៗ គ្នានៃភាគីនីមួយៗ នៅក្នុង RCEP
- រៀបចំលទ្ធផលនៃអន្តរកិច្ចប្រជុំរដ្ឋមន្ត្រី នៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) ជូន **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំឯកសារ និងចូលរួមកិច្ចប្រជុំលើកទី៨ គណៈកម្មាធិការចរចាពាណិជ្ជកម្ម ស្តីពី "ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ និងកិច្ចប្រជុំពាក់ព័ន្ធ" និងដឹកនាំចូលរួមកិច្ចប្រជុំក្រុមការងារស្តីពីពាណិជ្ជកម្មសេវានៅក្រោម RCEP នៅទីក្រុងណៃពិដោរ ប្រទេសមីយ៉ាន់ម៉ា ពីថ្ងៃទី១-៧ ខែមិថុនាឆ្នាំ២០១៥។ កិច្ចប្រជុំបានបន្តពិភាក្សា និងចរចាដោយភាពជឿនលឿនទៅមុខខ្លះៗ លើពាណិជ្ជកម្មទំនិញ និងពាណិជ្ជកម្មសេវា និងវិនិយោគ។ ចំពោះពាណិជ្ជកម្មសេវា ដោយភាពលំបាកលើកឡើងដោយគណៈប្រតិភូនៃប្រទេសក្រីក្រ (LDCs) កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា កិច្ចប្រជុំបានឯកភាពផ្តល់នូវភាពទន់ភ្លន់ចំពោះធាតុផ្សំដែលមានតម្លៃបន្ថែមទាំង៣ ស្នើឡើងដោយប្រទេសជប៉ុន កូរ៉េ អូស្ត្រាលី និងណូវែលហ្សេឡង់
- ដឹកនាំប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំក្រុមការងារពាណិជ្ជកម្មសេវា នៃគណៈកម្មាធិការចរចាពាណិជ្ជកម្ម ស្តីពី "ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP)" លើកទី១០ ពីថ្ងៃទី១០-១៧ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ។ ប្រទេសចូលរួមក្នុង RCEP បានផ្តល់នូវកញ្ចប់សន្យាបឋមនៃពាណិជ្ជកម្មសេវា។ ភាគីទាំងអស់បានចាប់ផ្តើមចរចាទ្វេភាគីលើកញ្ចប់សន្យាដែលបាន

ផ្តល់។ ប្រទេសកម្ពុជាបានបញ្ចប់ការចរចា ទ្វេភាគីលើកញ្ចប់សន្យាបឋម ជាមួយប្រទេសដៃគូពាណិជ្ជកម្មសេរីអាស៊ានមួយចំនួន។ មន្ត្រីក្រសួងក៏បានចូលរួមចរចាផងដែរ នៅក្នុងក្រុមការងារស្តីពីវិធានប្រភពដើមទំនិញ (ROO) ដែលប្រព្រឹត្តទៅដោយភាពរៀនរលូន

- ចូលរួមធ្វើជាវាគ្មិនអំពីខ្សែក្រវាត់មួយផ្លូវមួយ (One Belt One Road) ភាពជាដៃគូឆ្លងសមុទ្រប៉ាស៊ីហ្វិក (TPP) ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) និងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងបានចូលរួមជាវាគ្មិន និងពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមការងារអភិវឌ្ឍន៍ពាណិជ្ជកម្មដោយផ្តោតសំខាន់ផងដែរទៅលើជំនួយសម្រាប់ពាណិជ្ជកម្ម ការអនុគ្រោះពាណិជ្ជកម្មដូចជាៈ ការមិនជាប់ពន្ធគយ និងមិនជាប់កូតានិងបញ្ហាផ្សេងៗទៀត ដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្មនិងកាត់បន្ថយភាពក្រីក្រជាដើម។

## ២.៦.៧ ការងារអនុតំបន់

- សម្របសម្រួល រៀបចំឯកសារនិងចូលរួមកិច្ចប្រជុំលើកទី១ ក្រុមការងារចរចាកិច្ចព្រមព្រៀង ស្តីពី "ការជំរុញ និងសម្រួលពាណិជ្ជកម្មសំរាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV DTA)" នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ពីថ្ងៃទី១-៤ ខែកុម្ភៈ ឆ្នាំ២០១៥។ កិច្ចប្រជុំបានផ្លាស់ប្តូរយោបល់លើសេចក្តីព្រាងទី១ នៃកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងបានឯកភាពយកសេចក្តីព្រាងនេះទៅពិភាក្សានៅឯកិច្ចប្រជុំលើកទី២ នៅទីក្រុងក្រចេះ ព្រះរាជាណាចក្រកម្ពុជា នៅក្នុងខែឧសភា ឆ្នាំ២០១៥
- ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ និងចូលរួមកិច្ចប្រជុំលើកទី២ នៃក្រុមការងារចរចាកិច្ចព្រមព្រៀង ស្តីពី "ការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម (CLV DTA TPFA)" នៅទីក្រុងក្រចេះ ព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី១១-១២ ខែឧសភា ឆ្នាំ២០១៥ ដោយជោគជ័យ។ កិច្ចប្រជុំបានពិភាក្សា និងឯកភាពលើជំពូកចំនួន៣ និងមាត្រា ចំនួន១៣។ កិច្ចប្រជុំបានពិភាក្សា និងធ្វើបច្ចុប្បន្នភាពនៃការបង្កើតក្រុមការងារជាតិស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍ CLV និងឯកភាពលើទិសដៅនៃការចរចាបញ្ចប់កិច្ចព្រមព្រៀង CLV DTA TPFA តែចំនួន ៥ កិច្ចប្រជុំប៉ុណ្ណោះ គឺកិច្ចប្រជុំលើកទី៣ កំណត់ធ្វើនៅខែកញ្ញា ឆ្នាំ២០១៥ នៅខេត្តចំប៉ាសាក់ ប្រទេសឡាវ កិច្ចប្រជុំលើកទី៤ កំណត់ធ្វើនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ នៅខេត្តដាក់ឡាក់ ប្រទេសវៀតណាម និងកិច្ចប្រជុំលើកទី៥ កំណត់ធ្វើនៅដើមខែកុម្ភៈ ឆ្នាំ២០១៦ នៅទីក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រជុំបានឯកភាពថា សេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបញ្ចប់ការពិនិត្យលើទិដ្ឋភាពច្បាប់ និងដាក់ជូនរដ្ឋមន្ត្រីពិចារណា និងអនុម័ត។ កិច្ចប្រជុំបានស្នើថា កិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាមលើកទី៩ នៅព្រះរាជាណាចក្រកម្ពុជា នៅក្នុងឆ្នាំ២០១៦
- រៀបចំ និងផ្តល់ឯកសារសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់រៀបចំឯកសារជូនសម្តេចតេជោ ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជាចូលរួមកិច្ចប្រជុំកំពូល កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា និងវៀតណាម លើកទី៧ ពីថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ២០១៥ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា
- ចូលរួមកិច្ចប្រជុំជាមួយសមាជិករដ្ឋសភា និងព្រឹទ្ធសភាកម្ពុជា ដឹកនាំដោយ **ឯកឧត្តម ឈាង វុន ប្រធានគណៈកម្មាធិការទី៥** នៃរដ្ឋសភា ដើម្បីរាយការណ៍ និងពិភាក្សាអំពីតំបន់ត្រីកោណ

អភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥ នៅវិមានរដ្ឋសភាកម្ពុជា ដោយជោគជ័យ។ ឯកឧត្តម ឈាង វុន បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការអនុវត្តការងារ CLV DTA របស់រាជរដ្ឋាភិបាលកម្ពុជាជាពិសេស កិច្ចប្រតិបត្តិការល្អរបស់ក្រសួងពាណិជ្ជកម្ម ដែលជាក្រសួងនាំមុខការងារ CLV DTA ជាមួយរដ្ឋសភាជាតិកម្ពុជា។ ឯកឧត្តមប្រធានបានស្នើឲ្យរដ្ឋាភិបាល ជាពិសេស ក្រសួងពាណិជ្ជកម្មបន្ត និងបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយសភាជាតិកម្ពុជា

- អមដំណើរគណៈប្រតិភូកម្ពុជាចូលរួមសន្និសីទរដ្ឋមន្ត្រីមហាអនុតំបន់មេគង្គ (GMS) លើកទី ២០ ពីថ្ងៃទី៩-១០ ខែកញ្ញា ឆ្នាំ២០១៥ នៅទីក្រុងណៃពិដោរ ប្រទេសមីយ៉ាន់ម៉ា។ រដ្ឋមន្ត្រីបានពិនិត្យឡើងវិញអំពីសមិទ្ធផលថ្មីៗ នៃកិច្ចសហប្រតិបត្តិការមហាអនុតំបន់មេគង្គ រួមមានដូចជាវឌ្ឍនភាពនៃផែនការអនុវត្តន៍ក្របខ័ណ្ឌការងារវិនិយោគក្នុងតំបន់ (RIF-IP) និងពិភាក្សារកវិធីសាស្ត្រនានា ដើម្បីអនុវត្តផែនការការងារនេះទទួលបាននូវប្រសិទ្ធភាពខ្ពស់។ រដ្ឋមន្ត្រី GMS បានអនុម័តលើក្របខ័ណ្ឌការងារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ទីក្រុងក្នុងមហាអនុតំបន់មេគង្គនិងវាយតម្លៃខ្ពស់លើគំនិតផ្តួចផ្តើមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការបង្កើតនូវគម្រោងទិន្នន័យសម្រាប់តំបន់ GMS
- សម្របសម្រួល រៀបចំ និងដឹកនាំកិច្ចប្រជុំកិច្ចប្រជុំអន្តរក្រសួងនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីត្រៀមចូលរួមកិច្ចប្រជុំចរចា កិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម លើកទី៣។ កិច្ចប្រជុំបានពិនិត្យមើលនូវកថាខ័ណ្ឌ និងមាត្រាមួយចំនួនដែលបន្សល់ពីកិច្ចប្រជុំលើកទី២ និងឯកភាពលើចំណុច និងជំហរមួយចំនួនដើម្បីយកទៅចរចាជាមួយភាគីវៀតណាម
- សម្របសម្រួល និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំកិច្ចលើកទី៣ នៃក្រុមការងារចរចាកិច្ចព្រមព្រៀងជំរុញ និងសម្រួលពាណិជ្ជកម្មសំរាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV DTA TPFA) លើកទី៣ នៅទីក្រុងប៉ាកសេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ ពីថ្ងៃទី ២៣-២៤ ខែកញ្ញាឆ្នាំ ២០១៥ ប្រកបដោយជោគជ័យ។ កិច្ចប្រជុំបានពិភាក្សា និងឯកភាពលើមាត្រាមួយចំនួនបន្ថែម ទៀតនៅក្នុងកិច្ចព្រមព្រៀង CLV DTA TPFA។ កិច្ចប្រជុំ បានកត់សំគាល់លើមាត្រា ៨.២ ស្តីពីសំណើគ្រប់គ្រងសាច់ប្រាក់ ដែលបានលើកឡើងដោយភាគីឡាវ និងវៀតណាម។ កម្ពុជាពុំបានឯកភាពលើមាត្រា ៨.២ នេះទេ ហើយកម្ពុជាក៏បានលើកជាសំណើរថ្មីមួយផ្សេងទៀត គឺមាត្រា ៨.៣ ដោយកម្ពុជាចង់បានឲ្យមានការកំណត់ទឹកប្រាក់ច្បាស់លាស់ តាមច្បាប់អន្តរជាតិសម្រាប់ ឲ្យអ្នកធ្វើដំណើរកាន់សាច់ប្រាក់ទូទៅ ឆ្លងកាត់ព្រំដែននៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម អាចនឹងយកសាច់ប្រាក់តាមខ្លួនបានក្រោមមួយម៉ឺនដុល្លារ ក៏ប៉ុន្តែ បើអ្នកធ្វើដំណើរទូទៅកាន់សាច់ប្រាក់លើសពីមួយម៉ឺនដុល្លារ ត្រូវតែជូនដំណឹងដល់អាជ្ញាធរគយ នៅតាមមាត់ច្រកព្រំដែន។ កិច្ចប្រជុំ មិនបានឯកភាពគ្នាលើសំណើរទាំងពីរនេះទេ គឺទុកពិនិត្យ និងពិភាក្សាគ្នានៅកិច្ចប្រជុំលើកក្រោយកិច្ចប្រជុំបានឯកភាពលើមាត្រាមួយចំនួនបន្ថែមទៀត ហើយនឹងបន្តពិភាក្សាបន្ថែមទៀតទៅលើមាត្រាដែលនៅសេសសល់ ហើយភាគីនីមួយៗ អាចនឹងលើកនូវសំណើបន្ថែមទៀតសម្រាប់ដាក់បញ្ចូលក្នុងមាត្រានីមួយៗ នៅឯកិច្ចប្រជុំលើកក្រោយដែលគ្រោងធ្វើនៅទីក្រុងដាក់ឡាក់ ប្រទេសវៀតណាមនៅដើមឆ្នាំ២០១៦
- ត្រៀមរៀបចំឯកសារ និងសម្របសម្រួលការងារ ពាក់ព័ន្ធសម្រាប់ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះសម្រាប់អភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម លើកទី១០ និងកិច្ច

ប្រជុំពាក់ព័ន្ធ ដែលគ្រោងនឹងប្រារព្ធធ្វើពីថ្ងៃទី០៧-១១ ខែធ្នូ ឆ្នាំ២០១៥ នៅទីក្រុងប៉ាកសេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ

- សម្របសម្រួលរៀបចំកិច្ចប្រជុំពិភាក្សាត្រៀមនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ សម្រាប់ទៅចូលរួមកិច្ចប្រជុំ CLV DTA JCC លើកទី១០ និងកិច្ចប្រជុំពាក់ព័ន្ធ។ កិច្ចប្រជុំបានពិភាក្សាទៅលើការបែងចែកការងារពេលទៅចូលរួមប្រជុំនៅប្រទេសឡាវ និងពិភាក្សាលើកិច្ចការមួយចំនួនស្តីពីការត្រៀមរៀបចំកិច្ចប្រជុំអន្តរក្រសួង នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥។

## ២.៦.៨ ការទារទ្វេភាគី

- សហការ សម្របសម្រួល រៀបចំឯកសារ និងធ្វើជំនួយស្មារតីស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មរវាងកម្ពុជា-ចិន ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ទទួលជួបពិភាក្សាទ្វេភាគី ជាមួយគណៈប្រតិភូពាណិជ្ជកម្មដឹកនាំដោយលោកជំទាវ កៅ យាន (Gao Yan) អនុរដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន នៅព្រះរាជាណាចក្រកម្ពុជាពីថ្ងៃទី២៤-២៧ ខែឧសភា ឆ្នាំ២០១៥
- ដឹកនាំកិច្ចប្រជុំលើកទី៥ នៃគណៈកម្មាធិការសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងកម្ពុជា និងចិន នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ នៅសណ្ឋាគារភិសហ្វីលឡឺយ៉ាល់ នៃទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រកបដោយជោគជ័យ
- រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូក្រសួងពាណិជ្ជកម្មចូលរួមកិច្ចប្រជុំត្រៀមនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥ ដើម្បីពិនិត្យមើលលើសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-វៀតណាម ស្តីពីសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសលើកទី១៤ នៅខែតុលា ឆ្នាំ២០១៥ នៅប្រទេសវៀតណាម ដែលត្រូវដឹកនាំដោយ **ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម Pham Binh Minh ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសវៀតណាម។ ក្រសួងពាណិជ្ជកម្មបានផ្តល់នូវយោបល់មួយចំនួនពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម និងវិនិយោគ
- សម្របសម្រួលរៀបចំ និងចូលរួមកិច្ចប្រជុំកិច្ចប្រជុំអន្តរក្រសួងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ នៅក្រសួងពាណិជ្ជកម្ម ដើម្បីត្រៀមរៀបចំកិច្ចប្រជុំចរចា ស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម។ កិច្ចប្រជុំបានឯកភាពចំណុចមួយចំនួនដើម្បីចរចាជាមួយភាគីវៀតណាម
- ទទួលជាម្ចាស់ផ្ទះរៀបចំ និងចូលរួមកិច្ចប្រជុំចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាមនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ប្រកបដោយជោគជ័យ។ កិច្ចប្រជុំបានបន្តចរចាជំពូក និងមាត្រាមួយចំនួននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម ដែលបន្សល់ពីកិច្ចប្រជុំលើកទី១ និងបានឯកភាពនូវកថាខណ្ឌ និងមាត្រាមួយចំនួនបន្ថែមទៀត
- ចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់សហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃ លើកទី៩ ដែលបានប្រារព្ធធ្វើកាលពីថ្ងៃទី១៥-១៦ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាប។ ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មភាគីទាំងពីរបានសំដែងនូវការកោតសរសើរពីកំណើនពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍រវាងប្រទេសទាំងពីរ។ កិច្ចប្រជុំរំពឹងទុកថា ពាណិជ្ជកម្មទ្វេភាគី នឹងកើនឡើងជារៀងរាល់ឆ្នាំ ទៅតាមសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្មប្រទេសទាំងពីរ ដែលនឹងជំរុញឲ្យពាណិជ្ជកម្ម ទ្វេភាគីកើនឡើងបាន ៣០% ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ

២០១៥។ ដើម្បីបង្កើនពាណិជ្ជកម្ម និងវិនិយោគបន្ថែមទៀត ភាគីទាំងពីរនឹងរៀបចំកិច្ចចរចាលើកិច្ចព្រមព្រៀង ស្តីពីការជៀសវាងយកពន្ធទ្វេដងនៅពេលឆាប់ៗនេះ។ ភាគីថៃបានស្នើសុំឲ្យអ្នកជំនួញកម្ពុជាទាំងវិស័យសាធារណៈ និងឯកជនពិចារណាលើការប្រើប្រាស់ផ្សារមូលធនរបស់ថៃ (Thai Capital Market) ធ្វើជាទុនចលនទ្រព្យ ដើម្បីជួយជំរុញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា

- សម្របសម្រួលការពិភាក្សាការងារជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងភាគីវៀតណាម ដើម្បីពិនិត្យមើលឡើងវិញលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅតាមព្រំដែនរវាងកម្ពុជា និងវៀតណាម កិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម
- សម្របសម្រួលត្រៀមចូលរួមកិច្ចប្រជុំគណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-ថៃ លើកទី៥ ដែលពីថ្ងៃទី០៣-០៤ ខែធ្នូ ឆ្នាំ២០១៥ ក្រុងបាងកក ដើម្បីបន្តពិភាក្សារកដំណោះស្រាយលើបញ្ហាសំខាន់ៗមួយចំនួនដូចជា៖ បញ្ហាទាក់ទងនឹងការនាំទំនិញកសិផលកម្ពុជាចូល និងឆ្លងកាត់ប្រទេសថៃ ពីស្ថានភាពពាណិជ្ជកម្មទ្វេភាគី ត្រួតពិនិត្យលទ្ធផលអនុវត្តផែនការសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជានិងថៃ និងបញ្ហាថ្មីៗមួយចំនួនទៀត។

## ២.៦.៩ សហគមន៍សេដ្ឋកិច្ចអាស៊ាន

- តាមការអញ្ជើញរបស់ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មឡាវ មន្ត្រីក្រសួងពាណិជ្ជកម្មបានចូលរួមធ្វើជាវាគ្មិន ដើម្បីចែករំលែកបទពិសោធន៍ នៅក្នុងសិក្ខាសាលាស្តីពីសហគមន៍ សេដ្ឋកិច្ចអាស៊ាន (AEC) នៅទីក្រុងវៀងច័ន្ទ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៥ ដោយមានការចូលរួមស្តាប់ និងពិភាក្សា ពីផ្នែករដ្ឋាភិបាល ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលចំនួនជាង ៣០០នាក់
- ចុះផ្សព្វផ្សាយស្តីពី "សហគមន៍សេដ្ឋកិច្ចអាស៊ាន" នៅតាមខេត្ត-ក្រុងមួយចំនួន ដើម្បីឲ្យពួកគេប្រុងប្រៀបរៀបចំខ្លួនចូលរួមនិងធ្វើយុទ្ធសាស្ត្រ រកវិធីដោះស្រាយចំពោះការប្រឈម និងផលប៉ះពាល់នានាលើជីវភាពរស់នៅ ការងារ និងអាជីវកម្ម ពីការកែទម្រង់ ការប្រកួតប្រជែង ក៏ដូចជាទាញយកឱកាសនិងអត្ថប្រយោជន៍ ពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៦-២០២៥
- រៀបចំទូរជំនួយស្មារតី បទបង្ហាញ និងសុន្ទរកថានានា ជូនថ្នាក់ដឹកនាំ សម្រាប់វេទិកា និងសិក្ខាស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន និងវេទិកានានាស្តីពីពាណិជ្ជកម្មនៅក្នុងប្រទេស និងអន្តរជាតិ។

## ២.៦.១០ ពាណិជ្ជកម្មសេវា

- ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអាស៊ាន ស្តីពី "សេវាលើកទី៨០ (80 CCS) និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធ" ពីថ្ងៃទី១២-១៦ ខែមករា ឆ្នាំ២០១៥ នៅទីក្រុងសៀមរាបព្រះរាជាណាចក្រកម្ពុជា ប្រកបដោយជោគជ័យ។ កិច្ចប្រជុំបានពិភាក្សារៀបចំបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន (ATISA) ដែលនឹងជំនួយកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា(AFAS) ហើយគ្រោងចុះហត្ថលេខានៅក្នុងឆ្នាំ២០១៦។ កិច្ចប្រជុំបានចាប់ផ្តើមពិភាក្សារៀបចំកញ្ចប់សន្យាទី ១០ ឬកញ្ចប់ចុងក្រោយ នៃកិច្ចព្រមព្រៀង AFAS ជាពិសេសការផ្តល់ការសន្យាលើ បណ្តាអនុវិស័យសេវា នៅចន្លោះកម្រិតពី ១០៤ អនុវិស័យ ដល់ ១២៨ អនុវិស័យសម្រាប់កញ្ចប់សន្យាទី១០ តាមសេចក្តីសម្រេចរបស់កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤៤ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ នៅទីក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា។

កិច្ចប្រជុំបានឯកភាពរាយការណ៍អំពី លទ្ធផលនៃការពិភាក្សាជំបូងនេះ ជូនកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រីនៅកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅចុងខែកុម្ភៈ ឆ្នាំ២០១៥

- រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួម កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអាស៊ាន ស្តីពីសេវាលើកទី៨១ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ពីថ្ងៃទី៥-៨ ខែឧសភា ឆ្នាំ២០១៥។ កិច្ចប្រជុំបានបន្តពិភាក្សាសេចក្តីព្រាងកញ្ចប់សន្យាទី ១០ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា។ ដោយជួបនូវបញ្ហាលំបាកនៅក្នុងការបំពេញបានតាមចន្លោះកម្រិតពី ១០៤ ដល់ ១២៨ អនុវិស័យសម្រាប់កញ្ចប់ទី១០ កិច្ចប្រជុំបានឯកភាពដាក់ចេញនូវសំណើមួយចំនួនដូចជា៖ បង្កើនចំនួននៃភាពទន់ភ្លន់រហូតដល់ ១៥%, កាត់បន្ថយនូវកំរិតកំណត់នៃតម្លៃទ្រព្យបរទេសពី ៧០% មកនៅត្រឹម ៥០%,ពន្យាការកំណត់ពេលនៃការបញ្ចប់កញ្ចប់ទី១០, និងការរៀបចំសម្រាប់រយៈពេលអន្តរកាល ឲ្យស្របនឹងទិសដៅដើមរបស់កញ្ចប់ទី១០។ល។ កិច្ចប្រជុំបានឯកភាពធ្វើរបាយការណ៍ជូនឧត្តមមន្ត្រីនិងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានដើម្បីសូមការណែនាំ
- រៀបចំ និងដឹកនាំកិច្ចប្រជុំអន្តរក្រសួងនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដើម្បីពិភាក្សាអំពីការធ្វើសេចក្តីព្រាងកញ្ចប់សន្យាទី១០ ឬកញ្ចប់សន្យាចុងក្រោយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាសម្រាប់យកទៅពិភាក្សា នៅឯកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអាស៊ានស្តីពីសេវាកម្ម លើកទី៨២ ពីថ្ងៃទី២៨ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៥ នៅប្រទេសសិង្ហបុរី
- សម្របសម្រួល រៀបចំឯកសារ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល អាស៊ានស្តីពីសេវាលើកទី៨២ (82 CCS) និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធ ពីថ្ងៃទី២៨ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៥ នៅទីក្រុងសិង្ហបុរី ប្រកបដោយជោគជ័យ។ កិច្ចប្រជុំបានបន្តពិភាក្សារៀបចំកញ្ចប់សន្យាទី១០ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា និងបានបន្តពិភាក្សារៀបចំបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន (ATISA) ដែលនឹងជំនួយកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា និងគ្រោងដាក់ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានចុះហត្ថលេខានៅក្នុងឆ្នាំ២០១៦។ កិច្ចប្រជុំបានវាយតម្លៃចំពោះការផ្តល់ជំបូងកញ្ចប់សន្យាទី១០ នៃកិច្ចព្រមព្រៀង AFAS។ ក្នុងចំណោមប្រទេសអាស៊ាន មានតែប្រទេសសិង្ហបុរី ថៃ និងមីយ៉ាន់ម៉ាប៉ុណ្ណោះ ដែលបំពេញបាននូវការផ្តល់អនុវិស័យសេវាចំនួន៥០% ក្នុងកញ្ចប់សន្យាទី១០ សម្រាប់ឆ្នាំ២០១៥។ ការវាយតម្លៃរបស់លេខាធិការដ្ឋានអាស៊ាន ប្រទេសកម្ពុជានឹងត្រូវផ្តល់ការសន្យាបើកចំហរអនុវិស័យចំនួន១០ បន្ថែម ដើម្បីបំពេញបាន ៥០% នៃអនុវិស័យនៃកញ្ចប់សន្យាទី១០ សម្រាប់ឆ្នាំ២០១៥។

## ២.៧ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

- ទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Dherar Naser Ebrahim Al-Najran Al-Tuwaijri ឯកអគ្គរដ្ឋទូតនៃរដ្ឋគូវ៉ែតប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាអំពីការពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ
- រៀបចំឯកសារសំខាន់ៗ រួមមានឯកសារជំនួយស្មារតីអំពី ប្រទេសស្វ៊ីស អាហ្វ្រិកខាងត្បូង ហ្សាំងប៊ូកូឡំបឺ ដាណឺម៉ាក អាល្លឺម៉ង់ អេហ្ស៊ីប តួកគី និងសហព័ន្ធរុស្ស៊ី ដើម្បីប្រមូលទិន្នន័យស្ថិតិពាណិជ្ជកម្ម និងព័ត៌មានអំពីផលិតផលសក្តានុពល និងទីផ្សារសម្រាប់ចូលរួមកិច្ចប្រជុំ ស្តីពីវេទិកាសេដ្ឋកិច្ចពិភពលោកនៅដាវ៉ូស ប្រទេសស្វ៊ីស

- ទទួលជួបពិភាក្សាការងារជាមួយលោក Yoichi Kobayashi នាយកក្រុមហ៊ុន ITOCHU Corporation និងជាប្រធានគណៈកម្មាធិការជប៉ុន-មេគង្គនៃលេខាធិការដ្ឋានសភាពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសជប៉ុន ដើម្បីជំរុញឲ្យមានការបណ្តាក់ទុនពីជប៉ុនមកកម្ពុជា ការហោះហើរត្រង់រវាងកម្ពុជា និងជប៉ុន ព្រមទាំងការលុបចោលទិដ្ឋាការចូលរបស់ប្រទេសទាំងពីរ
- ជំនួបពិភាក្សាការងារជាមួយឯកឧត្តម វីតេសស្លេវ ប្រ្លាផល ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឆេក ប្រចាំកម្ពុជា
- រៀបចំ និងបង្កើតប្រកាសលេខ០៣៦ ព.ណអមអ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការ និងអនុគណៈកម្មការរៀបចំកិច្ចប្រជុំលើកទី១ ស្តីពីគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី
- សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចែករំលែកនូវព័ត៌មាន និងបានផ្តល់នូវរបាយការណ៍ស្តីពីបេសកកម្មពាណិជ្ជកម្មនៅរដ្ឋតួប៊ីត ពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥
- ទទួលជួបពិភាក្សាការងារជាមួយលោក Recep Eriş អនុតំណាងស្ថានទូតបេសកកម្មនិងជាលេខាទី១ នៃស្ថានទូតសាធារណរដ្ឋតួកគីប្រចាំនៅកម្ពុជា នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ដើម្បីពិនិត្យមើលអំពីការងារត្រៀមរៀបចំទូទៅ រាប់បញ្ចូលទាំងការពិភាក្សាអំពីរបៀបវារៈកិច្ចប្រជុំ និងការងារបដិសណ្ឋារកិច្ចរបស់កម្ពុជាចំពោះគណៈប្រតិភូតួកគី ដែលនឹងអញ្ជើញមកចូលរួមកិច្ចប្រជុំលើកទី១ នៃគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី
- រៀបចំកិច្ចប្រជុំត្រៀមផ្ទៃក្នុងក្រសួងពាណិជ្ជកម្ម សម្រាប់កិច្ចប្រជុំលើកទី១ ស្តីពីគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីអនុគណៈកម្មការទាំងអស់ ដើម្បីជម្រាបជូនអំពីការងារ និងការបែងចែកការងារក្នុងអនុគណៈកម្មាធិការទាំងអស់
- រៀបចំកិច្ចប្រជុំត្រៀមអន្តរក្រសួងសម្រាប់កិច្ចប្រជុំលើកដំបូង ស្តីពីគណៈកម្មការសេដ្ឋកិច្ចចម្រុះរវាងកម្ពុជា និងសាធារណរដ្ឋតួកគី នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីមន្ត្រីតំណាងអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ១៣ ដើម្បីពិនិត្យទៅលើសេចក្តីព្រាងរបៀបវារៈកិច្ចប្រជុំ និងកំណត់ហេតុកិច្ចប្រជុំរួម សំដៅរៀបចំជំហររួមរបស់កម្ពុជាក្នុងការចរចាជាមួយភាគីតួកគី
- សម្របសម្រួលការងារជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីបញ្ជូនសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជានិងតួកគី ស្តីពីស្តង់ដារនិងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នស្តង់ដារនៃប្រទេសទាំងពីរ
- រៀបចំប្រកបដោយជោគជ័យ និងមានផ្លែផ្កា កិច្ចប្រជុំលើកទី១ ស្តីពីគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១០-១១ ខែកុម្ភៈ ឆ្នាំ២០១៥ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ ក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម ដែលជាសហប្រធានអង្គប្រជុំជាមួយនឹងឯកឧត្តម Fikri IŞIK រដ្ឋមន្ត្រីក្រសួងវិទ្យាសាស្ត្រ ឧស្សាហកម្ម និងបច្ចេកវិទ្យានៃសាធារណរដ្ឋតួកគី
- ចូលរួមជាមួយថ្នាក់ដឹកនាំក្រសួង នៅក្នុងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង-ស្ថាប័ន សម្រាប់ដោះស្រាយបញ្ហាដី សម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំអំពៅផលិតស្ករសនាំចេញ នៅថ្ងៃទី១២ ខែកុម្ភៈ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥

- ជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូមួយក្រុមមកពីប្រទេសជប៉ុន ដែលដឹកនាំដោយលោក Shosuke MORI ប្រធានសហព័ន្ធសេដ្ឋកិច្ចតំបន់កាន់សៃ (Kankeiren) រួមទាំងគណៈប្រតិភូដែលមានសមាសភាពជា នាយកប្រតិបត្តិជាន់ខ្ពស់ក្រុមហ៊ុនជប៉ុនធំៗ ចំនួន ៣៦រូបនិង ឯកឧត្តម KUMAMARU Yuji ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំនៅកម្ពុជា នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- សហការជាមួយក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម វៀតណាម ដើម្បីរៀបចំឱ្យមានទស្សនកិច្ចសិក្សារបស់មន្ត្រី ដើម្បីស្វែងយល់អំពីបទពិសោធរបស់វៀតណាម នៅក្នុងការចរចាបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយសហភាពសេដ្ឋកិច្ចអាស៊ី-អឺរ៉ុប (EEU)
- រៀបចំឯកសារសំខាន់ៗ រួមមាន៖ សេចក្តីព្រាងច្បាប់និងសេចក្តីថ្លែងហេតុ សម្រាប់ស្នើសុំឱ្យសភាផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀង ស្តីពី កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ព្រមទាំងបានចូលរួមជាមួយថ្នាក់ដឹកនាំក្រសួង ដើម្បីការពារច្បាប់នៅរដ្ឋសភា និងព្រឹទ្ធសភា បន្ថែមពីលើការចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការជំនាញយ៉ាងច្រើនរបស់ស្ថាប័នទាំងពីរនេះ
- ចូលរួមកិច្ចប្រជុំចង្កៀតដើម្បីពិភាក្សា អំពីការអនុម័តលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី
- សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អំពីលទ្ធភាពក្នុងការរៀបចំបេសកកម្មផ្លូវការរបស់ថ្នាក់ដឹកនាំក្រសួងទៅសហព័ន្ធរុស្ស៊ី ចាប់ពីថ្ងៃទី២-៤ ខែមីនា ឆ្នាំ២០១៥ ប៉ុន្តែកាលបរិច្ឆេទនៃបេសកកម្មនេះជាន់គ្នាទៅនឹង កិច្ចប្រជុំចង្កៀតថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី
- ទទួលជួបជាមួយលោក Andrey Vladimirov ដែលជា Minister Counsellor នៃស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ដើម្បីពិភាក្សាអំពីផលិតផលសក្តានុពលរបស់កម្ពុជា រួមមានផលិតផលកសិកម្ម និងអាហារសមុទ្រ ព្រមទាំងការបង្កើតក្រុមការងារជាន់ខ្ពស់អន្តររដ្ឋាភិបាល ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី
- ជំនួបពិភាក្សាការងារជាមួយតំណាង Eurocham លោក Emmanuel Mananteau ប្រធានសភាពាណិជ្ជកម្មអឺរ៉ុប ដែលអមដំណើរដោយលោក Guillaume Massin នាយកគ្រប់គ្រងផ្នែកច្បាប់ និងពន្ធដារនៃ DFDL លោក Blaise Kilian នាយកផ្នែកតាំទ្រសភាពាណិជ្ជកម្មអឺរ៉ុប នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ នៅទីស្តីការក្រសួង ពាណិជ្ជកម្ម ដើម្បីពិនិត្យអំពីយន្តការនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងពាណិជ្ជកម្ម និង Eurocham រួមមានការរៀបចំឲ្យមានការចុះអនុស្សរណៈនៃការយោគយល់គ្នាមួយ
- ចូលរួមជាមួយថ្នាក់ដឹកនាំក្រសួង ក្នុងជំនួបពិភាក្សាការងារជាមួយឯកឧត្តម Joachim Baron von Marschall ឯកអគ្គរដ្ឋទូត នៃសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដើម្បីជំរុញឱ្យមានចំណាប់អារម្មណ៍បន្ថែមទៀត ពីវិនិយោគិនអាល្លឺម៉ង់មកលើកម្ពុជា រួមមានការរៀបចំទស្សនកិច្ចរបស់វិនិយោគិនអាល្លឺម៉ង់មកកាន់ប្រទេសកម្ពុជា នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ដើម្បីសិក្សាស្វែងយល់ដោយផ្ទាល់អំពីកាលានុវត្តភាពវិនិយោគ
- រៀបចំលិខិតស្នើសុំគោលការណ៍ពី សម្តេចតេជោនាយករដ្ឋមន្ត្រី ចំពោះសំណើរបស់រុស្ស៊ី ក្នុងការបង្កើតក្រុមការងារជាន់ខ្ពស់ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងកម្ពុជា-រុស្ស៊ី

- សហការជាមួយសន្និសីទអង្គការសហប្រជាជាតិសម្រាប់ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD) ដើម្បីស្នើសុំអ្នកជំនាញការ ជួយក្រសួងក្នុងការរៀបចំបង្កើត គោលនយោបាយពាណិជ្ជកម្មថ្មីសម្រាប់កម្ពុជារួមមានៈ ការសិក្សាអំពីលទ្ធភាពនៃការបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងកម្ពុជា និងសហភាពអឺរ៉ុប និងការវិភាគផលប៉ះពាល់ការបង្កើតតំបន់ពាណិជ្ជកម្មសេរីរបស់សមាជិកអាស៊ានមកលើកម្ពុជាជាដើម
- បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលាសើរីលើកទី៦ របស់ក្រសួងពាណិជ្ជកម្មស្តីពី ការកសាងម៉ាកយីហោសម្រាប់កម្ពុជា ដែលបានប្រព្រឹត្តទៅនៅវិទ្យាស្ថានជាតិអប់រំ (ជិតវិមានឯករាជ្យ)
- ចូលរួមកម្មវិធីពិសារអាហាររបស់ Eurocham Cambodia នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយដល់ វិស័យឯកជនរបស់សហភាពអឺរ៉ុប អំពីបច្ចុប្បន្នភាពនៃកំណែទម្រង់របស់ក្រសួងពាណិជ្ជកម្ម បរិយាកាសវិនិយោគ និងស្ថានភាពនៃសេដ្ឋកិច្ចកម្ពុជា
- ចូលរួមក្នុងកិច្ចប្រជុំអនុគណៈកម្មាធិការអេចិន្ត្រៃយ៍ ស្តីពីការអភិវឌ្ឍពាណិជ្ជកម្ម និងការវិនិយោគពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មលើកទី២១
- ចូលរួមក្នុងកិច្ចប្រជុំជាមួយបេសកកម្មរបស់សហភាពអឺរ៉ុប ស្តីពីកម្មវិធីគ្រប់គ្រងកសិកម្ម ឬធនធានធម្មជាតិសម្រាប់ឆ្នាំ២០១៤-២០២០
- រៀបចំ និងលើកឡើងគម្រោងបី ក្រោមកម្មវិធីជំនួយរបស់សហភាពអឺរ៉ុបរួមមាន (១)ការសិក្សាអំពីលទ្ធភាពនៃ ការបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយសហភាពអឺរ៉ុប (២)ការសិក្សាអំពីការផ្លាស់ប្តូរវិធានប្រភពដើមកំណើតទំនិញមកលើសេដ្ឋកិច្ចកម្ពុជា និង(៣) ការបង្កើនសមត្ថភាពចរចាដល់មន្ត្រីនាយកដ្ឋានតាមរយៈការផ្តល់ឱ្យនូវវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា
- សហការជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីពិនិត្យមើលសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មរវាងកម្ពុជា និងកាតា
- រៀបចំជំនួបសំដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Nikolai Nikiforov នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥។ ជាលទ្ធផល កម្ពុជាបានជំរុញឲ្យរុស្សីពិនិត្យបញ្ចីផលិតផលចំនួន ៣.០០០ មុខ ដែលរុស្សីបានយល់ព្រម លើកលែងពន្ធនិងមិនកំណត់កូតាសម្រាប់កម្ពុជា ដើម្បីនាំចេញទៅកាន់ប្រទេសរុស្សី និងបានគូសបញ្ជាក់ដល់វិនិយោគិនរុស្សី ក្នុងការស្វែងយល់អំពីវិស័យសណ្ឋាគារ និងឧស្សាហកម្មទេសចរណ៍ និងតំបន់សេដ្ឋកិច្ចពិសេស នៅខេត្តព្រះសីហនុ និងពិនិត្យមើលលទ្ធភាពនៃការបង្កើតជើងហោះហើរត្រង់រវាងរុស្សី និងកម្ពុជា
- រៀបចំកម្មវិធីវេទិកាធុរកិច្ចកម្ពុជា-រុស្សី ដែលបានប្រព្រឹត្តទៅ នៅទីស្តីការក្រសួងពាណិជ្ជកម្មដែលមានការអញ្ជើញចូលរួមពីវិស័យឯកជនកម្ពុជា និងតំណាងក្រុមហ៊ុនជាច្រើនមកពីសហព័ន្ធរុស្សី។ ជាលទ្ធផលនៃកម្មវិធីវេទិកានេះ ក្រុមហ៊ុនកម្ពុជា បានជំរុញឲ្យវិនិយោគិនរុស្សីចាប់អារម្មណ៍លើការវិនិយោគលើវិស័យកសិកម្ម ថាមពល ទូរគមនាគមន៍ និងទេសចរណ៍
- កម្មវិធីទស្សនកិច្ចសិក្សាចែករំលែកបទពិសោធន៍របស់វៀតណាម ក្នុងការចរចាកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីរវាងវៀតណាម និងសហភាពសេដ្ឋកិច្ចអាស៊ី-អឺរ៉ុប (Eurasian Economic Union) នៅប្រទេសវៀតណាម។ ជាលទ្ធផល គណៈប្រតិភូបានសិក្សាស្វែងយល់ និងជ្រួតជ្រាបអំពីនីតិវិធីក្នុងការចរចាកិច្ចព្រមព្រៀង តំបន់ពាណិជ្ជកម្មសេរីរវាងប្រទេសមួយ ជាមួយសហភាពសេដ្ឋកិច្ចអាស៊ី-អឺរ៉ុប (EEU) ការស្រាវជ្រាវអំពីផលប៉ះពាល់ និងអត្ថប្រយោជន៍នៃការចរចាកិច្ចព្រមព្រៀងនេះ
- រៀបចំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ដើម្បីពិភាក្សាលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេសរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋ

ប៊ុលហ្គារី និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា" ដែលមានការអញ្ជើញចូលរួមពីតំណាងអន្តរក្រសួងចំនួន១៧ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ នៅទីស្តីការក្រសួង។ ជាលទ្ធផល ក្រសួងពាក់ព័ន្ធបានផ្តល់មតិយោបល់របស់ខ្លួនលើកិច្ចព្រមព្រៀងខាងលើ និងបានផ្ញើជូនទៅក្រសួងពាក់ព័ន្ធទាំងនោះវិញ ដោយបានដាក់បញ្ចូលមតិយោបល់ដែលទទួលបានពីអង្គប្រជុំទៅក្នុងកិច្ចព្រមព្រៀង មុននឹងបញ្ជូនបន្តទៅភាគីប៊ុលហ្គារី

- ចូលរួមជាមួយថ្នាក់ដឹកនាំក្រសួងក្នុងដំណើរទស្សនកិច្ច និងធ្វើរបាយការណ៍ស្តីពី លទ្ធផលនៃការចូលរួមពិធីសម្ពោធ "ដៃថ្មីនៃព្រែកជីកស៊ុយអេស" ដែលប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ នៅប្រទេសអេហ្ស៊ីប និងផ្ញើជូនខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ តាមរយៈដំណើរទស្សនកិច្ចនេះ គណៈប្រតិភូបានយល់ដឹងអំពីសក្តានុពលសេដ្ឋកិច្ចរបស់អេហ្ស៊ីប ដែលទាញផលប្រយោជន៍ ពីដៃថ្មីនៃព្រែកជីកនេះ
- រៀបចំជំនួបសម្តែងការគួរសម និងចូលរួមពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត Valery Sadokho ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបេឡារុសប្រចាំកម្ពុជា ដែលមាននិវេសនដ្ឋាននៅទីក្រុងហាណូយ
- រៀបចំជំនួបសម្តែងការគួរសម និងចូលរួមពិភាក្សាការងារជាមួយ ឯកឧត្តម Jörg Asmussen រដ្ឋលេខាធិការនៃក្រសួងការងារ និងកិច្ចការសង្គម នៃសហព័ន្ធអាល្លឺម៉ង់
- រៀបចំកិច្ចប្រជុំពិភាក្សាការពារសេចក្តីព្រាងច្បាប់ ស្តីពី "ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស" ជាមួយគណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (គណៈកម្មការទី៩) គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន (គណៈកម្មការទី៨) និងតំណាងគណៈកម្មការផ្សេងទៀត បានប្រព្រឹត្តទៅនៅខែសីហាឆ្នាំ២០១៥ នៅវិមានរដ្ឋសភា។ ជាលទ្ធផលគណៈកម្មការសភា បានផ្តល់នូវការគាំទ្រចំពោះសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ
- រៀបចំជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Eric-Normand THIBEAULT នាយកថ្មីនៃការិយាល័យតំបន់សម្រាប់អាស៊ី-ប៉ាស៊ីហ្វិក (BRAP) នៃអង្គការ OIF
- ជួបពិភាក្សាការងារជាមួយគណៈប្រតិភូកម្មវិធី: ជាលទ្ធផលកម្មវិធី ACT បានស្នើភាគីពាក់ព័ន្ធគាំទ្រលើគំនិតផ្តួចផ្តើមរបស់ខ្លួនដើម្បីធានានិរន្តរភាពឧស្សាហកម្មវិស័យកាត់ដេរនៅកម្ពុជា និងប្រាក់ឈ្នួលដែលអាចទ្រទ្រង់ ដល់ជីវភាពរស់នៅរបស់កម្មករ-និយោជិក និងបានស្នើសុំការគាំទ្រពីក្រសួងពាណិជ្ជកម្មទៅលើគំនិតផ្តួចផ្តើមនេះ
- រៀបចំបង្កើត និងផ្សព្វផ្សាយជូនអន្តរក្រសួងពាក់ព័ន្ធនូវសេចក្តីសម្រេច ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារជាន់ខ្ពស់ដើម្បី ជំរុញគម្រោងវិនិយោគអាទិភាពរួម រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី" ដែលបានចុះហត្ថលេខាជំនួងខ្ពស់ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ និងបានស្នើសុំ upload សេចក្តីសម្រេចនេះទៅក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម
- ចូលរួមក្នុងកិច្ចប្រជុំពិនិត្យលើរបៀបវារៈ ដែលក្នុងនោះមានការពិភាក្សាជាជំហានដំបូងអំពីការរៀបចំរបៀបវារៈកិច្ចប្រជុំ សម្រាប់កិច្ចប្រជុំលើកទី៩ នៃក្រុមការងារកម្ពុជា-សហភាពអឺរ៉ុបស្តីពីពាណិជ្ជកម្ម ជាមួយតំណាងមកពីគណៈប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា និងថៃឡង់ដ៍

- ទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ គណៈប្រតិភូវេទិកាសេដ្ឋកិច្ចពិភពលោក ដែលដឹកនាំដោយលោក Dr. Philipp Rösler ចាប់ពីថ្ងៃទី១៩-២១ ខែតុលា ឆ្នាំ២០១៥ សំដៅស្វែងយល់ពីសក្តានុពលធុរកិច្ច និងវិនិយោគនៅកម្ពុជា និងជំនួបពិភាក្សាការងារជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាពាក់ព័ន្ធនឹងការងារដែលកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះ វេទិកាសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០១៦
- ចូលរួមកិច្ចប្រជុំពិភាក្សាការពារសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី "កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស" ក្នុងសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ នៅវិមានរដ្ឋសភា។ ជាលទ្ធផល អង្គប្រជុំរដ្ឋសភាទាំងមូល បានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុង លើសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ
- ចូលរួមកិច្ចប្រជុំពិភាក្សាការពារសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី "កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស" ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និងមានការអញ្ជើញចូលរួមពីសមាជិកព្រឹទ្ធសភា ចំនួន ៥៨រូប ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នៅព្រឹទ្ធសភា។ ជាលទ្ធផល អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ និងឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែចំនួន ៥៨សម្លេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងអស់
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងអន្តរក្រសួងដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងកម្ពុជា-រុស្ស៊ី និងការកំណត់នូវបណ្តាគម្រោងវិនិយោគអាទិភាពរួមរវាងប្រទេសទាំងពីរ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- សហការរៀបចំសិក្ខាសាលាជាមួយសាធារណរដ្ឋប៉ូឡូញ ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា-ប៉ូឡូញ ដែលរៀបចំឡើងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅរាជធានីភ្នំពេញ
- បាន និងកំពុងសិក្សាស្រាវជ្រាវព័ត៌មានទាក់ទងនឹងសភាពការណ៍ និងវឌ្ឍនភាពវិស័យសេដ្ឋកិច្ចនៅតំបន់អឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក ជាពិសេសវិស័យនិងផលិតផលសក្តានុពលសម្រាប់ការពង្រឹង និងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម
- រៀបចំលក្ខខណ្ឌការងារ (Terms of Reference) ស្តីពីការជំរុញគម្រោងវិនិយោគអាទិភាពរួមរវាងកម្ពុជា-រុស្ស៊ី និងបានរៀបចំកិច្ចប្រជុំនេះនៅទីស្តីការក្រសួង
- សហការរៀបចំ និងទទួលបដិសណ្ឋារកិច្ចចំពោះដំណើរទស្សនកិច្ច
- ផ្លូវការរបស់នាយករដ្ឋមន្ត្រីរុស្ស៊ី បានអញ្ជើញមកកម្ពុជាចាប់ពីថ្ងៃទី២៣-២៤ ខែវិច្ឆិកា ឆ្នាំ២០១៥។

## ២.៨ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មជាមួយទ្វីបអាមេរិក

- សម្របសម្រួលបេសកកម្មវិនិយោគពាណិជ្ជកម្មកាណាដា-កម្ពុជា៖
  - សម្របសម្រួលរៀបចំ នូវការពន្យល់សង្ខេបស្តីពីបរិយាកាសធុរកិច្ចកម្ពុជា ជូនដល់អ្នកវិនិយោគទុន និងធុរកិច្ចកាណាដាចំនួន ៧ នៅក្នុងនោះមានក្រុមហ៊ុន Clear Blue, BeeDoo,

C-Comsat, Jaylor Canada, Mchalnney, Lucky Iron Fish, and Trade Facilitation Office នៅព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ នៅសណ្ឋាគារ Raffles Hotel Le Royal ក្រោមអធិបតីភាពផ្ទេរលេខាធិការក្រសួងពាណិជ្ជកម្ម និងឯកឧត្តម Philip Calvert ឯកអគ្គរាជទូតកាណាដាប្រចាំកម្ពុជា ដែលមាននិវាសនដ្ឋាននៅទីក្រុងបាងកក ប្រទេសថៃ។ វាគ្មិនអញ្ជើញចូលរួមផ្តល់បទបង្ហាញរួមមាន៖ **ឯកឧត្តម សុខ ស៊ីផាន់ណា** ទីប្រឹក្សារបស់រាជរដ្ឋាភិបាលកម្ពុជា, លោក Julian Clarke មន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់មកពីធនាគារពិភពលោកប្រចាំនៅកម្ពុជា, លោក Martin Desautels, Regional Managing Partner, DFDL -Legal

- នៅល្ងាចថ្ងៃដដែល (ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥) ក្រសួងបានសហការជាមួយស្ថានទូតកាណាដាប្រចាំនៅកម្ពុជា ដែលមាននិវាសនដ្ឋាននៅទីក្រុងបាងកក បានរៀបចំពិធីលាងសាយភោជន៍មួយ ធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយពាណិជ្ជករកាណាដា-កម្ពុជា ដែលមានអ្នកចូលរួមចំនួនសរុប ១១២នាក់
- ថ្ងៃបន្ទាប់ (ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥) បានអញ្ជើញក្រុមហ៊ុនកម្ពុជាមួយចំនួន ជួបផ្លាស់ប្តូរព័ត៌មាន និងចាប់ដៃគ្នា ដើម្បីធ្វើជំនួញជាមួយគ្នា។ ក្រុមហ៊ុនកម្ពុជាចំនួន ៣៦ ក្រុមហ៊ុនបានជួបផ្លាស់ប្តូរព័ត៌មានជាមួយក្រុមហ៊ុនកាណាដា។

*ជាលទ្ធផល៖*

- បន្ទាប់ពីបេសកកម្មចុងក្រោយរបស់ប្រតិភូធុរកិច្ចកាណាដា ដែលដឹកនាំដោយ ឯកឧត្តមអគ្គរាជទូតកាណាដា ដែលមានទីតាំងនៅទីក្រុងបាងកក កាលពីចុងខែមករា ឆ្នាំ២០១៥ ក្រុមហ៊ុន JAYLOR បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយលើ "Dealer Agreement" ជាមួយក្រុមហ៊ុនមួយរបស់កម្ពុជា ដែលមានទឹកប្រាក់ប្រមាណជា $45,000
- ក្រុមហ៊ុន BeeDoo បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន EZECOM របស់កម្ពុជា កាលពីខែសីហា ឆ្នាំ២០១៥។ ជាមួយនឹងការចុះកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនទាំងពីរខាងលើ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ បានចាប់ផ្តើមដំណើរការសេវាកម្ម Cloud ដំបូង និងថ្មីបំផុតរបស់ខ្លួនឈ្មោះថា "BeeDoo" ដោយសេវានេះ និងអនុញ្ញាតឲ្យអ្នកប្រើប្រាស់រក្សាទុកទិន្នន័យលើអ៊ីនធឺណិត ចែករំលែកឯកសារ និងផ្តល់ដំណោះស្រាយក្នុងការធ្វើសារអេឡិចត្រូនិក។

- **ផ្សព្វផ្សាយពីលក្ខខណ្ឌនានា ដើម្បីនាំទំនិញកម្ពុជាទៅកាន់ទីផ្សារកាណាដា៖**
  - ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ក្រសួងពាណិជ្ជកម្ម បានសហការជាមួយការិយាល័យកិច្ចសម្រួលពាណិជ្ជកម្មកាណាដា (TFO) បានរៀបចំសិក្ខាសាលា ស្តីពី "ការនាំចេញទៅកាណាដា" គាំទ្រហិរញ្ញប្បទានដោយរដ្ឋាភិបាលកាណាដានៅសណ្ឋាគារ Raffles Hotel Le Royal ជូនដល់សហគ្រាសធុនតូច និងមធ្យម (SMEs) ដែលមានអ្នកចូលរួមសរុប ៥២នាក់។ ជាលទ្ធផល៖ ក្រុមហ៊ុន Woman for woman foundation Cambodia បានចុះឈ្មោះរបស់ខ្លួនចូលទៅក្នុងគេហទំព័ររបស់ TFO Canada ប្រយោជន៍ស្វែងរកអ្នកបញ្ជាទិញផ្ទាល់ពីក្រុមហ៊ុនកាណាដា (http://www.tfocanada.ca/supply.php?searchtype=2&indgroup=&supplycount=Cambodia&search=Search)

- នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រសួងពាណិជ្ជកម្ម បានសហការជាមួយការិយាល័យកិច្ចសម្រួលពាណិជ្ជកម្មកាណាដា បានរៀបចំសិក្ខាសាលាស្តីពី "ការនាំចេញទៅកាណាដា" គាំទ្រហិរញ្ញប្បទានដោយរដ្ឋាភិបាលកាណាដា នៅសណ្ឋាគារ ៧ មករា ខេត្តកំពង់ចាម ជូនដល់សហគ្រាសធុនតូច និងមធ្យម (SMEs) និងមន្ត្រីមន្ទីរពាណិជ្ជកម្ម កសិកម្ម ឧស្សាហកម្ម និងកិច្ចការនារី ខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុប ៥០នាក់
- យោងតាមមតិសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលបានអញ្ជើញចូលរួមបានលើកឡើងថា៖ ព័ត៌មានដែលបានផ្តល់ជូនតាមរយៈ សិក្ខាសាលាមានសារៈសំខាន់ ដល់ការនាំចេញរបស់ក្រុមហ៊ុន របស់ខ្លួន ហើយមានបំណងចង់បានព័ត៌មានបន្ថែម ស្តីពីការសិក្សាស្រាវជ្រាវ និងចុះឈ្មោះក្រុមហ៊ុនរបស់ពួកគេទៅក្នុងគេហទំព័រ www.tfocanada.ca របស់ការិយាល័យកិច្ចសម្រួលពាណិជ្ជកម្មកាណាដា (TFO) ជាបន្ទាន់។ ជារួមយើងឃើញថា ការចូលរួមរបស់សិក្ខាកាម សិក្ខាសាលាទាំងពីរខាងលើ គឺបានផ្តល់នូវព័ត៌មានថ្មី អំពីតម្រូវការផលិតផលរបស់កម្ពុជា នាំទៅប្រទេសកាណាដា ដែលសំខាន់ទាក់ទងទៅនឹងវិស័យផលិតផលចំណីអាហាររបស់សហគ្រាសខ្នាតធុនតូច និងមធ្យម (SMEs) នៅកម្ពុជា។

- **កិច្ចព្រមព្រៀងជាមួយការិយាល័យកិច្ចសម្រួលពាណិជ្ជកម្ម (2014-2018)**

ក្រៅពីនេះក្រោយបានចុះកិច្ចព្រមព្រៀងជាមួយ TFO ដែលក្នុងនោះរួមមានការទទួលបានការផ្តល់នូវសេវាកម្មបី រួមមាន៖

- ផ្សព្វផ្សាយផលិតផលកម្ពុជាតាមរយៈគេហទំព័រកាណាដាឈ្មោះ www.tfocanada.ca
- សេវាកម្មឆ្លើយតបរហ័ស
- សេវាកម្មការសិក្សាចូលទីផ្សារកាណាដា

ក្នុងសេវាកម្មនៃកិច្ចព្រមព្រៀងទាំងបីខាងលើនេះ មន្ត្រីរបស់ក្រសួង កន្លងមកធ្វើការទៅលើកិច្ចព្រមព្រៀងនៃសេវាកម្មទី១ ដោយបានទំនាក់ទំនងជាមួយក្រុមហ៊ុនមួយចំនួន ដើម្បីសុំឲ្យធ្វើការផ្សព្វផ្សាយផលិតផលរបស់ខ្លួននៅក្នុងគេហទំព័រនៃ TFO នោះ។ តែមកដល់ពេលនេះមិនទាន់មានក្រុមហ៊ុនណា មួយមកទំនាក់ទំនងដើម្បីធ្វើការផ្សព្វផ្សាយនៅឡើយទេ។ ចំពោះសេវាកម្មទី២ ក្រសួងផ្សព្វផ្សាយស្វែងរកក្រុមហ៊ុន ទៅធ្វើការតាំងពិព័រណ៍នៅក្នុងប្រទេសកាណាដា នៅក្នុងព្រឹត្តិការណ៍ SIAL Canada Trade Show 2016 ដែលប្រព្រឹត្តទៅនៅទីក្រុង ម៉ុងត្រេអាល់ តែមិនមានក្រុមហ៊ុនណាមួយចាប់អារម្ម ណ៍នឹងព្រឹត្តិការណ៍នោះឡើយ។

- **ស្រាវជ្រាវ និងលក្ខខណ្ឌសម្រាប់នាំផលិតផលកម្ពុជាទៅទីផ្សារកាណាដា**
  - កំណត់នូវវិស័យអាទិភាព ស្របតាមឯកសារយុទ្ធសាស្ត្រសមាហរណកម្មកម្ពុជា ២០១៤-២០១៨ ដែលក្នុងនោះរួមមាន៖ វិស័យស្រូវអង្ករ វិស័យកែច្នៃម្ហូបអាហារ នំស្រួយធ្វើពីអង្ករ, ផលិតផលផ្លែឈើ, ទឹកស៊ីអ៊ីវ និងផលិតផលកៅស៊ូ
  - សិក្សាស្រាវជ្រាវលក្ខខណ្ឌ សម្រាប់នាំចេញទំនិញទៅកាណាដា នឹងត្រូវបញ្ចប់នៅក្នុងដំណាច់ឆ្នាំ២០១៥នេះ និងដាក់ជូនថ្នាក់ដឹកនាំសម្រេច ដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយ
  - កែសម្រួល និងរៀបចំឯកសារជំនួយស្មារតី ទាក់ទងនឹងសហរដ្ឋអាមេរិក
  - តាមដាន និងស្រាវជ្រាវឯកសារ ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងក្របខ័ណ្ឌវិនិយោគរវាងកម្ពុជា-សហរដ្ឋអាមេរិក (TIFA) ដែលបានបង្កើតឡើងតាំងពីថ្ងៃទី១៤

ខែកក្កដា ឆ្នាំ២០០៦ និងបានរៀបចំកិច្ចប្រជុំលើកទី១ នាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ នៅខេត្តសៀមរាប។ ចាប់តាំងពីពេលនោះមក មិនមានកិច្ចប្រជុំណាមួយឡើយ។ រហូតមកដល់ឆ្នាំ២០១៥ នេះ ទើបភាគីសហរដ្ឋអាមេរិក ស្នើសុំឲ្យមានកិច្ចប្រជុំពិភាក្សា ស្តីពីកិច្ចព្រមព្រៀងខាងលើនេះឡើងវិញ

- ស្រាវជ្រាវឯកសារអំពីច្បាប់ស្តីពី GSP ថ្មី របស់សហរដ្ឋអាមេរិក ដើម្បីផ្សព្វផ្សាយ និងពន្យល់ដល់ភាគី GMAC អំពីការដាក់ញត្តិស្នើសុំ GSP លើជំពូកទំនិញ ៤២០២ "Traveler Goods" ដែលប្រធានាធិបតី លោក បារ៉ាក់ អូបាម៉ា ទើបតែចុះហត្ថលេខា ឲ្យក្លាយជាច្បាប់កាលពីខែមិថុនា ឆ្នាំ២០១៥ (ឧ.ច្បាប់ស្តីពី Trade Promotion Authority និង Trade Adjustment Assistances ) បន្ទាប់ពីសភាជាន់ខ្ពស់សហរដ្ឋអាមេរិកអនុម័ត រួមទាំងពង្រាងអត្ថបទចុះផ្សាយក្នុងសារព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម
- ស្រាវជ្រាវឯកសារជំនួយស្មារតី បណ្តាប្រទេសនៅទ្វីបអាមេរិកខាងត្បូង ដែលមានទំនាក់ទំនងការទូត និងពាណិជ្ជកម្ម ជាមួយប្រទេសកម្ពុជា ។

- ការងារកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម

 រៀបចំសេចក្តីព្រាងជំនួយស្មារតីជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មជួបជាមួយឯកអគ្គរដ្ឋទូតនានាដូចជា៖

- ជួបពិភាក្សាការងារជាមួយ ឯកឧត្តម Donald Bobiash ឯកអគ្គរាជទូតកាណាដាប្រចាំអាស៊ាន ឥណ្ឌូណេស៊ី និងទីម័រខាងកើត និង ឯកឧត្តម Philip Calvert ឯកអគ្គរាជទូតកាណាដាប្រចាំកម្ពុជា ដែលមាននិវាសនដ្ឋាន នៅទីក្រុងបាងកក កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- ជួបពិភាក្សាការងារជាមួយ ឯកឧត្តម Kurt TONG ឧបការីរងទទួលបន្ទុកកិច្ចការធុរកិច្ច និងសេដ្ឋកិច្ចរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក និងឯកឧត្តម William E. TODD ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- ជួបពិភាក្សាការងារជាមួយ ឯកឧត្តម Peter MacArthur អគ្គនាយកពាណិជ្ជកម្ម និងការទូតរបស់កាណាដាប្រចាំតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- បន្តធ្វើការងារជំរុញពាណិជ្ជកម្មទ្វេភាគី ជាមួយកាណាដា តាមរយៈការិយាល័យកិច្ចសម្រួលពាណិជ្ជកម្មកាណាដាដូចជា៖ ផ្តល់ព័ត៌មានពីព្រឹត្តិការណ៍ពាណិជ្ជកម្មនៅកម្ពុជា ការត្រៀមចុះហត្ថលេខាលើ ឯកសារជួយស្រាវជ្រាវផលិតផល ដែលមានសក្តានុពលរបស់កម្ពុជាសម្រាប់នាំចេញទៅកាន់ទីផ្សារកាណាដា និងបេសកកម្មពាណិជ្ជកម្មកម្ពុជានិងកាណាដា
- សហការជាមួយ មន្ត្រីស្ថានទូតកាណាដាពិភាក្សាការងារ ស្តីពីការជួយកសាងសមត្ថភាពដល់មន្ត្រីនាយកដ្ឋានអាមេរិក និងការជួយភ្ជាប់ទំនាក់ទំនង ក្រុមហ៊ុនផ្គត់ផ្គង់កម្ពុជាឲ្យដល់ក្រុមហ៊ុនទទួលទិញរបស់កាណាដា
- ចូលរួមវេទិកាធុរកិច្ច កាណាដា-អាស៊ានលើកទី២ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី១៨-១៩ ខែមីនា ឆ្នាំ២០១៥ នៅទីក្រុងបាងកក ប្រទេសថៃ

- ធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុន CANATEXC ENGINEERING & CONSTRUCTION COMPANY LIMITED/DBD Engineering & Construction Co., Ltd/BKEC Co., ltd. ជាមួយលោក ម៉ែន ប៊ុនទៀង មន្ត្រីសម្របសម្រួលពាណិជ្ជកម្មរបស់ស្ថានទូតកាណាដា ជួបពិភាក្សាជាមួយលោក Anthony Watanabe នាយកក្រុមហ៊ុន "Clear Blue" ប្រចាំតំបន់អាស៊ីអាគ្នេយ៍
- ការងារជំរុញពាណិជ្ជកម្មទ្វេភាគី ជាមួយកាណាដា តាមរយៈការិយាល័យកិច្ចសម្រួលពាណិជ្ជកម្មកាណាដា(TFO)ដូចជា៖ ផ្តល់ព័ត៌មានពីព្រឹត្តិការណ៍ពាណិជ្ជកម្មកម្ពុជា ការត្រៀមចុះហត្ថលេខាលើ ឯកសារស្រាវជ្រាវផលិតផលសក្តានុពលកម្ពុជា សម្រាប់ទីផ្សារកាណាដា
- កាលពីថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ២០១៥ បានសម្របសម្រួលដំណើរទស្សនៈកិច្ចរបស់ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន មកកម្ពុជា និងបានរៀបចំកិច្ចប្រជុំរវាងក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន ដែលដឹកនាំគណៈប្រតិភូដោយ លោកស្រី Kathleen T. Santilo នាយកគ្រប់គ្រង នៅទីស្តីការក្រសួងពាណិជ្ជកម្ម នាសាលប្រជុំអង្គរវត្ត និង**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** នៅវិមានសន្តិភាព ព្រមទាំងបានសម្របសម្រួលឲ្យមានជំនួបជាមួយរដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួនផងដែរ
- ធ្វើការទំនាក់ទំនងជាមួយ លោក Joe Rouseជាតម្រោងថៃនូរបស់ក្រុមហ៊ុន get2volume កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ កន្លងទៅនេះ
- កាលពីថ្ងៃទី១១-១៥ ខែឧសភា ឆ្នាំ២០១៥ គណៈប្រតិភូក្រសួងពាណិជ្ជកម្ម និងលោក William E.Todd ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ទៅបំពេញបេសកកម្មជំរុញវិនិយោគនិងធុរកិច្ច នៅទីក្រុង San Francisco រដ្ឋ California ទីក្រុង Atlanta រដ្ឋ Georgia និងទីក្រុង Washington D.C សហរដ្ឋអាមេរិក ដោយមានគណៈប្រតិភូធុរកិច្ចកម្ពុជាចំនួន ២៨ក្រុមហ៊ុនចូលរួមផងដែរ
- បន្ទាប់ពីដំណើរទស្សនកិច្ចនេះបានបញ្ចប់ ភាគីសហរដ្ឋអាមេរិកបានអញ្ជើញកម្ពុជា បង្កើតក្រុមការងារជាន់ខ្ពស់ជំនាញសេដ្ឋកិច្ច ដើម្បីសន្ទនាគោលនយោបាយសេដ្ឋកិច្ច។ ក្រុមការងារជាន់ខ្ពស់នេះ កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ កន្លងទៅនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត និងចុះហត្ថលេខា រួចរាល់ហើយ ដែលមានសមាជិកសរុបចំនួន១០រូបហៅថា៖ "ក្រុមការងារជាន់ខ្ពស់សម្រាប់កិច្ចសន្ទនាអំពីភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ចរវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក"
- កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ បានធ្វើកិច្ចសម្របសម្រួលរវាងក្រុមហ៊ុន Five Star Enterprise ជួបជាមួយសមាគមអ្នកកាត់ដេរនៅកម្ពុជា ដើម្បីស្វែងរកអ្នកផ្គត់ផ្គង់សម្លៀកបំពាក់ពេទ្យសម្រាប់នាំចេញទៅកាណាដា
- ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ជំនួបប្រជុំការងារជាមួយលោក ដេវីដ មេយើរ៍ អនុប្រធានផ្នែកនយោបាយនិងសេដ្ឋកិច្ច ស្ថានទូតអាមេរិកប្រចាំប្រទេសកម្ពុជា
- ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ផ្តល់ Contract Information របស់ក្រុមហ៊ុន WEI HUA GARMENT Co., Ltd. ជូនលោក ម៉ែន ប៊ុនទៀង ទីប្រឹក្សាពាណិជ្ជកម្មរបស់ស្ថានទូតកាណាដា និងភ្នាក់ងារសេវាកម្មព្រំដែនកាណាដា (CBSA)
- ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ជ្រើសរើសក្រុមហ៊ុន Food Products Processing ដើម្បីជួយឲ្យ ក្រុមហ៊ុនទាំងនោះអាចចូលរួមក្នុងកម្មវិធី Webinar ស្តីពី "Grocery Innovation Canada -

An Entry into Canada Grocery Market" ដែលធ្វើនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោង ១២:០០ -០១:០០ រសៀល នៅអូតាវ៉ា ប្រទេសកាណាដា

- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ បញ្ជាប់ទម្រង់គំរូ ចុះបញ្ជីអ្នកចូលរួមសិក្ខាសាលាដែលមាន (ទម្រង់គំរូ) សម្រាប់ក្រុមហ៊ុនបំពេញព័ត៌មាន
- ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ស្តីពីការទាមទារអត្ថប្រយោជន៍នៃ GSPថ្មី របស់សហរដ្ឋអាមេរិក ដល់ប្រទេសកម្ពុជា
- ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ អ៊ីម៉ែលទំនាក់ទំនងជាមួយមន្ត្រីការិយាល័យសម្រួលពាណិជ្ជកម្មកាណាដា (TFO Canada) ដើម្បីសុំព័ត៌មានអំពីតម្លៃតូប (Booth Cost) សម្រាប់សហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា ធ្វើការពិនិត្យនូវលទ្ធភាពរបស់ខ្លួន ក្នុងការចូលរួម "SIAL Canada Trade Show 2016"
- ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥ ផ្តល់ព័ត៌មានអំពីតម្លៃតូប (Booth Cost) "SIAL Canada Trade Show 2016" ទៅឲ្យនាយកដ្ឋានព័ត៌មានពាណិជ្ជកម្ម ដើម្បីផ្តល់ព័ត៌មានបន្តទៅដល់សហគ្រាសធុនតូច និងមធ្យមកម្ពុជា
- ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ជ្រើសរើសក្រុមហ៊ុន សហគ្រាស សិប្បកម្ម ដើម្បីអញ្ជើញចូលរួមក្នុងការធ្វើបទបង្ហាញស្តីពី "ការចុះឈ្មោះក្នុងគេហទំព័រ www.tfocanada.ca របស់ការិយាល័យសម្រួលពាណិជ្ជកម្មកាណាដា" ដែលធ្វើនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥
- ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ជំនួបប្រជុំការងារជាមួយលោកស្រី Margaret Hsiang តំណាងស្ថានទូតអាមេរិកប្រចាំកម្ពុជា នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- ចុះប្រមូលព័ត៌មានអំពីទំនិញ ពីបណ្តាក្រុមហ៊ុនដែលផលិតសំលៀកបំពាក់ទារក (Baby wears) បានចំនួន ០៤ ក្រុមហ៊ុន ជូនស្ថានទូតកាណាដា តាមរយៈ លោក ម៉ែន ប៊ុនឡេង មន្ត្រីសម្របសម្រួលពាណិជ្ជកម្មរបស់ស្ថានទូតកាណាដា។ ជាមួយនេះដែរ បានជួបពិភាក្សាការងារ និងផ្សព្វផ្សាយ i.Profile និងគោលនយោបាយវិនិយោគកម្ពុជា ទៅដល់ Vriens Partner (ក្រុមហ៊ុនប្រឹក្សាយោបល់) មកពីប្រទេសសិង្ហបុរី កាលពីថ្ងៃទី២៨ ខែតុលាឆ្នាំ២០១៥
- នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ចូលរួមដំណើរទស្សនកិច្ចចរចារទ្វេភាគីជាមួយសហរដ្ឋអាមេរិក ជាប្រធានក្រុមចរចាជាន់ខ្ពស់ ព្រមទាំងមានការចូលរួមពី ឯកឧត្តម លោក ដែលជាសមាជិកនៃក្រុមចរចាកម្ពុជានៅទីក្រុង Washington, D.C. U.S.A។

## ២.៥ ការងារសមាហរណកម្មសាកល

- ពិនិត្យ និងប្រមូលឯកសារ ស្តីពីអនាម័យ និងភូតគាមអនាម័យ (Sanitary and Phyto-sanitary, SPS) ដោយសហការជាមួយមន្ត្រីជំនាញនៃក្រសួង/ស្ថាប័នពាក់ព័ន្ធនឹងការងារ SPS ដើម្បីរៀបចំធ្វើសេចក្តីផ្តល់ព័ត៌មានទៅការិយាល័យចុះបញ្ជីកណ្តាល (Central Registration of Notification, CRN) នៃលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក
- ត្រៀមលក្ខណៈធ្វើការផ្តល់ព័ត៌មាន ស្តីពីការផ្តល់សច្ចាប័នរបស់ស្ថាប័ននីតិបញ្ញត្តិ លើពិធីសារសម្រាប់ធ្វើវិសោធនកម្មដាក់បញ្ចូលកិច្ចព្រមព្រៀង ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មទៅក្នុងឧបសម្ព័ន្ធ "១ក" នៃកិច្ចព្រមព្រៀងស្តីពីអង្គការពាណិជ្ជកម្មពិភពលោក ទៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក

- កំពុងរៀបចំបញ្ជូនសេចក្តីផ្តល់ព័ត៌មាន ស្តីពីកម្មសិទ្ធិបញ្ញាទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបញ្ជូនបន្តទៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក
- បិតបញ្ចប់ការកែសម្រួលអត្ថបទនៃ សេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្មជាភាសាខ្មែរដែលបានបកប្រែដោយក្រុមហ៊ុនឯកជនផ្តល់ដោយអង្គការ USAID។ ការត្រួតពិនិត្យឡើងវិញនេះមានការលំបាកយ៉ាងខ្លាំងដោយសារមានកំហុសច្រើនផ្នែកខ្លឹមសារនៅក្នុងការបកប្រែ ព្រមទាំងកំហុសអក្ខរាវិរុទ្ធ និងមានភាពមិនដូចគ្នានៅក្នុងការបកប្រែពាក្យអង់គ្លេស មកជាភាសាខ្មែរដោយប្រើពាក្យពេចន៍ផ្សេងៗ គ្នា
- ចូលរួម និងផ្តល់យោបល់ក្នុងសិក្ខាសាលា ស្តីពី "ច្បាប់ និងគោលនយោបាយប្រកួតប្រជែង" ដែលរៀបចំដោយក្រសួងពាណិជ្ជកម្មដែលប្រព្រឹត្តទៅនាខែមករា ឆ្នាំ២០១៥
- បន្តចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី "ច្បាប់ឧបាស្រ័យពាណិជ្ជកម្មក្នុងក្របខណ្ឌអាស៊ាន+6"
- បន្តធ្វើបច្ចុប្បន្នភាព និងជំរុញអន្តរក្រសួង-ស្ថាប័ន ឲ្យអនុវត្តកម្មវិធីការងារ WTO របស់រាជរដ្ឋាភិបាលកម្ពុជា ផ្អែកលើការតម្រូវរបស់ អង្គការពាណិជ្ជកម្មពិភពលោក និងស្របតាមអនុសាសន៍ដែលទទួលបាននៅក្នុងការត្រួតពិនិត្យ គោលនយោបាយពាណិជ្ជកម្មរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោកនៅវិច្ឆិកា ឆ្នាំ២០១១ ដែលបានទទួលការឯកភាពពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១២ និងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៧៧២ សជណ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២។ បច្ចុប្បន្នភាពថ្មីបំផុតនៃកម្មវិធីការងារ WTO របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានធ្វើឡើងនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ហើយឯកសារបច្ចុប្បន្នភាពនេះត្រូវបានដាក់ជូនកិច្ចប្រជុំក្រុមការងារនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច(ក្រុម ឃ) នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- បន្តតាមដានការវិវត្តន៍នៃការចរចា និងការអនុវត្តកញ្ចប់បាលីដែលសម្រេចដោយ រដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេស ការងារពាក់ព័ន្ធនឹងការមិនយកពន្ធ និងមិនដាក់កូតា (Duty Free Quota Free) កិច្ចសម្រួលពាណិជ្ជកម្ម វិធានប្រភពដើមទំនិញ ដែលសុទ្ធតែជាវិស័យដែលមានសារៈសំខាន់ និងមានអត្ថប្រយោជន៍ចំពោះកម្ពុជា
- រៀបចំអត្ថបទ ស្តីពីកិច្ចសហប្រតិបត្តិការនៅក្រោមអង្គការពាណិជ្ជកម្មពិភពលោក សម្រាប់កិច្ចប្រជុំលើកទី១របស់គណៈកម្មាធិការចម្រុះកម្ពុជា-ទួរគី
- ទំនាក់ទំនង និងផ្តល់ព័ត៌មានជូនស្ថានទូតអូស្ត្រាលីពាក់ព័ន្ធនឹងដំណើរការនៃការផ្តល់សច្ចាប័នលើពិធីសារ ស្តីពី "វិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក"
- ចូលរួមកិច្ចប្រជុំតុមូល រៀបចំឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស
- ជួបពិភាក្សា និងដោះដូរយោបល់ជាមួយលេខាទីមួយស្ថានទូតជប៉ុន ប្រចាំនៅកម្ពុជា អំពីដំណើរការនៃការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ដោយក្នុងនោះភាគីជប៉ុនបានស្នើសុំឲ្យកម្ពុជាពិចារណាផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងខាងលើក្នុងពេលសមស្របណាមួយ
- បាន និងកំពុងតាមដានការវិវត្តនៃការចរចាក្នុងក្របខណ្ឌ អង្គការពាណិជ្ជកម្មពិភពលោក ក្នុងជំហានឆ្ពោះទៅរកសន្និសីទលើកទី១០នៃរដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោក ដែលគ្រោងធ្វើនៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា នាពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៥ នេះ
- រៀបចំលិខិតស្នើសុំគោលការណ៍ ដើម្បីអនុម័តលើសមាសភាពមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាទៅចូលរួមសន្និសីទ រដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោកលើកទី១០ នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា

- រៀបចំលិខិតទៅ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្នើសុំចាត់តាំងសមាសភាពមន្ត្រីទៅចូលរួមសន្និសីទរដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោកលើកទី១០ នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា
- រៀបចំលិខិតទៅ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្នើសុំជួយអន្តរាគមន៍ទៅស្ថានបេសកកម្មអចិន្ត្រៃយ៍របស់កម្ពុជាប្រចាំនៅហ្សឺណែវ ដើម្បីផ្តល់ព័ត៌មានជាផ្លូវការទៅ អង្គការពាណិជ្ជកម្មពិភពលោក អំពីសមាសភាពគណៈប្រតិភូកម្ពុជាដែលត្រូវទៅចូលរួមកិច្ចប្រជុំតុមូល Fourth China Round Table on WTO Accession និងចូលរួមសន្និសីទរដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោកលើកទី១០ ដែលនឹងប្រព្រឹត្តទៅនៅខែធ្នូ នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា
- ពិនិត្យ និងស្រាវជ្រាវឯកសារបន្ថែមដើម្បីផ្តល់យោបល់លើលិខិតចំនួន ៣ ដូចជា៖ ១.លិខិតរបស់ Mr. Roberto Azevedo អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ស្តីពីការផ្តល់សច្ចាប័នលើ ពិធីសារនៃកិច្ចព្រមព្រៀងសម្រួលពាណិជ្ជកម្ម (Ratification of the Trade Facilitation Agreement Protocol), ២. លិខិតរបស់ WTO ជូនដំណឹងអំពីការផ្តល់លក្ខខណ្ឌអនុគ្រោះរបស់សាធារណរដ្ឋកូរ៉េចំពោះវិស័យសេវាកម្ម និងការផ្តល់ភាពអនុគ្រោះសម្រាប់វិស័យសេវាកម្មដល់ប្រទេសអភិវឌ្ឍន៍តិចតួចបំផុត, និង ៣. លិខិតរបស់ WTO ស្តីពីការរំលឹកកាតព្វកិច្ចជូនដំណឹងរបស់កម្ពុជាក្នុងវិស័យកសិកម្ម សេវាកម្ម កម្មសិទ្ធិបញ្ញា ការបើកទីផ្សារ វិនិយោគ និងវិធានការទាក់ទងនឹងការលក់បង្ខូចថ្លៃ និងឧបត្ថម្ភធន
- រៀបចំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័នចំនួនបីលើក ដើម្បីត្រៀមសម្រាប់សន្និសីទរដ្ឋមន្ត្រីលើកទី១០នៃអង្គការពាណិជ្ជកម្មពិភពលោកដែលគ្រោងនឹងធ្វើនៅខែធ្នូ ឆ្នាំ២០១៥ ប្រទេសកេនយ៉ា នាពេលខាងមុខៗ ខ្លឹមសារសំខាន់គឺ ពិភាក្សាអំពីជំហររបស់កម្ពុជាក្នុងការកំណត់ប្រភេទបញ្ញត្តិ ក ខ និង គ សម្រាប់អនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មនៃអង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំឯកសារជំនួយស្មារតីសម្រាប់ជំនួបរវាង ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាមួយភារៈធារីនៃសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា ស្តីពីដំណើរការនៃការរៀបចំ សម្រាប់ការផ្តល់សច្ចាប័នលើពិធីសារ ស្តីពីកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្មរបស់កម្ពុជា
- ខិតខំប្រឹងប្រែងកែសម្រួលអត្ថបទជាភាសាខ្មែរ នៃពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក និងឧបសម្ព័ន្ធនៃពិធីសារនេះ (កិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម របស់អង្គការពាណិជ្ជកម្មពិភពលោក) ដើម្បីផ្ញើជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងស្នើសុំដាក់ចូលជារបៀបវារៈនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីអនុម័ត និងបញ្ជូនទៅរដ្ឋសភាសុំការផ្តល់សច្ចាប័ន
- រៀបចំសេចក្តីថ្លែងហេតុនៃពិធីសារ សម្រាប់ធ្វើវិសោធនកម្ម កិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក និងបានពិភាក្សាជាមួយក្រុមប្រឹក្សាអ្នកច្បាប់អំពីសេចក្តីព្រាងនោះ ដើម្បីដាក់ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះហត្ថលេខាស្នើសុំទៅរដ្ឋសភាដើម្បីផ្តល់សច្ចាប័ន
- រៀបចំលិខិតទៅ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើសុំកិច្ចសហការក្នុងការចូលរួមការពារពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកនៅរដ្ឋសភា

- ចូលរួមផ្តល់មតិលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងស្រវឹង ដែលព្រាងដោយក្រសួងសុខាភិបាល និងបានចូលរួមក្នុងកិច្ចប្រជុំរវាង ឯកឧត្តមទេសរដ្ឋមន្ត្រី ជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្តីពីសេចក្តីព្រាងច្បាប់ខាងលើ ដើម្បីធានាថាច្បាប់ថ្មីនោះស្របតាមបទដ្ឋាន និងការកំណត់ទាំងឡាយនៅក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក
- រៀបចំលិខិតទៅ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្នើសុំចាត់បញ្ជូនមន្ត្រីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីចូលរួមជាមួយមន្ត្រីក្រសួងពាណិជ្ជកម្ម ការពារឯកសារសម្រាប់ការផ្តល់សច្ចាប័នលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេស ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥
- ចូលរួមសម្របសម្រួលការងារ សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម នៅក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន និងដៃគូពិភាក្សា
- បន្តតាមដានការវិវត្តន៍ថ្មីៗ នៃការចរចាសេវាកម្មក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក
- ស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងការចរចាសេវាកម្មតាមគេហទំព័ររបស់ WTO និងអាស៊ាន
- រួមជាមួយក្រុមការងារមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា ចូលរួមប្រជុំក្រុមការងារក្របខណ្ឌគុណវុឌ្ឍិអាស៊ាន ដើម្បីសម្រួលឲ្យមានលំហូរដោយសេរីនូវកម្លាំងពលកម្មក្នុងប្រទេសអាស៊ាន ស្របតាមគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។

## ២.១០ ការងារសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងជំនួយ

### ២.១០.១ ការអនុវត្តអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម

- ក្នុងឆ្នាំ ២០១៥ ក្រសួងបានរៀបចំកិច្ចប្រជុំអនុគណៈកម្មការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម SSC-TD-TRI (Sub-Steering Committee on Trade Development and Trade Related Investment) ចំនួន ៤ លើក (សូមពិនិត្យរបាយការណ៍នៃកិច្ចប្រជុំនីមួយៗ)
- ក្នុងឆ្នាំ ២០១៥ ក្រសួងបានរៀបចំកិច្ចប្រជុំគណៈកម្មការអនុវត្តគម្រោង IC (Implemntation Committee) ចំនួន៥ លើក (សូមពិនិត្យរបាយការណ៍នៃកិច្ចប្រជុំនីមួយៗ)
- ក្រសួងពាណិជ្ជកម្ម (i) បានធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិលើការអនុវត្ត CTIS 2014-2018, (ii) បានកំណត់បញ្ជីនៃកន្សោមអាទិភាពចំនួន ១០ដែលត្រូវការ ការជំនួយបច្ចេកទេស និង (iii)បានចាប់ផ្តើមរៀបចំផែនការរយៈពេលមធ្យម សម្រាប់កៀងគរជំនួយ ពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ2016-2020 ។

### ២.១០.២ ការអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម

- កម្មវិធីគាំទ្រការអភិវឌ្ឍវិស័យពាណិជ្ជកម្ម (TDSP) ចាប់ផ្តើមថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០០៩ ហើយបានបន្តចំនួន ៣លើក ដែលលើកចុងក្រោយនេះគឺនឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៦។ TDSP គឺគាំទ្រមូលនិធិពហុម្ចាស់ជំនួយ មានសហគមន៍អឺរ៉ុប អង្គការ UNIDO និង DANIDA ដែលមានអ្នកចាត់ចែងមូលនិធិដោយធនាគារពិភពលោក(WB)។ គិតចាប់ពីពេលអនុវត្តន៍កម្មវិធីដំបូង ពីឆ្នាំ២០០៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ នេះក្រសួងបានធ្វើការចំណាយថវិកាសរុបចំនួន $11,802,418 ស្មើនឹង 76.4% នៃចំនួនថវិកាសរុបរបស់កម្មវិធី ($15,450,000)
- កម្មវិធីនេះមានគម្រោងសរុបចំនួន ២៩ ក្នុងនោះគម្រោងចំនួន ២០ ត្រូវបានបិទ និងបញ្ចប់ ហើយគម្រោងចំនួន ៩ ទៀត កំពុងបន្តអនុវត្តន៍រហូតដល់ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៦។ ការវាយតម្លៃ

ចុងក្រោយនៃការអនុវត្ត TDSP ដោយធនាគារពិភពលោក និងសហគមន៍អឺរ៉ុប បានបញ្ជាក់ថា TDSP សមស្របទៅនឹងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្ម។

### ២.១០.៣ ការអនុវត្តកម្មវិធីពង្រឹងសមាហរណកម្ម

- កម្មវិធីពង្រឹងសមាហរណកម្មជំហានទី១ (EIF Tier 1) ចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ២០១០ និងបានបញ្ចប់នៅខែមីនា ឆ្នាំ២០១៦។ គម្រោងមានថវិកាសរុបចំនួន $1,293,900 ហើយរហូតមកដល់ខែកញ្ញា ឆ្នាំ២០១៥ គម្រោងបានចំណាយថវិកាចំនួន $1,125,639 ឬ ស្មើនឹង 87% នៃចំនួនថវិកាសរុប។ EIF Tier 1 គឺសំដៅពង្រឹងសមត្ថភាពអង្គភាព អង្គភាពអនុវត្តគម្រោង និងអន្តរក្រសួងដែលពាក់ព័ន្ធ
- កម្មវិធីពង្រឹងសមាហរណកម្មជំហានទី២ (EIF Tier 2), CEDEP I ចាប់ផ្តើមពីខែកក្កដា ឆ្នាំ២០១២ និងបញ្ចប់នៅខែតុលា ឆ្នាំ២០១៦ ដោយផ្តោតលើវិស័យចំនួន២គឺ វិស័យអង្ករ (IFC), វិស័យសូត្រ (ITC), និង ការត្រួតពិនិត្យនិងវាយតម្លៃ (DICO)។ រហូតមកដល់ខែកញ្ញា ឆ្នាំ២០១៥ គម្រោងបានចំណាយអស់ $1,174,790 ដែលស្មើ នឹង 49% នៃថវិកាសរុបរបស់គម្រោងដែលមានចំនួន $3,383,429 ។ សម្រាប់ គម្រោង CEDEP II ចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ២០១៤ និងបញ្ចប់នៅខែកក្កដា ឆ្នាំ២០១៨ ដោយផ្តោតលើវិស័យចំនួន៣ គឺ វិស័យជំឡូងមី (អនុវត្តដោយ UNDP), ផលផលសមុទ្រ (អនុវត្តដោយ UNIDO), សាលារាជបណ្ឌិតសភាធ្វើម្ហូប (អនុវត្តដោយអង្គការ Shift 360), និងការត្រួតពិនិត្យនិងវាយតម្លៃ (អនុវត្តដោយ DICO) ។ រហូតមកដល់ខែកញ្ញា ឆ្នាំ២០១៥ គម្រោងបានធ្វើការចំណាយអស់ $28,068 ដែល ស្មើនឹង 8.0% នៃថវិកាសរុបរបស់គម្រោងដែលមានចំនួន $347,610 ។

### ២.១០.៤ ការរៀបចំផែនការរយៈពេលមធ្យម

ក្រសួងបាន និងកំពុងរៀបចំផែនការរយៈពេលមធ្យម MTP (Medium Term Plan 2016-2020) ដើម្បីកៀង គរជំនួយសម្រាប់ពាណិជ្ជកម្ម ពីឆ្នាំ ២០១៦ ដល់ ២០២០ ។ ការរៀបចំផែនការនេះដោយផ្អែកលើការពិនិត្យ មើលឡើងវិញលើការអនុវត្តកន្លងមក នូវយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា និងផែនទីបង្ហាញផ្លូវ CTIS (Cambodia Ttrade Integration Strategy 2014-2018) ។ ជាលទ្ធផល កន្ត្រាមអាទិភាពចំនួន ១០ វិស័យត្រូវបានអនុម័តដោយ SSC និងក្រសួងពាណិជ្ជកម្ម។ ផ្អែកលើកន្ត្រាមអាទិភាពទាំង ១០ នេះ ក្រសួងបានបង្កើតនូវឯកសារទស្សនាទាន (Concept Nates) ចំនួន ៥ ដែលឯកសារនេះ នឹងប្រើប្រាស់ដើម្បីស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍។ ក្រសួងនឹងរៀបចំឯកសារទស្សនាទានចំនួន ៥ ផ្សេងទៀត នៅពេលខាងមុខ។ ផែនការរយៈពេលមធ្យម ២០១៦-២០២០ គ្រោងនឹងធ្វើចប់សព្វគ្រប់នៅត្រីមាសទី ១ ឆ្នាំ ២០១៦ ។

## ២.១១ ការត្រួតពិនិត្យ បង្ក្រាបការក្លែងបន្លំ និងការពារអ្នកប្រើប្រាស់

### ២.១១.១ ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យការនាំចេញ-នាំចូល តាមច្រកព្រំដែន

- រកឃើញ និងរឹបអូសយកកម្ទេចចោលនូវផលិតផលម្ហូបអាហារគ្មានសុវត្ថិភាពចំនួន ១៣.៥៧៥ គីឡូក្រាម
- រកឃើញសារធាតុរាវគ្មានស្លាកសញ្ញាចំនួន ១៥ប៊ីដុង ស្មើ៣០០លីត្រ និងម្សៅក្រាមពណ៌សគ្មានស្លាកសញ្ញាចំនួន ២០គីឡូក្រាម

- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ រកឃើញ និងឃាត់ទុកជាបណ្ដោះអាសន្ននូវគ្រឿង កន្ទុយដំរីក្រញាំ ចង្កូមខ្លា មានទម្ងន់សរុប ៤៥,៦០គីឡូក្រាម
- ឃាត់ទុកមេទ្បេលាបស្បែកចំនួន ៦ធុង ស្មើ ៣០គីឡូក្រាម និងអាស៊ីតអាសេនិចចំនួន ៣៦ដប ស្មើ ៤២លីត្រ។

## ២.១១.២ ពង្រឹងប្រសិទ្ធភាពនៃការឃ្លាំពិនិត្យទីផ្សារ ទប់ស្កាត់គ្រោះថ្នាក់សុខមាលភាព សុវត្ថិភាពអ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងផលិតផល

កម្មវិធីឃ្លាំពិនិត្យទីផ្សាររួមមាន៖ ការធ្វើអង្កេតលើការប្រើប្រាស់សារធាតុគីមីហាមឃាត់ និងសារធាតុគីមីបន្ថែមក្នុងម្ហូបអាហារ វត្តមានមីក្រូជីវសាស្ត្រដែលបណ្ដាលឲ្យពុល និងការធ្វើអង្កេតលើមេតាណុលក្នុងស្រា។ ជាលទ្ធផលបានឃ្លាំពិនិត្យទីផ្សារចំនួន ១.២២៧លើក និង២៤គ្រឹះស្ថានសិក្សា នៅទូទាំងប្រទេសដកហូតទំនិញដែលមានភាពមិនប្រក្រតី (ទំនិញក្លែងក្លាយ, ខូចគុណភាព, ផុតកំណត់រយៈពេលប្រើប្រាស់ ។ល។) សរុបប្រមាណ ១៣.៥៥៦គីឡូក្រាម មកកម្ទេចចោល។

## ២.១១.៣ ពង្រឹងស្ថាប័នធ្វើឱ្យប្រសើរ និងមានប្រសិទ្ធភាពចំពោះកិច្ចការពារអ្នកប្រើប្រាស់

- បិទផ្ទាំងរូបភាពផ្សព្វផ្សាយ (Posters) អំពីរបៀបពិនិត្យស្លាកសញ្ញាផលិតផលម្ហូបអាហារដែលមានសុវត្ថិភាព នៅតាមទីផ្សារ និងទីសាធារណៈ បានចំនួន ៥១.៦៣០ផ្ទាំង
- ស្នើសុំផ្អាកការផ្សាយពាណិជ្ជកម្មលក់ផលិតផលចំនួន ០៤ ជាបណ្ដោះអាសន្ន ដើម្បីឲ្យក្រុមហ៊ុនកែសម្រួលខ្លឹមសារឲ្យបានសមស្របឡើងវិញ។ តាមការតាមដានរបស់ក្រសួងឃើញថា ក្រុមហ៊ុនដែលជាម្ចាស់ផលិតផលទាំង ៤ បានប្រតិបត្តិតាមកិច្ចសន្យារបស់ខ្លួនបានសមស្រប
- ពិភាក្សាជាមួយក្រុមហ៊ុនចំនួន ១០ ពីតម្លាភាពនៃការផ្ដល់រង្វាន់ និងប្រសិទ្ធភាពនៃផលិតផលដែលក្រុមហ៊ុនបានអះអាងតាមរយៈការឃោសនាផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍។

## ២.១១.៤ លើកកម្ពស់ការយល់ដឹងសាធារណៈ

- ចុះអប់រំផ្សព្វផ្សាយអំពីគុណភាព សុវត្ថិភាពម្ហូបអាហារ និងផលប៉ះពាល់ដល់អាជីវករ នៅតាមទីផ្សារបានចំនួន ១.២២៧លើក ដោយមានអាជីវករចូលរួមប្រមាណ ២២.៩២៥នាក់
- ចុះអប់រំផ្សព្វផ្សាយអំពីគុណភាព សុវត្ថិភាពម្ហូបអាហារ និងផលប៉ះពាល់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀននៅតាមវិទ្យាល័យ និងមហាវិទ្យាល័យបានចំនួន ១៩លើក ដោយមានសិស្សានុសិស្ស-និស្សិត លោកគ្រូ-អ្នកគ្រូ និងសាស្ត្រាចារ្យចូលរួមចំនួន ៤.៩៦៩នាក់។

## ២.១១.៥ ទប់ស្កាត់ការក្លែងបន្លំ

- សហការបង្ក្រាបសិប្បកម្មផលិតកាហ្វេមួយកន្លែង ដែលមានកំហុសផ្នែកបច្ចេកទេសលើសំបកវេចខ្ចប់ ដោយបានភូតកុហកអ្នកប្រើប្រាស់ថាជាកាហ្វេ ១០០%
- ចុះត្រួតពិនិត្យគុណភាពកម្រិតសន្ទស្សន៍អុកតាន (Octance) និងបរិមាណរង្វាស់រង្វាល់ប្រេងសាំងនៅស្ថានីយ៍ប្រេងឥន្ធនៈចំនួន ៤៥ នៅរាជធានីភ្នំពេញ ដោយរកឃើញស្ថានីយ៍ ៣ បានដាក់លក់ប្រេងសាំងដែលមានកម្រិតអុកតានទាបជាងបទដ្ឋានកំណត់ និងមានស្ថានីយ៍ចំនួន ៨ មានកម្រិតលំអៀងផ្នែករង្វាស់រង្វាល់ (ពី ១.៣លីត្រ ទៅ ៦.៤ លីត្រ ក្នុងបរិមាណប្រេង ១០០ លីត្រ)។ ក្រសួង

ពាណិជ្ជកម្ម បានឲ្យម្ចាស់ស្ថានីយ៍ទាំង ១១ ធ្វើកិច្ចសន្យាដើម្បីធ្វើការកែសម្រួលជាការប្រញាប់។ ក្នុងករណីពុំអនុវត្តតាមការណែនាំ ក្រសួងនឹងអនុវត្តវិធានការច្បាប់ជាបន្ត

- សម្របសម្រួលពាក្យបណ្តឹងជាមួយក្រុមហ៊ុនបារី ៥៥៥ The British American Tobacco Cambodia ជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មក្នុងវិធានការស្រាវជ្រាវការលក់បារី៥៥៥ ពីសំណាក់ក្រុមហ៊ុនដទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា
- ចូលរួមសហការ ត្រួតពិនិត្យទីតាំងផលិតទំនិញក្លែងក្លាយចំនួន ២កន្លែង នៅរាជធានីភ្នំពេញគឺៈ ទីតាំងផលិតគ្រឿងសំអាង ក្លែងបន្លំម៉ាកមួយកន្លែង និងទីតាំងសិប្បកម្មផលិតភេសជ្ជៈម៉ាក ENERGY DRINK លួចបន្លំស្លាកសញ្ញាក្បាលក្របីមួយកន្លែង ដោយដកហូតវត្ថុតាងមួយចំនួនបញ្ជូនទៅតុលាការ
- ចុះត្រួតពិនិត្យ និងដកហូតស្រាក្លែងក្លាយចំនួន ១៨៨៨ប បញ្ជូនទៅតុលាការដើម្បីចាត់ចែងតាមនីតិវិធី
- ត្រួតពិនិត្យ និងធ្វើតេស្តិ៍សាកល្បងលើជញ្ជីងលក់ក្តាមនៅខេត្តកំពត និងខេត្តកែបចំនួន ២៧ជញ្ជីង ដែលលទ្ធផលពិនិត្យឃើញមានជញ្ជីងចំនួន ៥ មានកម្រិតលំអៀងលើសពី ១០០ក្រាម ដល់ ៥០០ក្រាម លើជុំទម្ងន់ ២០ គីឡូក្រាម ដែលបានសាកល្បង។

### ២.១១.៦ បញ្ហារធំនាក់ទំនងអំពីអនាម័យ និងភូតគាមអនាម័យ (SPS Enquiry Points)

ស្រាវជ្រាវ និងពិនិត្យការជូនដំណឹងអំពីអនាម័យ និងភូតគាមអនាម័យបានចំនួន ៥៨៤ករណី (ផ្នែកសុវត្ថិភាពផលិតផលម្ហូបអាហារចំនួន ៤២២ករណី ផ្នែកកិច្ចការពាររុក្ខជាតិចំនួន ៦០ករណី និងផ្នែកកិច្ចការពារសុខភាពសត្វចំនួន ៦២ករណី) ពី ១៧ប្រទេស និងតាមដានព្រឹត្តិការណ៍ស្តីពីសុវត្ថិភាពផលិតផលម្ហូបអាហារ ដែលកើតមាននៅប្រទេសនានាបានចំនួន ១១ករណី ដូចជាៈ

- ករណីមិនអនុញ្ញាតឲ្យនាំចូល និងបញ្ជូនត្រឡប់ទៅវិញ នូវអង្ករសើរីតដែលមានប្រភពដើមនៅប្រទេសឥណ្ឌា ក្រោយពីបានរកឃើញមានបរិមាណ សំណល់ថ្នាំកសិកម្មCarbendazim ក្នុងកម្រិត0.03mg/Kg របស់ប្រទេសអ៊ីតាលី
- សេចក្តីជូនដំណឹងរបស់អាជ្ញាធរប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់ អំពីវិធានការរបស់ក្រុមហ៊ុន Patties Foods Ltd ប្រមូលមកវិញនូវផលិតផលផ្លែឈើបង្កក (Mixed Berries and Raspberries; Creative Gourmet Mixed Berries) ដែលមានប្រភពដើមនៅប្រទេសចិន។ ផលិតផល ផ្លែឈើនេះ ត្រូវបានរកឃើញមានការចម្លងចូលវីរុស Hepatitis A
- ការហាមឃាត់ មិនអនុញ្ញាតឲ្យនាំចូល និងកម្ទេចចោលផ្លែស្រកានាគ នាំចូលពីប្រទេសវៀតណាម បន្ទាប់ពីបានរកឃើញវត្តមានសំណល់ថ្នាំកសិកម្ម Carbendazim លើសកម្រិតកំណត់ ក្នុងបទប្បញ្ញត្តិនៅប្រទេសប៊ែលហ្សិក
- ការប្រមូលមកវិញនូវផ្លែប៉ោម ដែលផលិតដោយក្រុមហ៊ុន Bidart Brothers និងក្រុមហ៊ុនដាំដែតុ Bidart Brothers បន្ទាប់ពីបានរកឃើញមានចម្លងបាក់តេរី Listoria Monocytogenes នៅសហរដ្ឋអាមេរិក
- ការជូនព័ត៌មានអំពីការប្រមូលមកវិញនូវផលិតផល Fisher Brand 10 Ounce Chopped Walnuts របស់ក្រុមហ៊ុន John B. Sanfilippo & Son, Inc បន្ទាប់ពីបានរកឃើញថាមានការចម្លងចូលបាក់តេរី Salmonella

- អាជ្ញាធរសុវត្ថិភាពផលិតផលម្ហូបអាហារ ប្រទេសបែលហ្ស៊ិក បានគេឃើញវត្តមានបរិមាណសំណល់ថ្នាំកសិកម្ម Chlorpyrifos 12.2mg/Kg លើផលិតផលគ្រឿងទេសជីនាងវង (SweetBasil) ដែលមានប្រភពនៅកម្ពុជា លើសពីការកំណត់ក្នុងបទបញ្ញត្តិសហភាពអឺរ៉ុប
- សេចក្តីណែនាំជាសាធារណៈ មិនឲ្យទិញ លក់ ឬទទួលទានស្ករគ្រាប់រសជាតិផ្លែឈើដែលមានម៉ាក (យីហោ) "Wendy's" ដែលសង្ស័យពីលទ្ធភាព នៃការចម្លងចូលបាក់តេរីបង្កជម្ងឺ Samolnella E. coli របស់រដ្ឋបាលឱសថ និងម្ហូបអាហារប្រទេសហ្វីលីពីន
- ការជូនព័ត៌មានអំពីក្រុមហ៊ុន Atkins International BV បានស្ម័គ្រចិត្តប្រមូលមកវិញផលិតផលនំសូកូឡា "Atkins Endulge Chocolate Break Wafers" បន្ទាប់ពីសង្ស័យលទ្ធភាព នៃការចម្លងចូលបាក់តេរី Salmonella នៅចក្រភពអង់គ្លេស
- ក្រុមហ៊ុន Butala Emporium, Inc of Jackson Heights, NY នៅសហរដ្ឋអាមេរិក បានស្ម័គ្រចិត្តប្រមូលមកវិញនូវផលិតផលអាហារបំប៉ន "Ayurvedic Dietary Supplements" ដែលនាំចូលពីប្រទេសឥណ្ឌា បន្ទាប់ពីបានគេឃើញថាមានវត្តមានសារធាតុពុលលោហៈធាតុធ្ងន់សំណរ និងបារតក្នុងកម្រិតបរិមាណ ដែលនឹងបណ្តាលឲ្យមានគ្រោះថ្នាក់ ដល់សុខភាពអ្នកប្រើប្រាស់ ជាពិសេសទារក កុមារតូច និងស្ត្រីមានផ្ទៃពោះ។
- សេចក្តីជូនដំណឹងពីស្ថាប័នអនាម័យម្ហូបអាហារ និងបរិស្ថាន រដ្ឋបាលក្រុងហុងកុង ដែលបានហាមទទួលទាន ចែកចាយ និងលក់ផលិតផលភេសជ្ជៈអាល់កុល (ចំពោះតែឡូត៍ផលិតផលដែលមានបញ្ហា) ដែលផលិតនៅប្រទេសបារាំង បន្ទាប់ពីទទួលបានសេចក្តីជូនជូនដំណឹង ពីវត្តមានសារធាតុគីមី Ethyl Carbamate ( 11.4 milligram per Litre) នៅក្នុងផលិតផលនេះ ។

### ២.១១.៧ ការងារពាក់ព័ន្ធ ACCSQ, ATFC, ARASFF, ARASCP, ACOST, ACCP

- កិច្ចការអាស៊ាន
  - ACCSQ: បានចូលរួមក្នុងកិច្ចប្រជុំលើកទី ២០ នៃក្រុមការងារផលិតផលម្ហូបអាហារផ្សំស្រេច (Prepared Food stuff Working Group) ដែលជាក្រុមការងារក្រោមគណៈកម្មាធិការពិគ្រោះយោបល់អាស៊ាន អំពីកិច្ចការស្តង់ដារ និងគុណភាព ( ACCSQ) ដើម្បីពិនិត្យ និងយល់ព្រមនូវកិច្ចការមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការធ្វើសុខដុមនីយកម្មម្ហូបអាហារផ្សំស្រេចជាអាទិ៍ ការទទួលស្គាល់គ្នាទៅវិញទៅមក, ការកំណត់ លក្ខខណ្ឌតម្រូវសម្រាប់ការត្រួតពិនិត្យផលិតផលម្ហូបអាហារ, ការរៀបចំមន្ទីរពិសោធន៍ សម្រាប់ប្រើប្រាស់ជាយន្តការដោះស្រាយជម្លោះក្នុងពាណិជ្ជកម្មម្ហូបអាហារ
  - ATFC: បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា ដើម្បីកំណត់នូវជំហរ ឯកភាពគ្នាលើបណ្តាចំណុចពាក់ព័ន្ធនឹងការគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ដែលយន្តការកូដិចអន្តរជាតិបានដំណើរការកសាង នូវស្តង់ដារ ទៅតាមបណ្តាដំណាក់
  - គួរកត់សំគាល់ថា អនុលោមទៅតាមបែបបទនៃការប្រជុំប្តូរវេន កម្ពុជាមានភារកិច្ចត្រូវធ្វើជាម្ចាស់ផ្ទះ សម្រាប់កិច្ចប្រជុំលើកទី ១៧ នៃ ATFC នៅក្នុងឆ្នាំ ២០១៧ ខាងមុខ
  - ARASFF: បានចូលរួមក្នុងកិច្ចប្រជុំ ប្រព័ន្ធឆ្លើយតបបន្ទាន់ សម្រាប់ម្ហូបអាហារ និងចំណីសត្វរបស់អាស៊ាន (ARASFF) ដែលមានសមាសភាពមកពីបណ្តាប្រទេសក្នុងតំបន់អាស៊ានបានចូលរួម។ កម្មវត្ថុ នៃកិច្ចប្រជុំ គឺដើម្បីស្តាប់របាយការណ៍អំពីលទ្ធផល, ភាពខ្លាំង, និងការ

លំបាកនៃការអនុវត្តប្រព័ន្ធ ARASFF ដែលប្រទេសអាស៊ានជាសមាជិកបានអនុវត្តកន្លងមក និងការរៀបចំផែនការសម្រាប់អនុវត្តរយៈពេល ៣ ឆ្នាំបន្ត (២០១៦-២០១៨)។

### ២.១១.៨ ការងារគណៈកម្មាធិការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាពសុវត្ថិភាពផលិតផល និងសេវា និងគណៈកម្មាធិការកូដិចជាតិ

- កិច្ចការកូដិចអន្តរជាតិ
  - រៀបចំសារជាថ្មី នូវសមាសភាព របស់គណៈកម្មាធិការកូដិចជាតិ, លេខាធិការដ្ឋាន, និងក្រុមការងារបច្ចេកទេសទាំង ៤
  - រៀបចំកិច្ចប្រជុំគណៈកម្មាធិការកូដិចជាតិ ដើម្បីប្រកាសសមាសភាពតែងតាំងថ្មី ដោយមានការណែនាំឲ្យមានផែនការសកម្មភាពសមស្របអមដោយរបាយការណ៍ អំពីសកម្មភាពដែលបានអនុវត្ត ទៅតាមរចនាសម្ព័ន្ធដែលបានកំណត់។

### ២.១១.៩ ការកសាងច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេសសម្រាប់ការងារការពារអ្នកប្រើប្រាស់

- កំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីម្ហូបអាហារនិងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- កំពុងរៀបចំសេចក្តីព្រាងបញ្ញត្តិបច្ចេកទេស អំពី "ការនាំចូលផលិតផលម្ហូបអាហារ និងការប្រមូលត្រលប់មកវិញនូវម្ហូបអាហារដែលមានគ្រោះថ្នាក់ (Food Recall)"
- បន្តការស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានហានិភ័យ បង្កដោយផលិតផលម្ហូបអាហារ ដើម្បីកំណត់វិធានការត្រួតពិនិត្យការនាំចូល និងឃ្លាំពិនិត្យទីផ្សារ ព្រមទាំងវាយតម្លៃហានិភ័យ លើប្រភេទម្ហូបអាហារកំប៉ុង ផលិតផលទឹកដោះគោ, ផលិតផលទំពាំងបាយជូរ/ទឹកកកិសារ, និងផលិតផលប្រេងឥន្ធនៈមួយចំនួន។

### ២.១១.១០ ការងារមន្ទីរពិសោធន៍

- ចូលរួមការធ្វើតេស្តក្នុងកម្មវិធីអន្តរមន្ទីរពិសោធន៍ជាលក្ខណៈអន្តរជាតិបានមួយលើក ស្តីពីការវិភាគរកលោហៈធ្ងន់ក្នុងទឹក (ដែក, កាត់ម្យូម, ទង់ដែង, និងសំណ) រៀបចំឡើងដោយការិយាល័យគុណភាព និងសុវត្ថិភាពម្ហូបអាហារ នៃក្រសួងសុខាភិបាលថៃ
- ទទួលវិភាគសារធាតុគីមីបន្ថែម ក្នុងម្ហូបអាហារចំនួន ១,២៤១គំរូ, សារធាតុចម្លងចំនួន ៥៩គំរូ, មីក្រូជីវសាស្ត្រចំនួន ៥១៨គំរូ, រូបសាស្ត្រចំនួន ១.៩៦៧គំរូ, សារធាតុអាហារូបត្ថម្ភចំនួន ៦៣គំរូ, សំណល់សារធាតុគីមីចំនួន ៣២គំរូ, គុណភាពប្រេងឥន្ធនៈចំនួន ៧៧៦គំរូ, និងការវិភាគផ្សេងទៀតចំនួន ១០គំរូ ដោយពិនិត្យឃើញផលិតផលចំនួន ១២៨គំរូ មិនសមស្របតាមស្តង់ដារតម្រូវ
- អនុញ្ញាតឲ្យនិស្សិត មកពីមហាវិទ្យាល័យឱសថសាស្ត្រ គីមីសាស្ត្រ និងគីមីចំណីអាហារ ចំនួន ១៣៧នាក់ បានធ្វើកម្មសិក្សា ស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ និងវិធីសាស្ត្រវិភាគគុណភាព និងសុវត្ថិភាពម្ហូប
- រៀបចំមន្ត្រីតាមជំនាញ និងបង្កើនសមត្ថភាពបច្ចេកទេស តាមការហ្វឹកហាត់ក្នុងប្រទេស/ក្រៅប្រទេស និងការបណ្តុះបណ្តាលជំនាញជាកំលាក់បន្ថែម ជាពិសេសការបណ្តុះបណ្តាល ការប្រើប្រាស់ឧបករណ៍ទំនើប។ វគ្គបណ្តុះបណ្តាលទាំងនោះមានដូចជា៖ វិធីសាស្ត្រញែកសារធាតុគីមីដោយប្រើប្រាស់ឧបករណ៍ទំនើប GC-MS យុទ្ធសាស្ត្រគ្រប់គ្រងសារធាតុគីមី និងការសិក្សា

រចនាសម្ព័ន្ធដែលមានលក្ខណៈសម្បត្តិសម្រាប់ធានាសុវត្ថិភាពម្ហូបអាហារ។ល។

## ២.១២ ការងារមន្ត្រី បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងមានក្របខណ្ឌមន្ត្រីរាជការសរុបចំនួន ១.៦៨៤ នាក់ ស្រីចំនួន ៤៣៦នាក់រួមមាន៖

- រដ្ឋបាលកណ្តាល ចំនួន ១.១៨៨ នាក់ ស្រីចំនួន ២៨២ នាក់
- មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ចំនួន ៤៩៦ នាក់ ស្រីចំនួន ១៥៤ នាក់
- ក្របខណ្ឌ មុខងារសាធារណៈ ចំនួន ១.៦១៥ នាក់
- ក្របខណ្ឌ មិនមែនមុខងារសាធារណៈ ចំនួន ២៩ នាក់
- ប្រភេទក្របខណ្ឌ "ក" ចំនួន ១.៣៣៧នាក់ ក្របខណ្ឌ "ខ" ចំនួន ១០២នាក់ ក្របខណ្ឌ "គ" ចំនួន ២០៥នាក់
- ដោយឡែកជនពិការមានចំនួន ២៦នាក់ ស្រីចំនួន ៧នាក់ គិតជាភាគរយចំនួន ១.៦% នៃមន្ត្រីសរុប
- ធ្វើសេចក្តីជូនដំណឹង ស្តីពី "មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ឆ្នាំ២០១៦" មានចំនួន ២៨នាក់ ជូនទៅគ្រប់អង្គភាពពាក់ព័ន្ធ
- ធ្វើប័ណ្ណសំគាល់ខ្លួនជូនថ្នាក់ដឹកនាំ ទីប្រឹក្សាជំនួយការ និងមន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្មទៅទីស្តីការក្រសួងបានចំនួន ១.៣៣៧នាក់ និងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តបានចំនួន ៤៣១ នាក់ សរុបទាំងអស់បានចំនួន ១.៧៦៨នាក់
- ការងារមេដាយ បានរៀបចំបែបបទឯកសារស្នើសុំផ្តល់គ្រឿងឥស្សរិយយស ជូនមន្ត្រីរាជការ នៅតាមអង្គភាពក្រោមឱវាទក្រសួង ដែលបានខិតខំបំពេញការងារក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ ទៅតាមប្រភេទមេដាយឡើងវិញ ដូចខាងក្រោម៖

*ក. គ្រឿងឥស្សរិយយសសម្រាប់លទ្ធផលការងារឆ្នាំ២០១២ មានចំនួន ១៣នាក់ក្នុងនោះមាន៖*

- មេដាយសុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០៣នាក់
- មេដាយសុវត្ថារា ថ្នាក់មហាសេនា ចំនួន ១០នាក់។

*ខ. គ្រឿងឥស្សរិយយសសម្រាប់លទ្ធផលការងារ ឆ្នាំ២០១៣ មានចំនួន ២៧រូប ក្នុងនោះមាន៖*

- មេដាយមាតុប្រទេស ជាតូបការ ចំនួន ០៣នាក់
- មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០២នាក់
- មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា ចំនួន ០២នាក់
- មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា ចំនួន ០១នាក់
- មេដាយសុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០៥នាក់
- មេដាយសុវត្ថារា ថ្នាក់មហាសេនា ចំនួន ១៤នាក់។

- កែសម្រួលតួនាទីតាមប្រកាសតែងតាំង និងកែសម្រួលប្រាក់បំណាច់មុខងារជូនមន្ត្រី ដែលបានតែងតាំង ដោយអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី "ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង" នៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អនុវត្តផែនការក្របខ័ណ្ឌមន្ត្រីរាជការ ដែលបានឯកភាពពីក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់ក្របខ័ណ្ឌមន្ត្រីថ្មីចំនួន ៨៥កន្លែង បុគ្គលិកជាប់កិច្ចសន្យាចំនួន ១០០ កន្លែង និងពលករអណ្តែតចំនួន ៩៦កន្លែង សម្រាប់ឆ្នាំ២០១៦

- មន្ត្រីរាជការក្រសួងពាណិជ្ជកម្ម បានចូលជាសមាជិកសមាគមមន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងចំនួន ៧៨៧នាក់ និងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តចំនួន ៥៤៩នាក់ សរុបមានចំនួន ១.៣៣៦នាក់។ ក្រសួងបានចាត់តាំង និងចាត់បញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការតំណាង ក្រសួងឲ្យចូលរួមក្នុងគណៈកម្មការ និងយន្តការនានាមានចំនួន ១០៣រូប។

ក. <u>តែងតាំង៖</u>

តែងតាំង និងសម្រួលភារកិច្ចជូនមន្ត្រីរាជការ ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស សរុបចំនួន ២៧៩រូប (ថ្នាក់រដ្ឋបាលកណ្តាលចំនួន ៩៩រូប សម្រួលភារកិច្ចថ្នាក់កណ្តាល សរុបចំនួន ១៧៦នាក់ និងថ្នាក់រាជធានី-ខេត្តចំនួន ១៥រូប) រួមមាន៖ អគ្គាធិការមួយរូប អគ្គនាយកជំរុញពាណិជ្ជកម្មមួយរូប ទីប្រឹក្សាក្រសួងមានឋានៈស្មើអនុរដ្ឋលេខាធិការមួយរូប អគ្គនាយករង ២រូប ទីប្រឹក្សាពាណិជ្ជកម្មអមស្ថានបេសកកម្មកម្ពុជា នៅទីក្រុងហ្សឺណែវមានឋានៈស្មើអគ្គនាយករង មួយរូប និងអគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដចំនួនមួយរូប និងទីប្រឹក្សាពាណិជ្ជកម្មអមស្ថានបេសកកម្មកម្ពុជា នៅទីក្រុងហ្សឺណែវមានឋានៈស្មើប្រធាននាយកដ្ឋានមួយរូប ទីប្រឹក្សាក្រសួងមានឋានៈស្មើអគ្គនាយករងមួយរូប ប្រធាននាយកដ្ឋាន ៦រូប អនុប្រធាននាយកដ្ឋាន ១០រូប ថ្នាក់ប្រធានការិយាល័យ ៣០រូប ថ្នាក់អនុប្រធានការិយាល័យចំនួន ៤៨រូប។ និងការតែងតាំងថ្នាក់ក្រោមជាតិមានដូចជា៖ប្រធានមន្ទីរ ៣រូប និងប្រធានមន្ទីរស្តីទីចំនួនមួយរូប អនុប្រធានមន្ទីរ ២រូប និងប្រគល់ភារកិច្ចអនុប្រធានមន្ទីរ ២រូប និងប្រធានការិយាល័យថ្នាក់ក្រោមជាតិចំនួន ៧រូប សរុបមានចំនួន ១៥រូប។

ខ. <u>ផ្ទេរ និងសម្រួលភារកិច្ច៖</u>

- សម្រួល និងផ្ទេរភារកិច្ចជូនមន្ត្រី នៃអគ្គនាយកដ្ឋានកាំកុងត្រូលសរុបមានចំនួន ១៦២រូប ក្នុងនោះមាន៖ ប្រធានសាខាចំនួន ២៨រូប និងអនុប្រធានសាខាមានចំនួន ១៣៤រូប
- សម្រួល និងផ្ទេរភារកិច្ចជូនមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបមានចំនួនចំនួន ៨រូប។

គ. <u>ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស៖</u>

- រៀបចំវគ្គបណ្តុះបណ្តាលបានចំនួន ១៦ លើក សរុបសិក្ខាកាមចំនួន ៨៣៩នាក់ក្នុងនោះ៖
    - មន្ត្រីក្រសួងពាណិជ្ជកម្ម ចំនួន ៧៨៤ នាក់
    - មន្ត្រីក្រសួងពាក់ព័ន្ធ ចំនួន ១៥ នាក់
    - វិស័យឯកជន ចំនួន ៤០នាក់
- រៀបចំវគ្គបណ្តុះបណ្តាលការសិក្សាពីចម្ងាយ (Distance Learning) របស់អង្គការពាណិជ្ជកម្មពិភពលោកចំនួន ២វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន ៧៥នាក់
- ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់វិទ្យាស្ថាន ពីក្នុងចំណោមមន្ត្រីគ្រប់នាយកដ្ឋាន និងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត បានចំនួន ៦០នាក់
- បណ្តុះបណ្តាលវិធីសាស្ត្រសិក្សាស្រាវជ្រាវដល់មន្ត្រីក្រសួងពាណិជ្ជកម្មចំនួន ៣៥នាក់ ដែលនឹងក្លាយខ្លួនជាក្រុមមន្ត្រីបង្គោលសម្រាប់ការងារស្រាវជ្រាវរបស់ក្រសួងពាណិជ្ជកម្ម
- រៀបចំកម្មវិធីសិក្សាពាណិជ្ជកម្មរយៈពេលវែង មធ្យម និងខ្លីសម្រាប់បណ្តុះបណ្តាលមន្ត្រីថ្នាក់កណ្តាលមន្ត្រីរាជធានី-ខេត្ត និងវិស័យឯកជន

- រៀបចំកម្មវិធីសិក្សាកុំព្យូទ័រចំនួន ១២០ម៉ោង និងកម្មវិធីសិក្សាភាសាអង់គ្លេសចំនួន ១២ កម្រិត ដើម្បីបណ្តុះបណ្តាលមន្ត្រីថ្នាក់កណ្តាល និងមន្ទីររាជធានី-ខេត្ត
- ដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យ ARDI របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដែលអាចចូលទៅកាន់សៀវភៅនិងអត្ថបទសិក្សាផ្សេងៗ រាប់ពាន់មុខសម្រាប់ប្រើប្រាស់ក្នុងបណ្ណាល័យរបស់វិទ្យាស្ថាន
- រៀបចំចងក្រង និងបោះពុម្ពកម្មវិធីសិក្សាពាណិជ្ជកម្មដែលមានចំនួន ២០ មេរៀន (Modules)
- រៀបចំគោលនយោបាយនិងឯកសារវាយតម្លៃសកម្មភាពបណ្តុះបណ្តាលសម្រាប់វិទ្យាស្ថាន និងក្រសួងទាំងមូល
- រៀបចំធ្វើផែនការវាយតម្លៃ អំពីតម្រូវការអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាននិមួយៗ និងមន្ទីររាជធានី-ខេត្ត និងរៀបចំផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានសម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខ
- រៀបចំគេហទំព័ររបស់វិទ្យាស្ថានដែលបច្ចុប្បន្ននេះសម្រេចបាន ៧០% ហើយនឹងដាក់ដំណើរការក្នុងពេលឆាប់ៗខាងមុខនេះ
- ធ្វើការសិក្សាស្រាវជ្រាវខ្សែសង្វាក់តម្លៃផលិតកម្ម ចំពោះផលិតផលកង់ ស្ករត្នោត និងផលិតផលស្វាយ
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន និងក្រុមការងារឧទ្ទកាល័យ រៀបចំកម្មវិធីភ្ញាស់គំនិតអាជីវកម្ម (MOC 101) សម្រេចបានវគ្គបណ្តុះបណ្តាលបឋម (BootCamp) ចំនួន ៤ដង វគ្គភ្ញាស់គំនិតអាជីវកម្ម (Incubator) ចំនួន ៦វគ្គ និងត្រៀមរៀបចំកម្មវិធីទីផ្សារ និងពិព័រណ៍ (Market Day) និងកម្មវិធីជួបជាមួយអ្នកវិនិយោគទុន និងសិក្ខាកាមដែលទទួលបានជ័យលាភី (Pitch Day) នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ
- ចុះអនុស្សរណៈយោគយល់គ្នា សម្រាប់កិច្ចសហប្រតិបត្តិការ ក្នុងការបណ្តុះបណ្តាលធនធានមនុស្សនិងការសិក្សាស្រាវជ្រាវជាមួយវិទ្យាស្ថានមេគង្គ (Mekong Institute)
- ធ្វើការកែសម្រួលតួនាទីភារកិច្ច តាមការវិភាគមុខងារជាក់លាក់ សម្រាប់មន្ត្រីនាយកដ្ឋាន ដើម្បីធានាប្រសិទ្ធភាពការងារ។
- **ការបណ្តុះបណ្តាលក្នុងប្រទេស៖** បានបញ្ជូនមន្ត្រីសរុបចំនួន ២១០នាក់ ស្រីចំនួន ៦០នាក់ ទៅចូលរួមតាមវគ្គបណ្តុះបណ្តាលជំនាញដូចជា៖
    - វគ្គបណ្តុះបណ្តាល Intermediate English Language and Communication Skills
    - វគ្គបណ្តុះបណ្តាល Project Management for the Public Sector
    - វគ្គបណ្តុះបណ្តាល Principles in Tax Laws and Its Interpretation
    - វគ្គបណ្តុះបណ្តាល Enabling Private Sector Growth and Attracting PDIs
    - វគ្គបណ្តុះបណ្តាល Public Speaking Presentation Skill
    - វគ្គបណ្តុះបណ្តាល Intermediate English Language and Communication Skill (I)
    - វគ្គបណ្តុះបណ្តាល Tourism Development and Promotion
    - វគ្គបណ្តុះបណ្តាល Logistics and Planning of Meeting, Conventions and Exhibition
    - វគ្គបណ្តុះបណ្តាល Capacity Building for Negotiation FTAs
    - វគ្គបណ្តុះបណ្តាល Business Etiquette and Professional Image

- វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសថ្នាក់: Elementary
- វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសថ្នាក់: Pre-Intermediate Level
- វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសថ្នាក់: UpperIntermediate Level
- វគ្គបណ្តុះបណ្តាលថ្នាក់កុំព្យូទ័រទូទៅ
- វគ្គបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងវិស័យសាធារណៈ
- សិក្ខាសាលាស្តីពីការសិក្សាលើមុខងារចេនាសម្ព័ន្ធនិងនីតិវិធីការបំពេញមុខងាររបស់អង្គភាពគ្រប់ គ្រងធនធានមនុស្សនៅក្នុងរដ្ឋបាលសាធារណៈ
- សិក្ខាសាលាស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីសមត្ថភាពមន្ត្រីរាជការស៊ីវិលឆ្នាំ២០១៤-២០១៥
- ចូលរួមវេទិកាស្តីពី Green Business Forum
- បរិញ្ញាបត្រជាន់ខ្ពស់ (ចំនួន ០២នាក់)។

- ការបណ្តុះបណ្តាលក្រៅប្រទេស៖ ចាត់បញ្ជូនទៅតាមបណ្តាប្រទេសស៊ុយអែត សិង្ហបុរី ម៉ាឡេស៊ី ថៃ ទូវែលហ្សេឡង់ កូរ៉េ ស្វីស ចិន ជប៉ុន អូស្ត្រាលី អូទ្រីស ដែលមានចំនួនសរុប ១១៥នាក់ ស្រីចំនួន ២៥នាក់ ដោយបានចូលរួមទៅតាមជំនាញដូចជា៖
    - វគ្គបណ្តុះបណ្តាល Efficient Energy Use and Planning 2015A
    - វគ្គបណ្តុះបណ្តាល Investment and Trade facilitation
    - វគ្គបណ្តុះបណ្តាល Quality Infrastructure of Sustainable Development
    - វគ្គបណ្តុះបណ្តាល Successful Contract Farming Models in Thailand
    - វគ្គបណ្តុះបណ្តាល The ACWL's Secondment Programme for Trade Lawyers
    - វគ្គបណ្តុះបណ្តាល Quality Infrastructure for Food Safety
    - វគ្គបណ្តុះបណ្តាល Master of Laws in Business law
    - វគ្គបណ្តុះបណ្តាល Public Procurement
    - វគ្គបណ្តុះបណ្តាល Master of International Economic Cooperation (1Year)
    - វគ្គបណ្តុះបណ្តាល ASEAN Single Electronic Window
    - វគ្គបណ្តុះបណ្តាល The Practical Guide for Trade Policy Analysis
    - វគ្គបណ្តុះបណ្តាល Efficient Energy Use and Planning 2015B
    - វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសស្តីពីTrade Policy
    - សិក្ខាសាលា Trade Promotion for Developing Countries
    - សិក្ខាសាលា 24th Asian Promotion Forum
    - សិក្ខាសាលា Information System Application Management of E-Commerce for Cambodia in 2015
    - សិក្ខាសាលា Intermediate Thematic Course, Level2, for Least Development Country
    - សិក្ខាសាលា China-ASEANConvention & Exhibition Affairs
    - សិក្ខាសាលា Trade Negotiation Skills
    - សិក្ខាសាលា Malaysian Technology Development Corporation
    - សិក្ខាសាលា Investment Trade Facilitation

- សិក្ខាសាលា Commercial Circulation &Comprehensive Transportation System Construction for Developing Countries
- ប្រលងប្រជែងយកអាហារូបករណ៍នៅប្រទេសកូរ៉េ Master's Degree Program in Global Leaders in Economic Policy (GLEP)
- ប្រលងប្រជែងយកអាហារូបករណ៍នៅប្រទេសកូរ៉េ Master's Degree Program in Korean Experience of Economic Development and Economic Cooperation (MKE)
- ប្រលងប្រជែងយកអាហារូបករណ៍នៅប្រទេសកូរ៉េ Master's Degree Program in Economic Policy and Development

## ២.១៣ រដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ

### ក. ការងាររដ្ឋបាលទូទៅ

- ទទួលលិខិតចូលចំនួន ៨.៣៨២ច្បាប់
- បញ្ជូនលិខិតចេញចំនួន ១៧.៧៦៧ច្បាប់
- រៀបចំសណ្តាប់ធ្នាប់ចំណតយានយន្តរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ព្រមទាំងអតិថិជន ភ្ញៀវជាតិ និងអន្តរជាតិ
- សហការពង្រឹងសន្តិសុខ និងសុវត្ថិភាពក្នុងទីស្តីការក្រសួង
- ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ (ទឹក ភ្លើង ម៉ាស៊ីនត្រជាក់ លូ ផ្លូវ សួនច្បារ។ល។) នៅក្នុងទីស្តីការក្រសួងរៀបចំ និងចងក្រងរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មប្រចាំ សប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ និងសមិទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០១៥ និងទិសដៅឆ្នាំ២០១៦ ផែនការសកម្មភាពពាណិជ្ជកម្មឆ្នាំ២០១៦ និងលទ្ធផលការងារការងារពាណិជ្ជកម្មគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៥
- រៀបចំពិធីបដិសណ្ឋារកិច្ចទទួលភ្ញៀវជាតិ-អន្តរជាតិ ពិធីបុណ្យជាតិ និងកិច្ចប្រជុំផ្សេងៗ
- រៀបចំទុកដាក់ឯកសារ ឲ្យបានល្អប្រសើរតាមលំដាប់នៃលេខកូដ នៃសៀវភៅងាយស្រួលក្នុងការស្វែងរក។

### ខ. ការងារហិរញ្ញវត្ថុ

- អនុវត្តការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់លាភការផ្សេងៗ ជូនមន្ត្រីរាជការសរុបទឹកប្រាក់ចំនួន ១៥.៧៦៦,៩លានរៀល ក្នុងទឹកប្រាក់ប្រចាំឆ្នាំ ៩៨.០០៩,៧លានរៀល
- កត់ត្រា និងតាមដានរាល់ចំណូល-ចំណាយថវិកាជាតិត្រឹមត្រូវ
- រៀបចំបើកប្រាក់បៀវត្សមន្ត្រីរាជការតាមប្រព័ន្ធធនាគារ (ATM) និងធានាបើកប្រាក់បៀវត្សបានទៀងទាត់រៀងរាល់ចុងសប្តាហ៍ទី៤ នៃខែនីមួយៗ
- *ចំណូល*

ការអនុវត្តចំណូល ស្តីពីការផ្តល់សេវាសាធារណៈក្នុងឆ្នាំ២០១៥ បានចំនួន ២៥៦.០៥៥,៧ លានរៀល ក្នុងនោះបានបង់ចូលថវិកាជាតិចំនួន ២០៤.៧២០,៤ លានរៀល វេរទៅកាត់ទុកជូនក្រសួងពាណិជ្ជកម្មចំនួន ៥១.៦២២,៨ លានរៀល និងវេរទៅកាត់ទុកជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១.២៣០,៣ លានរៀល។

- *ចំណាយ៖*
  - ជំពូក៦០: មានឥណទានអនុម័តចំនួន ១១.៦៣៣.៣០០.០០០រៀល អនុវត្តបាន ៤.៣៥១.១៦៤.៧៧៩ (៣៧,៤%)
  - ជំពូក៦១: មានឥណទានអនុម័តចំនួន ៣៥.៩៧៣.៩០០.០០០រៀល អនុវត្តបាន ៣០.៥០៦.៤២៦.៤២៥ (៨៤,៨០%)
  - ជំពូក៦២: មានឥណទានអនុម័តចំនួន ៣.០០០.០០០.០០០រៀល អនុវត្តបាន ៣.៩១៣.០០០.០០០(១៣០%)(ស្នើសុំថវិកាបន្ថែមសម្រាប់ផ្តល់ជូនសហព័ន្ធស្រូវអង្ករកម្ពុជា)
  - ជំពូក៦៣: មានឥណទានអនុម័តចំនួន ១៧.០០០.០០០រៀល អនុវត្តបាន ៨.៥០៥.០០០ (៥០%)
  - ជំពូក៦៤: មានឥណទានអនុម័តចំនួន ៩៤.០០៤.៧០០.០០០រៀល អនុវត្តបាន ៤៩.៣៤៩.៤៤៦.៧៦១ (៥២,៤៦%)
  - ជំពូក៦៥: មានឥណទានអនុម័តចំនួន ១.២១៩.២០០.០០០រៀល អនុវត្តបាន ៣៤៥.៥៣៤.៧២០ (២៨,៣៤%)
- រៀបចំផែនការសកម្មភាពដំណាក់កាលទី៣ សម្រាប់កម្មវិធីកំណែទម្រង់ថវិកាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (MAP3)
- រៀបចំផែនការយុទ្ធសាស្ត្រថវិកាក្រសួងឆ្នាំ២០១៥-២០១៧
- រៀបចំគម្រោងថវិកាក្រសួងប្រចាំឆ្នាំ២០១៦
- ចូលរួមការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០១៦
- លើកកម្មវិធីចំណូលចំណាយថវិកាប្រចាំត្រីមាស ឆ្នាំ
- ចូលរួមរៀបចំអនុស្សរណៈយោគយល់ ស្តីពីការទូទាត់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក (E-Payment) ជាមួយធនាគារចំនួន៣គឺ៖ ធនាគារអេស៊ីលីដាភីអិលស៊ី (ACLEDA PLC) ធនាគារ កាណាឌីយ៉ា ក.អ (CANADIA Bank PCL) និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)
- ចូលរួមក្នុងគណៈកម្មការរៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្ម
- រៀបចំកម្មវិធីបណ្តុះបណ្តាល មន្ត្រីទទួលចំណូលនៅបញ្ជរ ដើម្បីធ្វើការទូទាត់កម្រៃសេវាតាមប្រព័ន្ធអេឡិកត្រូនិក (E-Payment)
- រៀបចំប្រព័ន្ធបែងចែកប្រាក់រង្វាន់ទៅតាមសន្ទស្សន៍ និងកម្រិតសកម្ម ទៅតាមការវាយតម្លៃរបស់អង្គភាពនីមួយៗ
- អនុវត្តការបើកប្រាក់ប្រាក់រង្វាន់លើកទឹកចិត្តតាមប្រព័ន្ធធនាគារ (ATM)
- ពិនិត្យ និងកែសម្រួលកម្រៃសេវា ក្នុងទិសដៅប្រមូលចំណូល និងចំណាយឲ្យបានសមស្រប
- រៀបចំគម្រោងដេញថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈ-សម្ភារៈការិយាល័យ-ឧបករណ៍មន្ទីរពិសោធន៍ និងការបោះពុម្ព
- រៀបចំផែនការលទ្ធកម្មឆ្នាំ២០១៥
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារលទ្ធកម្មប្រចាំឆ្នាំ
- ចូលរួមក្នុងគណៈកម្មការដើម្បីផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌ
- បញ្ចប់បញ្ជីសារពើភ័ណ្ឌឆ្នាំ២០១៤ និងកំពុងបន្តរៀបចំបញ្ជីសារពើភ័ណ្ឌឆ្នាំ២០១៥
- ផ្គត់ផ្គង់សម្ភារៈការិយាល័យ និងបរិក្ខារជូនបណ្តាអគ្គនាយកដ្ឋាន និងនាយកដ្ឋាន។

## ២.១៤ ការងារសន្តិសុខស្បៀង និងសន្និធិអាហារ

តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ថានៅឆ្នាំ ២០១៥ ជាឆ្នាំគោលដើម្បីជំរុញការផលិតស្រូវសេសសល់ពីការប្រើប្រាស់ក្នុងស្រុកឲ្យបានច្រើនជាង ៤លានតោន ក្នុងនោះបរិមាណអង្ករសម្រាប់នាំចេញត្រូវសម្រេច ឲ្យបានយ៉ាងតិច ១លានតោន និងធ្វើឲ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។

ការនាំចេញតាមបណ្តាឆ្នាំកន្លងមក យោងតាមតួលេខពីលេខាធិការដ្ឋានសេវាច្រកចេញចូលតែមួយ សម្រាប់បំពេញបែបបទនាំចេញអង្ករកម្ពុជាឃើញថាមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១. នៅឆ្នាំ ២០១០ នាំចេញបាន | = | ១០៥.២៥៩តោន |
| ២. នៅឆ្នាំ ២០១១ នាំចេញបាន | = | ២០១.៨៩៩តោន |
| ៣. នៅឆ្នាំ ២០១២ នាំចេញបាន | = | ២០៥.៧១៧តោន |
| ៤. នៅឆ្នាំ ២០១៣ នាំចេញបាន | = | ៣៧៨.៨៥៦តោន |
| ៥. នៅឆ្នាំ ២០១៤ នាំចេញបាន | = | ៣៨៧.០៦១តោន |

ដោយឡែក ឆ្នាំ២០១៥ នៅក្នុងរយៈពេល ១០ខែដំបូងនាំចេញបាន ៥០៨.១៦៩តោន កើនឡើង ១៣៣,៩២%បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទោះជាមានការកើនឡើងជាងឆ្នាំមុនលើបរិមាណនាំ ចេញក៏ពិតមែន ប៉ុន្តែយើងឃើញថាថ្លៃអង្ករកម្ពុជា មានតម្លៃថ្លៃជាងអង្ករដែលបាននាំចេញពីបណ្តាប្រទេសជិតខាងដូចជា៖ ប្រទេសវៀតណាម ថៃ ជាដើមក្នុងករណីនេះកម្ពុជាពិតជាពិបាកធ្វើការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ បើយោងតាមគោលការណ៍សម្រាប់ការនាំចេញអង្ករឲ្យបាន ១លានតោននៅឆ្នាំ២០១៥នេះ។

- ការងារអាជីវកម្ម និងវិនិយោគក្នុងឆ្នាំ២០១៥ របស់ក្រុមហ៊ុនគ្រឿនគ្រេង បានលទ្ធផលដូចខាងក្រោម៖
    - ការប្រមូលទិញទំនិញក្នុងឆ្នាំ២០១៥ បរិមាណ ៧.៥៧៩តោន៩២៧ ស្មើនឹងទឹកប្រាក់ ១២.១៤៣.០២៩.៥៥០៛ ស្មើនឹង ១២២,៦៦% នៃផែនការទិញស្មើនឹង ៩៦,៩១% បើធៀបនឹងឆ្នាំ២០១៤
    - ការលក់ចេញសរុបលក់ឆ្នាំ២០១៥ បរិមាណ ៨.៧៧៩តោន២៥៨ ស្មើនឹងទឹកប្រាក់ ១៦.១៩៦.៥០៩.២៧០៛ ស្មើនឹង ១០៣,១០% នៃផែនការទិញស្មើនឹង ១២៤,៨៧% បើធៀបនឹងការអនុវត្តឆ្នាំ២០១៤
    - ការគ្រប់គ្រងស្តុកអង្ករត្រៀមបម្រុងរបស់រាជរដ្ឋាភិបាលគិតត្រឹមថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ មានចំនួន ១២.០០៤តោន៥៣១
    - ចំណូលអាជីវកម្មឆ្នាំ២០១៥ មានចំនួន ១៧.២២៦.៩០៥.០០០៛
    - ចំណាយអាជីវកម្មឆ្នាំ២០១៥ មានចំនួន ១៧.១៩២.៦៦៧.០០០៛
    - ចំណេញសុទ្ធឆ្នាំ២០១៥ មានចំនួន ៨៤.២៣៧.០០០៛

## ២.១៥ ការងារអធិការកិច្ច និងសវនកម្ម

### ២.១៥.១ ការងារអធិការកិច្ច

- ចុះធ្វើអធិការកិច្ចត្រួតពិនិត្យការងារគ្រប់គ្រងរដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រុមហ៊ុនហ្គ្រីនត្រេដ រយៈពេល ២ខែ
- ធ្វើការតាមដាន និងត្រួតពិនិត្យ ការអនុវត្តកែលម្អនូវអនុសាសន៍របស់ក្រុមអធិការកិច្ច ទៅលើអង្គភាពចំនួន ១៥ គឺមន្ទីរពាណិជ្ជកម្មខេត្តកំពត ខេត្តមណ្ឌលគិរី ខេត្តព្រះសីហនុ ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តរតនៈគិរី ខេត្តស្ទឹងត្រែង ខេត្តបាត់ដំបង ខេត្តកែប ខេត្តសៀមរាប ខេត្តកណ្ដាល ខេត្តឧត្ដរមានជ័យ និងខេត្តប៉ៃលិន និងសាខាកាំកុងត្រូលស្វាយរៀង។ រាល់អនុសាសន៍ដែលតម្រូវឱ្យមានការកែលម្អមាន៖
    - កំហុសឆ្គងទាក់ទងនឹងការងារគ្រប់គ្រងរដ្ឋបាលបច្ចេកទេស : ៧ ករណី
    - កំហុសឆ្គងទាក់ទងនឹងការងារគណនេយ្យ ហិរញ្ញវត្ថុ : ១៨ ករណី
    - កំហុសឆ្គងទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ : ១៥ ករណី

    អង្គភាពទាំង ១៥ ខាងលើបានធ្វើការកែលម្អ ដោយបានបញ្ជាក់ជាលាយលក្ខណ៍អក្សរនូវរាល់ចំណុចដែលបានរកឃើញខាងលើនេះ
- ចុះធ្វើអធិការកិច្ច ការអនុវត្តបទបញ្ជាផ្ទៃក្នុង ខ្លឹមសារនៃលិខិតរបស់ក្រសួងពាណិជ្ជកម្ម ស្ដីពីការពង្រឹងការអនុវត្តការងារ និងរបបប្រជុំ បានចំនួន ២០អង្គភាព
- ធ្វើការតាមដានត្រួតពិនិត្យការធ្វើរបាយការណ៍ស្ដីពីការពង្រឹងការអនុវត្តការងារ និងរបបប្រជុំបានចំនួន ៥ខែ ស្មើនឹង២៨អង្គភាព
- ការងារទទួលពាក្យបណ្ដឹង និងដោះស្រាយវិវាទ៖
    - ទទួលការផ្ដល់ព័ត៌មាន និងដោះស្រាយពីភាពអសកម្មរបស់មន្ត្រី និងខ្សែសង្វាក់ការងារនៅក្នុងក្រសួងពាណិជ្ជកម្មបានចំនួន ៣លើក
    - ស្រាវជ្រាវរកមូលហេតុនៃភាពអសកម្មនៅក្នុងអង្គភាពចំណុះទីស្ដីការក្រសួងពាណិជ្ជកម្មបានចំនួន ៣លើក
    - កំពុងដំណើរការតាមដានពាក្យបណ្ដឹងស្ដីពីជំពាក់ប្រាក់ទារមិនទាន់បាននៅមន្ទីរខេត្តកំពតមួយករណី
    - កំពុងតាមដានការវិវត្តនៃភាពមិនប្រក្រតីនៅមន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែងមួយករណី
    - កំពុងធ្វើការតាមដានការអនុវត្តសំណងត្រឡប់មកវិញនូវ
    - ការបាត់បង់នៅក្រុមហ៊ុនហ្គ្រីនត្រេដមួយករណី
- ការងារអធិការកិច្ចលើប្រភពដើមក្នុងការនាំចេញស្រូវអង្ករ៖
    - ដឹកនាំក្រុមការងារដំណើរការរៀបចំសាង ផែនការយុទ្ធសាស្ត្រ សម្រាប់អនុវត្តន៍ក្នុងការងារត្រួតពិនិត្យប្រភពដើមការនាំចេញស្រូវអង្ករទៅបរទេស
    - ដំណើរការសិក្ខាសាលាមួយ ដើម្បីផ្សព្វផ្សាយពីគោលបំណង និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះជូនភាគីពាក់ព័ន្ធនានា
    - កិច្ចការនេះកំពុងស្ថិតនៅក្នុងដំណើរការ និងអនុវត្តន៍បន្ត ។

### ២.១៥.២ ការងារសវនកម្មផ្ទៃក្នុង

- ចុះធ្វើការងារសវនកម្មបានចំនួន ៥៨ អង្គភាពក្នុងនោះមានៈ
  - អង្គភាពថ្នាក់កណ្តាល ០៥ អង្គភាព
  - មន្ទីរពាណិជ្ជកម្មខេត្ត ២៥ អង្គភាព
  - សាខាកាំកុងត្រូល ២២ អង្គភាព
  - តំបន់សេដ្ឋកិច្ចពិសេស ០៥ អង្គភាព
  - ក្រុមហ៊ុនហ្រ្វីនគ្រេដ ០១ អង្គភាព
- លទ្ធផលដែលបានរកឃើញមានដូចខាងក្រោមៈ
  - កង្វះខាតក្នុងការងារគ្រប់គ្រងរដ្ឋបាល (ការរៀបចំរចនាសម្ព័ន្ធចាត់តាំង ការធ្វើតារាងវិភាគមុខងារ ការគ្រប់គ្រងវត្តមានមន្ត្រីរាជការ ការលើកផែនការការងារ និងការធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលការងារតាមការិយាល័យជំនាញនីមួយៗ)
  - កង្វះខាតក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុ (របាយការណ៍សម្រេចទូទាត់រួចរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំឆ្នាំ បញ្ជីបេឡា និងរបាយការណ៍កិច្ចលទ្ធកម្មសាធារណៈ)
  - កង្វះខាតក្នុងការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (បញ្ជីសារពើភ័ណ្ឌគោលឆ្នាំ២០១៤ របាយការណ៍ស្ដីពីការចូលនិងលក់ទ្រព្យសម្បត្តិរដ្ឋ ការធ្វើប័ណ្ណកម្មសិទ្ធលើអចលទ្រព្យ និងកិច្ចជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ)
  - កង្វះខាតក្នុងការងារអនុវត្តន៍ តាមអនុលោមភាពនៃច្បាប់ (ការអនុវត្តស្តង់ដារសេវាសាធារណៈ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ)

## ២.១៦ ការងារសង្គមកិច្ច និងសម្ព័ន្ធភាព

- ចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ សម្ភារៈសាងសង់ និងវិភាគទានដល់ កងទ័ពជើងគោក បញ្ជាការដ្ឋានកាំភ្លើងធំ ខេត្តកំពង់ឆ្នាំងនូវទឹកប្រាក់ចំនួន ៤៦លានរៀល និងថវិកាសាងសង់ទីបញ្ជាការវរសេនាតូចចំនួន ៥៤.៧៩២ដុល្លារសហរដ្ឋអាមេរិក
- ចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ សម្ភារៈសាងសង់ និងវិភាគទានដល់ បញ្ជាការដ្ឋានកងទ័ពជើងគោក យោធភូមិភាគទី៥ ក្នុងទិវានារីអន្តរជាតិលើកទី១០៨ នូវទឹកប្រាក់ចំនួន ៥,៥លានរៀល
- ចុះសួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ សម្ភារៈសាងសង់ និងវិភាគទានដល់ កងពលប្រចាំសមរភូមិទិសប្រាសាទព្រះវិហារ និងទិសទី៣ ក្នុងវង្វង់ទឹកប្រាក់ចំនួន ១០៧លានរៀល
- សួរសុខទុក្ខ និងឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ និងវិភាគទានដល់ បញ្ជាការដ្ឋានអង្គរក្សសម្ដេចតេជោ នូវទឹកប្រាក់ចំនួន ៣២.៤៣៦ដុល្លារសហរដ្ឋអាមេរិក និង៣២លានរៀល
- ឧបត្ថម្ភឧត្តមសេនីយ៍ឯក ព្រហ្ម ផេង នូវស៊ីម៉ង់ត៍ និងស័ង្កសីក្នុងទឹកប្រាក់ចំនួន ៧.១០០ ដុល្លារសហរដ្ឋអាមេរិក
- ឧបត្ថម្ភឧត្តមសេនីយ៍ទោ ឡាយ តាក នូវអាគុយសម្រាប់ប្រើប្រាស់ក្នុងទឹកប្រាក់ចំនួន ៧.៨០០ ដុល្លារសហរដ្ឋអាមេរិក
- ឧបត្ថម្ភឧត្តមសេនីយ៍ ស្រី នឹក នូវស៊ីម៉ង់ត៍ និងដែកក្នុងទឹកប្រាក់ចំនួន ១២.៨៨០ ដុល្លារសហរដ្ឋអាមេរិក

- ឧបត្ថម្ភឧត្តមសេនីយ៍ កែវ ធី ក្នុងការរៀបចំធ្វើលេនដ្ឋានចំនួន ២ និងឧបត្ថម្ភស៊ីម៉ង់ត៍ ៩០តោន ដែលប្រើប្រាស់ទឹកប្រាក់អស់ចំនួន ១៥.២០០ដុល្លារសហរដ្ឋអាមេរិក
- ឧបត្ថម្ភឯកឧត្តមនាយឧត្តមសេនីយ៍ ៣ តាក នូវស៊ីម៉ង់ត៍ និងដែកដែលមានតម្លៃចំនួន ៥.២៥០ ដុល្លារសហរដ្ឋអាមេរិក
- ឧបត្ថម្ភយុវជនអាស៊ានចំនួន ១.០០០ដុល្លារសហរដ្ឋអាមេរិក
- ឧបត្ថម្ភនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចំនួន ៥លានរៀល
- មន្ត្រីក្រសួងពាណិជ្ជកម្មចំនួន ៨០នាក់ចូលរួមធ្វើការបរិច្ចាគឈាមដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម
- រៀបចំកម្មវិធីប្រគុំតន្ត្រីសប្បុរសធម៌ "ពេលវេលាដែលត្រូវតបស្នង" និងបានប្រគល់ថវិកាជូន៖
  - ក្រុមគ្រួសាររបស់លោក ស៊ិន ស៊ីសាមុត ចំនួន ៥៣.៦៧៧ដុល្លារសហរដ្ឋអាមេរិក
  - ក្រុមគ្រួសាររបស់លោកស្រី រស់ សេរីសុទ្ធា ចំនួន ៥.៣៦៧ដុល្លារសហរដ្ឋអាមេរិក
  - សមាគមសិល្បៈករ ចំនួន ១៦.១០៣ដុល្លារសហរដ្ឋអាមេរិក
  - មន្ទីរពេទ្យគន្ធបុប្ផា ចំនួន ២១.៨៧១ដុល្លារសហរដ្ឋអាមេរិក
  - និងមន្ទីរពេទ្យព្រះអង្គឌួង ចំនួន ១០.៧៣៥ដុល្លារសហរដ្ឋអាមេរិក។

## ២.១៧ ការងារយេនឌ័រ

- មន្ត្រីរាជការស្ត្រីចំនួនសរុប ៤៣៦នាក់ ស្មើ ២៥,៥% និងស្ត្រីមានមុខតំណែងតាមតួនាទីមានចំនួនសរុប ១៥៩នាក់ ស្មើនឹង៩,៧%
- សេចក្តីសម្រេច លើការបញ្ជ្រាបយេនឌ័រ បានចាត់បញ្ជូនមន្ត្រីក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម ចូលរួមសកម្មភាព ជាមួយក្រសួងកិច្ចការនារី ក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយដល់ស្ត្រីចំនួន ១២ដង
- ក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្មសម្រេចបាននូវសកម្មភាពបញ្ជ្រាបយេនឌ័រ សម្រាប់អនុវត្តក្នុងឆ្នាំ២០១៥ មាន ៥ ចំណុចដូចខាងក្រោម៖
  - បើកកិច្ចប្រជុំពិភាក្សាពង្រឹងការអនុវត្តការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដែលមានសមាសភាពអ្នកចូលរួមចំនួន ៧៨នាក់ ស្ត្រី៥២នាក់ និងបុរស ២៦នាក់
  - បើកវគ្គផ្សព្វផ្សាយ ស្តីពី "ការបញ្ជ្រាបយេនឌ័រ គោលគំនិតយេនឌ័រ និងអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ" នៅខេត្តស្ទឹងត្រែង ដែលមានសមាសភាពចូលរួមចំនួន៦៧នាក់ ស្ត្រី៤២នាក់និងបុរស២៥នាក់
  - បើកវគ្គបណ្តុះបណ្តាល ស្តីពី "សុវត្ថិភាពចំណីអាហារនិងយេនឌ័រ" នៅខេត្តសៀមរាប ដែលមានអ្នកចូលរួមចំនួន ៦៩នាក់ ស្ត្រី៥០នាក់
  - បើកវគ្គបណ្តុះបណ្តាល ស្តីពី "ការអភិវឌ្ឍស្ត្រីក្នុងវិស័យសហគ្រាសធុនតូចនិងមធ្យមនិងយេនឌ័រ" នៅខេត្តក្រចេះ ដែលមានចំនួន ៦២នាក់ ស្ត្រី៣៩នាក់ និងបុរស២៣នាក់
  - បើកកិច្ចប្រជុំបូកសរុបសកម្មភាពការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៥ និងលើកទិសដៅសកម្មភាពការងារបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្មឆ្នាំ២០១៦ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- ជាមួយគ្នានេះដែរសមាជិកខ្លះ នៃក្រុមការងារយេនឌ័រក្រសួងពាណិជ្ជកម្ម បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះលើគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ លើកកំពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខ

ងារសាធារណៈ ចូលរួមកិច្ចប្រជុំពិភាក្សាព្រាងរបាយការណ៍ជាតិនៃអនុសញ្ញា CEDAW នៃអង្គការសហប្រជាជាតិ និងចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលា ស្តីពីការអភិវឌ្ឍសហគមអាជីវកម្មស្ត្រី របស់ក្រសួងកិច្ចការនារី ព្រមទាំងសិក្ខាសាលារួមអន្តរវិស័យនានាទៀតជាច្រើន។

## ២.១៨ សកម្មភាពការងារមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

### ២.១៨.១ ការងារអាជីវកម្ម

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបាន ១០.៥៨៤ច្បាប់
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម-សេវាកម្ម-ពាណិជ្ជកម្មបានចំនួន ៣.២៤៥ច្បាប់ តាមរយៈការិយាល័យច្រកចេញ-ចូលតែមួយ នៅតាមក្រុង-ស្រុក-ខណ្ឌគោលដៅ
- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មគ្រឿងអលង្ការ លោហធាតុ និងត្បូងថ្មមានតម្លៃបានចំនួន ២.២៩៤ច្បាប់
- ផ្តល់ប្រឹក្សាជួយសម្រួលដល់ពាណិជ្ជករ អាជីវករ ដែលមានបំណងចង់បង្កើតអាជីវកម្ម ការចុះបញ្ជីពាណិជ្ជកម្មសហគ្រាស ក្រុមហ៊ុន ចុះបញ្ជីម៉ាក និងសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រកបអាជីវកម្ម
- ផ្សព្វផ្សាយណែនាំ អំពីតម្រូវការទីផ្សារ ពិសេសចំពោះមុខទំនិញកសិផល ដែលជាតម្រូវការទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ដើម្បីតម្រង់ទិសឲ្យកសិករអាចសម្រេចចិត្តធ្វើការដាំដុះបានត្រឹមត្រូវ ជៀសវាងការធ្លាក់ថ្លៃ និងទំនិញគគស្ទះ
- ចូលរួមសហការជាមួយថ្នាក់ងារកាំកុងត្រូល ធ្វើការត្រួតពិនិត្យអនុលោមភាពបទដ្ឋានបច្ចេកទេសមុខទំនិញម្ហូបអាហារ ទំនិញវេចខ្ចប់ និងស្វែងរកសារធាតុគីមីហាមឃាត់ ដែលអាចប៉ះពាល់សុខភាពអ្នកប្រើប្រាស់។

### ២.១៨.២ ការងារជំរុញពាណិជ្ជកម្ម

- ស្រង់ស្ថិតិថ្លៃទំនិញចាំបាច់សម្រាប់ជីវភាពនៅទីផ្សារ បញ្ជូនជាប្រចាំមកក្រសួង សម្រាប់ប្រើប្រាស់ក្នុងការវិភាគព័ត៌មានពាណិជ្ជកម្ម និងរាយការណ៍ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីប្រចាំសប្តាហ៍
- តាមដានត្រួតពិនិត្យ និងផ្សព្វផ្សាយណែនាំឲ្យមានការបិទស្លាកថ្លៃទំនិញនៅតាមទីផ្សារ ដើម្បីធានាតម្លាភាពរវាងអ្នកទិញ និងអ្នកលក់
- សហការជាមួយគណៈកម្មការរៀបចំពិព័រណ៍ថ្នាក់ខេត្ត រៀបចំពិព័រណ៍ប្រចាំឆ្នាំ និងពិព័រណ៍ភូមិមួយផលិតផលមួយជារៀងរាល់ឆ្នាំ
- ចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិរៀបចំដោយខេត្តសម្ព័ន្ធភាព ដែលធ្វើឡើងនៅតាមខេត្តនៃប្រទេសនីមួយៗ
- រៀបចំពិព័រណ៍ផលិតផលកសិកម្មដោយសហការជាមួយមន្ទីរកសិកម្ម ដើម្បីជំរុញការធ្វើពិពិធកម្មការនាំចេញទំនិញកសិផលកម្ពុជា
- ចូលរួមផ្សព្វផ្សាយការអនុវត្តច្បាប់ពាណិជ្ជកម្មដល់អាជីវករ និងសភាពាណិជ្ជកម្មដើម្បីឲ្យយល់ ដឹងអំពីបញ្ញត្តិច្បាប់ពាណិជ្ជកម្មថ្មីៗ ដែលទើបនឹងកសាង និងដាក់ឲ្យអនុវត្ត
- ចូលរួមក្នុងវេទិកាសាធារណៈដើម្បីស្តាប់នូវសំណូមពររបស់ប្រជាពលរដ្ឋ និងអាជីវករទាក់ទងនឹងវិស័យពាណិជ្ជកម្ម សំដៅផ្តល់នូវដំណោះស្រាយចំពោះមុខទាន់ពេលវេលា និងពាំនាំបញ្ហាមួយចំនួនដែលមិនអាចដោះស្រាយបាន សម្រាប់ជូនថ្នាក់ក្រសួងដោះស្រាយ។

## III. ទិសដៅការងារពាណិជ្ជកម្មឆ្នាំបន្ត

### ៣.១ ការងារអធិការកិច្ច

- អនុវត្តផែនការធ្វើអធិការកិច្ចអង្គភាពនានាក្នុងក្រសួងពាណិជ្ជកម្មប្រចាំឆ្នាំ២០១៦
- បន្តការងារធ្វើអធិការកិច្ចប្រភពដើមទំនិញស្រូវអង្ករនាំចេញទៅបរទេស
- ធ្វើអធិការកិច្ចឆ្លើយតាមគោលដៅនានា ជាពិសេសតាមបណ្តាអង្គភាពចំណុះ ឲ្យទីស្តីការក្រសួងពាណិជ្ជកម្ម
- តាមដាន ការកែលម្អតាមបណ្តាអនុសាសន៍នានា ដែលបានរកឃើញដោយ ក្រុមអធិការកិច្ចនិងអង្គភាពសវនកម្ម ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាអង្គភាព ដែលមានកំហុសឆ្គងពិតជាបានធ្វើការកែលម្អពិតប្រាកដមែន
- បន្តឃ្លាំមើលតាមដានជាប្រចាំ ស្មារតីគោរពវិន័យ ពេលម៉ោងធ្វើការ សណ្តាប់ធ្នាប់ និងអំពីសកម្មភាពអវិជ្ជមាននានាដែលអាចប៉ះពាល់ដល់នយោបាយកំណែទម្រង់របស់ក្រសួងពាណិជ្ជកម្ម
- បន្តតាមដានការគោរពបទបញ្ជាផ្ទៃក្នុង និងការធ្វើរបាយការណ៍កិច្ចប្រជុំផ្ទៃក្នុង ត្រួតពិនិត្យការអនុវត្តការងារ របស់បណ្តាអង្គភាពចំណុះទីស្តីការក្រសួងពាណិជ្ជកម្ម។

### ៣.២ ការងារសវនកម្មផ្ទៃក្នុង

- ធ្វើផែនការសវនកម្មប្រចាំឆ្នាំ២០១៦
- ធ្វើការសិក្សាលើហានិភ័យរបស់អង្គភាពរងសវនកម្ម ដើម្បីកំណត់វិសាលភាពការងារដែលត្រូវអនុវត្តតាមបណ្តាសវនដ្ឋាននីមួយៗ ឆ្នាំ២០១៦
- ចុះធ្វើសវនកម្មនៅតាមអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្មរួមមានៈ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកដ្ឋានកាំកុងត្រូលនិងសាខា តំបន់សេដ្ឋកិច្ចពិសេស និងមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត។

### ៣.៣ ការងាររដ្ឋបាល

- បូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ប្រចាំខែ
- បូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ត្រីមាសទី១
- បូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឆមាសទី១
- បូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ៩ខែដើមឆ្នាំ
- បូកសរុបសកម្មភាពការងារឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម
- រៀបចំសន្និបាតបូកសរុបការងារពាណិជ្ជកម្មប្រចាំឆ្នាំ២០១៦
- រៀបចំពិធីបុណ្យផ្សេងៗ
- កែលម្អសោភ័ណភាពខាងក្នុង និងក្រៅអគារទីស្តីការក្រសួង
- ពង្រឹងបទបញ្ជាផ្ទៃក្នុងក្រសួង និងរៀបចំឲ្យមន្ត្រីពាក់ផ្លាកសម្គាល់ (អត្តសញ្ញាណប័ណ្ណមន្ត្រី)។

### ៣.៤ ការងារមន្ត្រី

- រៀបចំឯកសារតាំងស៊ប់មន្ត្រីកម្មសិក្សា ដែលបានប្រឡងជាប់ចូលបម្រើការងារចំនួន ៦៨នាក់ នៅក្នុងក្របខ័ណ្ឌក្រសួងឆ្នាំ២០១៥

- រៀបចំការដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ដែលចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងឆ្នាំ២០១៦
- ការប្រឡងប្រជែងផ្ទៃក្នុងសម្រាប់ផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការថ្នាក់ជាតិ និងក្រោមជាតិ
- ជំរុញឲ្យបានឆាប់សម្រេចនូវការចេញព្រះរាជក្រឹត្យ អនុក្រឹត្យ ចំពោះមន្ត្រីរាជការដែលបានប្រឡងផ្ទៃក្នុង សម្រាប់ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌឆ្នាំ២០១៥
- រៀបចំកែសម្រួលភារកិច្ច និងតែងតាំងមន្ត្រីដឹកនាំតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន ជំនួសមន្ត្រីចូលនិវត្តន៍ និងមន្ត្រីដែលកំពុងបំពេញភារកិច្ចនៅក្រៅប្រទេស
- រៀបចំស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ ដែលបានបម្រើការងារជូនក្រសួងពាណិជ្ជកម្មឆ្នាំ២០១៥
- សិក្ខាសាលាពង្រឹងសមត្ថភាពដល់មន្ត្រីកម្មសិក្សាថ្នាក់ជាតិ
- បណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងដល់មន្ត្រីជំនាញការងារបុគ្គលិក
- ចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ ប្រកាស និងសេចក្តីណែនាំ របស់រាជរដ្ឋាភិបាល នៅតាមមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- ធ្វើបៀវត្សមូលដ្ឋានដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត។

### ៣.៥ ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា
- លើកគម្រោងផែនការថវិកាក្រសួងឆ្នាំ២០១៧
- ចូលរួមការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០១៧
- រៀបចំប្រកាសអាណាប័កផ្ទេរសិទ្ធិ រដ្ឋបាលកណ្តាល និងរាជធានី-ខេត្ត
- រៀបចំបង់ និងបង្វែរចំណូលថវិកាទៅតាមជំពូក គណនី និងអនុគណនី
- រៀបចំសំណើរការចំណាយប្រចាំខែ និងត្រីមាស
- ពិនិត្យ និងដោះស្រាយសំណើថវិកាតាមបណ្តាអង្គភាព
- រៀបចំប្រកាសអន្តរក្រសួង និងលក្ខខ័ណ្ឌវិនិច្ឆ័យសម្រាប់បង្កើតអង្គភាពថវិកា
- រៀបចំរបាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ
- លើកកម្មវិធីចំណូល-ចំណាយថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំ
- បណ្តុះបណ្តាលមន្ត្រីបញ្ជរ ស្តីពី "ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក"
- ពិនិត្យ និងកែសម្រួលតម្លៃសេវាក្នុងទិសដៅពង្រឹងការប្រមូលចំណូល
- ពិនិត្យឡើងវិញនូវបំណុលចាស់
- ចូលរួមគណៈកម្មការដើម្បីផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌ
- រៀបចំបញ្ជីសារពើភ័ណ្ឌ
- ធ្វើរបាយការណ៍បូកសរុបបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ
- រៀបចំនីតិវិធីដើម្បីបញ្ចូលអគារដែលទើបសាងសង់ហើយក្នុងបញ្ជីសារពើភ័ណ្ឌ
- ចូលរួមត្រួតពិនិត្យ និងតាមដានការបង់ចំណូល និងបំណុលដែលមានភាពយឺតយ៉ាវ
- សិក្សាចងក្រងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងទ្រព្យសម្បត្តិរដ្ឋ
- សិក្សារៀបចំប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

## ៣.៦ ការងារសមាហរណកម្មអាស៊ាន

- សម្របសម្រួលជាមួយអន្តរក្រសួងសិក្សារៀបចំផែនការ និងយុទ្ធសាស្ត្រនានា ដើម្បីចូលរួមអនុវត្តផែនការមេគ្រោងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥
- សម្របសម្រួល សហការរៀបចំឯកសារ ជំនួយស្មារតី សុន្ទរកថា និងអមដំណើរឧត្តមមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន កិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនានា
- សម្របសម្រួលរៀបចំឯកសារគោលជំហរ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចចរចា និងកិច្ចប្រជុំរបស់គណៈកម្មាធិការ និងក្រុមការងារនានា នៅក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ រួមមានៈ ពាណិជ្ជកម្មទំនិញ, ពាណិជ្ជកម្មសេវា, ការសម្រួលពាណិជ្ជកម្មនិងវិធានប្រភពដើមទំនិញ, កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងក្រុមការងារសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០១៥ ជាដើម
- សម្របសម្រួលរៀបចំឯកសារ គោលជំហរ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចចរចាបង្កើនកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូក១ រួមមានៈ ប្រទេសចិន ជប៉ុន កូរ៉េ ឥណ្ឌា អូស្ត្រាលី និងណូវែលហ្សេឡង់។
- សម្របសម្រួលរៀបចំឯកសារគោលជំហរ និងដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមក្នុងកិច្ចចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង សំដៅបញ្ចប់ការចរចា និងដាក់ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ហុងកុងចុះហត្ថលេខានៅចុងឆ្នាំ២០១៦ និងចូលរួមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មីៗ ផ្សេងទៀត
- សម្របសម្រួលរៀបចំឯកសារ គោលជំហរ និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងចូលរួមចរចាវិធានប្រភពដើមទំនិញ នៅក្រោមភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់សំដៅបញ្ចប់ការចរចា និងដាក់ជូនរដ្ឋមន្ត្រី RCEP ចុះហត្ថលេខានៅចុងឆ្នាំ២០១៦
- សិក្សាស្រាវជ្រាវ និងតាមដានអំពីឥទ្ធិពល នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដែលលេចឡើងថ្មីៗ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់នានា ដូចជាសហប្រតិបត្តិការសេដ្ឋកិច្ចប៉ានប៉ុព ខ្សែក្រវាត់មួយផ្លូវមួយ (One Belt One Road) និងភាពជាដៃគូឆ្លងសមុទ្រប៉ាស៊ីហ្វិក (TPP) ជាដើម មកលើសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) និងសេដ្ឋកិច្ចប្រទេសកម្ពុជា
- រៀបចំឯកសារ និងស្នើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ជូនក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មនានារបស់អាស៊ានដែលទើបចរចាចប់
- សម្របសម្រួលបកប្រែ និងរៀបចំឯកសារ ស្តីពីកិច្ចព្រមព្រៀង និងពិធីសារពាណិជ្ជកម្មអាស៊ាន, អាស៊ានបូក១ និង RCEP ដែលបានចុះហត្ថលេខារួច ដើម្បីដាក់ជូនរាជរដ្ឋាភិបាលចូលជាធរមាន ឬដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា សុំសច្ចាប័ន ដើម្បីអនុវត្តកិច្ចព្រមព្រៀង និងពិធីសារទាំងនោះ
- សម្របសម្រួលរៀបចំឯកសារគោលជំហរ ជំនួយស្មារតី សុន្ទរកថា និងអមដំណើរគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចអនុតំបន់ដូចជាៈ កិច្ចប្រជុំក្រុមការងារចរចាកិច្ចព្រមព្រៀងជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV DTA) កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងកិច្ចប្រជុំពាក់ព័ន្ធកិច្ចប្រជុំកំពូល CLV DTA កិច្ចប្រជុំឧត្តមមន្ត្រី រដ្ឋមន្ត្រី កិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គ កិច្ចប្រជុំ

ក្រោមកិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន កិច្ចប្រជុំ AMECS កិច្ចប្រជុំតំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ និងកិច្ចប្រជុំទ្វេភាគីនានា ដូចជា៖ កិច្ចប្រជុំក្រុមការងារចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម កិច្ចប្រជុំគណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-ថៃ

- ទទួលធ្វើជាម្ចាស់ផ្ទះ ឬសហការរៀបចំកិច្ចចរចាពាណិជ្ជកម្ម ដូចជា៖ កិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង, អាស៊ាន-ចិន, កិច្ចប្រជុំការងារចរចាកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មសម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម, កិច្ចប្រជុំកំពូលតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម, កិច្ចប្រជុំក្រុមការងារចរចា កិច្ចព្រមព្រៀងពាណិជ្ជកម្មតាមតំបន់ព្រំដែនកម្ពុជា-វៀតណាម និងប្រជុំផ្សេងៗទៀត
- បន្តចុះផ្សព្វផ្សាយ ស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាននៅតាមខេត្ត-ក្រុងសំខាន់ៗ តាមរយៈការធ្វើសិក្ខាសាលា និងសន្និសីទនានា ដើម្បីណែនាំ និងផ្តល់នូវចំណេះដឹងជូន ប្រជាពលរដ្ឋ មន្ត្រីរាជការ អាជីវករ ផលិតករ អ្នកវិនិយោគ យុវជន និស្សិត-សិស្ស និងអង្គការសង្គម-ស៊ីវិលនានា ដើម្បីឲ្យពួកគេប្រុងប្រៀបរៀបចំខ្លួនចូលរួមនិងធ្វើយុទ្ធសាស្ត្រ រកវិធីដោះស្រាយចំពោះការប្រឈម និងផលប៉ះពាល់នានាលើជីវភាពរស់នៅ ការងារ និងអាជីវកម្មរបស់ពួកគេ ពីការកែទម្រង់ ការប្រកួតប្រជែង ក៏ដូចជាទាញយកឱកាស និងអត្ថប្រយោជន៍ពី សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥
- បន្តផ្សព្វផ្សាយអំពីសហគមន៍សេដ្ឋកិច្ចអាស៊ាន និងអត្ថប្រយោជន៍របស់វានៅតាមប្រទេសសំខាន់ៗ ក៏ដូចជាការចូលរួមផ្លាស់ប្តូរបទពិសោធន៍ អំពីការអនុវត្តសហគមន៍សេដ្ឋកិច្ចអាស៊ាន ដើម្បីធ្វើមូលដ្ឋានកែលម្អគោលនយោបាយសេដ្ឋកិច្ចពាណិជ្ជកម្មជាតិ ឲ្យជឿនលឿនតាមការវិវត្តសហគមន៍អាស៊ាន និងសកលភាវូបនីយកម្ម
- ចូលរួមការពិភាក្សាជាមួយថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន ជំនាញការចំណុះក្រសួងពាណិជ្ជកម្ម និងក្រសួង-ស្ថាប័នផ្សេងៗ អំពីគោលនយោបាយ និងការអភិវឌ្ឍពាណិជ្ជកម្ម
- សហការរៀបចំឯកសារជំនួយស្មារតី សុន្ទរកថា និងបទបង្ហាញនានា ជូនថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹងសេដ្ឋកិច្ចពាណិជ្ជកម្មអាស៊ាន ដៃគូអាស៊ាន និងប្រទេសនានានៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

## ៣.៧ ការងារនៅទ្វីបអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

- រៀបចំកិច្ចប្រជុំ គណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងកម្ពុជា-បេឡារុស ដែលនឹងប្រព្រឹត្តទៅនៅភ្នំពេញ
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងក្រសួង ដើម្បីពិនិត្យ និងពិភាក្សាអំពីរបៀបវារៈសម្រាប់កិច្ចប្រជុំលើកទី៩ នៃក្រុមការងារ កម្ពុជា-សហភាពអឺរ៉ុបស្តីពី ពាណិជ្ជកម្ម នៅទីស្តីការក្រសួង
- សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីរៀបចំកិច្ចប្រជុំលើកទី៩ នៃក្រុមការងារកម្ពុជា-សហភាពអឺរ៉ុបស្តីពីពាណិជ្ជកម្ម ដែលនឹងប្រព្រឹត្តទៅនៅភ្នំពេញ
- សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីរៀបចំកិច្ចប្រជុំ និងឱ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេសរវាងរដ្ឋាភិបាលប៊ុលហ្គារី និងរដ្ឋាភិបាលកម្ពុជានៅទីក្រុងភ្នំពេញ
- ចូលរួមកិច្ចប្រជុំលើកទី២ នៃគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី នៅប្រទេសតួកគី

- រៀបចំអនុស្សរណៈនៃការនាំចេញអង្ករពីកម្ពុជាទៅសហព័ន្ធរុស្ស៊ី និងរៀបចំពិធីចុះហត្ថលេខាដែលនឹងត្រូវចុះហត្ថលេខាដោយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម និងភាគីរុស្ស៊ី
- រៀបចំ និងចូលរួមក្នុងបេសកកម្មពាណិជ្ជកម្មទៅប្រទេសវៀតណាម អាភីប៉ូរម និងដទៃទៀត
- រៀបចំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី៣ រវាងវៀតណាម និងកម្ពុជា នៅវៀតណាម
- ចូលរួមជាភ្ញៀវ ក្នុងការបណ្តុះបណ្តាលមន្ត្រីជំនាញ ដើម្បីបង្កើនសមត្ថភាពចរចា តាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ
- បន្តសិក្សាស្រាវជ្រាវព័ត៌មានទាក់ទងនឹងសភាពការណ៍ និងវឌ្ឍនភាពវិស័យសេដ្ឋកិច្ច នៅតំបន់អឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក ជាពិសេសវិស័យនិងផលិតផលសក្តានុពលសម្រាប់ការពង្រឹង និងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម។

## ៣.៨ ការងារនៅទ្វីបអាមេរិក

- ភ្ជាប់ទំនាក់ទំនងដៃគូពាណិជ្ជកម្មរវាងធុរកិច្ចជនមកពីទ្វីបអាមេរិកជួបជាមួយធុរកិច្ចជនកម្ពុជា
- ធ្វើបច្ចុប្បន្នភាពទីផ្សារពាណិជ្ជកម្ម នៅបណ្តាប្រទេសរបស់ទ្វីបអាមេរិកសម្រាប់ថ្នាក់ដឹកនាំ និងធុរកិច្ចកម្ពុជា
- ជ្រើសរើសសហគ្រាសនាំចេញរបស់កម្ពុជាសម្រាប់ធ្វើការសិក្សាលទ្ធភាពចូលទីផ្សារកាណាដា
- ទិញសម្ភារៈការិយាល័យ និងបរិក្ខារការិយាល័យ (កុំព្យូទ័រ ម៉ាស៊ីនស្កេន តុ ទូដាក់ឯកសារ កៅអី...)
- ផ្សព្វផ្សាយព័ត៌មាន ស្តីពី "មគ្គុទ្ទេសក៍ផ្សារកាណាដាដល់អ្នកនាំចេញកម្ពុជា"
- ផ្សព្វផ្សាយគេហទំព័រ TFO ដាក់ព័ត៌មាននាំចេញទៅកាណាដាដល់សហគ្រាសនាំចេញកម្ពុជា
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការនាំចេញទៅកាណាដា"
- សិក្សាពីលទ្ធភាពចូលទីផ្សារនៃផលិតផលនំស្រួយលីលីផលិតពីអង្ករ និងផ្សព្វផ្សាយ
- សិក្សា ស្តីពី "ការធ្វើពាណិជ្ជកម្មសេរីរវាងកម្ពុជា-កាណាដា និងផ្សព្វផ្សាយ" ស្វែងរកការគាំទ្រពីអ្នកផ្តល់ជំនួយបេសកកម្មជំរុញវិនិយោគ និងធុរកិច្ចជនកម្ពុជាទៅកាន់សហរដ្ឋអាមេរិក
- បេសកកម្មជំរុញវិនិយោគ និងធុរកិច្ចជនកម្ពុជាទៅកាន់កាណាដា
- បេសកកម្មចាប់ផ្តើមទំនាក់ទំនងពាណិជ្ជកម្មជួបជាមួយស្ថានទូតអាហ្សង់ទីន ឈីលី និងប៉ារ៉ាហ្គាយ
- រៀបចំទទួលគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ានមកបំពេញទស្សនកិច្ចនៅកម្ពុជា
- វាយតម្លៃការអនុវត្តឆ្នាំ២០១៦។

## ៣.៩ ការងារអនុបត្តតម្រោច

- គាំទ្រវិទ្យាស្ថានស្តង់ដារកម្ពុជា ក្នុងការទទួលបានលក្ខណៈសម្បត្តិ ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពអង្ករ
- ការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ ASYCUDA ដោយ UNCTAD
- បន្តការគាំទ្រដល់ការអនុវត្តស្វ័យប្រវត្តិកម្ម C/O
- បន្តការគាំទ្រដល់ការអនុវត្តស្វ័យប្រវត្តិកម្មការចុះបញ្ជីពាណិជ្ជកម្ម (ធ្វើលទ្ធកម្មឧបករណ៍ និងសម្ភារៈ)
- បន្តការគាំទ្រដល់ការអនុវត្តស្វ័យប្រវត្តិកម្មការចុះបញ្ជីម៉ាក
- គាំទ្រការអនុវត្តគម្រោងស្វ័យប្រវត្តិកម្មវិញ្ញាបនបត្រភូតគាមអនាម័យ (SPS) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បន្តគាំទ្រគម្រោងមជ្ឈត្តការការងារតាមរយៈមូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្តាល

- បន្តគាំទ្រគម្រោងមជ្ឈត្តការពាណិជ្ជកម្ម តាមរយៈការពង្រឹងលេខាធិការដ្ឋាន
- រៀបចំកិច្ចប្រជុំរវាងថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ជាមួយនាយកប្រតិបត្តិក្រុមហ៊ុន
- រៀបចំការវាយតម្លៃបញ្ចប់គម្រោង TDSP សម្រាប់ Implementation Completion Report
- ពង្រឹងប្រព័ន្ធត្រួតពិនិត្យវាយតម្លៃសម្រាប់អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម (TradeSWAp) រួមទាំង TDSP
- ចុះត្រួតពិនិត្យតាមដាន លទ្ធផលអនុវត្តគម្រោង TDSP របស់ភ្នាក់ងារអនុវត្តគម្រោង
- បន្តអនុវត្តផែនការទំនាក់ទំនង (Communication Plan)
- បន្តគាំទ្រការអនុវត្តគម្រោងរបស់វិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលពាណិជ្ជកម្ម (TTRI)
- ផ្តល់វគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "កំណែទម្រង់របស់ក្រសួងពាណិជ្ជកម្ម (MoC Seminar series)"
- បណ្តុះបណ្តាលដល់បុគ្គលិក DICO នៅលើវគ្គសិក្សា ស្តីពី "ការគ្រប់គ្រងគម្រោង លទ្ធកម្ម ហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និងវាយតម្លៃ"
- បន្តគាំទ្រគម្រោងពង្រឹងសមត្ថភាព DICO និង IAs ស្តីពី "ការគ្រប់គ្រងគម្រោងនិងពាណិជ្ជកម្ម និងការអភិវឌ្ឍក្នុងឆ្នាំ២០១៦-២០២០"
- ធ្វើលទ្ធកម្មផ្តល់សម្ភារៈបរិក្ខារសម្រាប់អាគារថ្មីរបស់ក្រសួងពាណិជ្ជកម្ម
- បន្តធ្វើសវនកម្មផ្ទៃក្នុងផ្នែកហិរញ្ញវត្ថុក្រោមគម្រោង TDSP សម្រាប់ឆ្នាំ២០១៥-២០១៦
- ពង្រឹងយន្តការសមត្ថភាពស្ថាប័ន សម្រាប់រៀបចំគម្រោង អនុវត្តគ្រប់គ្រង និងត្រួតពិនិត្យនូវយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា
- បោះពុម្ព និងផ្សព្វផ្សាយ៖ ព្រឹត្តិប័ត្រ, Trade Swap Facebook, Trade SWAp Website, និងសម្ភារៈផ្សេងៗទៀត (រួមគ្នារវាង EIF និង TDSP)
- បន្តគាំទ្រគម្រោងសូត្រប្រណីតពិសេសការបង្កើត និងពង្រឹងក្រុមប្រឹក្សាជាតិសម្រាប់សូត្រ (តាមរយៈ ITC)
- ពង្រឹងសមត្ថភាពផ្នែកត្រួតពិនិត្យ និងវាយតម្លៃព្រមទាំងការងារផ្សព្វផ្សាយ
- រៀបចំការវាយតម្លៃបញ្ចប់គម្រោង CEDEP I - សមាសភាគអង្ករ និងសូត្រប្រណីត
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ (DICO Retreat)
- បន្តគាំទ្រការអនុវត្តគម្រោងដំឡូងមីតាមរយៈការគាំទ្រក្រុមអ្នកផលិត ការពង្រឹងផ្នែក (SPS) និងការជំរុញការនាំចេញទៅកាន់ទីផ្សារថ្មី
- បន្តគាំទ្រការអនុវត្តគម្រោងផលផលសមុទ្រតាមរយៈការសិក្សាតម្រូវការ ការសាកល្បង ការគាំទ្រក្រុមផលិត ការពង្រឹងគុណភាព និងស្តង់ដាផលិតផលផលផលសមុទ្រ និងការជំរុញការនាំចេញ
- បន្តគាំទ្រការអនុវត្តគម្រោងបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើម្ហូបអាហារ
- ពង្រឹងសមត្ថភាពផ្នែកត្រួតពិនិត្យ និងវាយតម្លៃព្រមទាំងផ្សព្វផ្សាយ
- រៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិគម្រោង CEDEP II
- សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលវាយតម្លៃពាក់កណ្តាលអាណត្តិ
- ចុះពិនិត្យការអនុវត្តគម្រោង CEDEP II
- រៀបចំផែនការរយៈពេលមធ្យម២០១៦-២០១៨
- រៀបចំកិច្ចប្រជុំជាទៀងទាត់នៃគណៈកម្មការនានារបស់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម

- គៀងគរជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តគម្រោងក្រោម TDSP និង EIF-Tier 1
- គៀងគរជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសបន្ថែមទៀតពីដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តគម្រោងក្រោម Trade SWApតាមរយៈគម្រោង TDSP និងEIF
- ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្ត CTIS 2014-2018។

## ៣.១០ ការងារផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់

- បន្តតាមដាន និងជំរុញអន្តរក្រសួង-ស្ថាប័នឲ្យអនុវត្តកម្ម វិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជាផ្អែកលើតម្រូវការរបស់អង្គការពាណិជ្ជកម្មពិភពលោក
- ធ្វើសេចក្តីផ្តល់ព័ត៌មាន អំពីអនាម័យនិងភូតគាមអនាម័យ (SPS Notification) ទៅការិយាល័យចុះបញ្ជីកណ្តាលសម្រាប់ការផ្តល់ព័ត៌មាននៃលេខាធិការដ្ឋានអង្គការ WTO
- ធ្វើសេចក្តីផ្តល់ព័ត៌មានអំពីចំណុចសាកសួរព័ត៌មាន ស្តីពីអនាម័យនិងភូតគាមអនាម័យ (SPS Enquiry Point Notification) ទៅការិយាល័យចុះបញ្ជីកណ្តាលសម្រាប់ការផ្តល់ព័ត៌មាន នៃលេខាធិការដ្ឋានអង្គការ WTO
- រៀបចំមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មពិភពលោក (WTO Reference Center) នៅក្នុងនាយកដ្ឋានផ្តល់ព័ត៌មាននិងផ្ទៀងផ្ទាត់ច្បាប់
- បញ្ជូនអត្ថបទសេចក្តីព្រាងច្បាប់ឧបាស្រ័យពាណិជ្ជកម្មទៅទីស្តីការគណៈរដ្ឋមន្ត្រី
- បន្តចូលរួមពិភាក្សា ផ្តល់យោបល់ពាក់ព័ន្ធនឹងអនុលោមភាព WTO នៅក្នុងសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ របស់អន្តរក្រសួង-ស្ថាប័ន និងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្រិតទ្វេភាគី អនុតំបន់ និងតំបន់ (ផ្អែកតាមការស្នើសុំសាមីស្ថាប័ន)
- តាមដានការអនុវត្តលទ្ធផលនៃសន្និសីទលើកទី១០ នៃរដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោក
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលក្នុងក្របខណ្ឌ WTO លើប្រធានបទមួយចំនួនដូចជា "ការស្វែងយល់អំពីអង្គការពាណិជ្ជកម្មពិភពលោក" និង "ការចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិ ក្រោមប្រព័ន្ធពាណិជ្ជកម្មពហុភាគី" ។ល។

## ៣.១១ ការងារច្បាប់ និងបទបញ្ញត្តិផ្សេងៗ

- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអេ-ពាណិជ្ជកម្ម៖ ពិភាក្សាសេចក្តីព្រាងច្បាប់ជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំសេចក្តីសម្រេចពីគណៈរដ្ឋមន្ត្រី និងបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅ រដ្ឋសភា និងព្រឹទ្ធសភា
- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់៖ ពិភាក្សាសេចក្តីព្រាងច្បាប់ជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំសេចក្តីសម្រេចពីគណៈរដ្ឋមន្ត្រី និងបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅរដ្ឋសភា និងព្រឹទ្ធសភា
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង៖ រៀបចំសេចក្តីព្រាងច្បាប់នៅក្រសួងពាណិជ្ជកម្ម និងពិភាក្សាសេចក្តីព្រាងច្បាប់ ជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំសេចក្តីសម្រេចពីគណៈរដ្ឋមន្ត្រី និងបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅ រដ្ឋសភា និងព្រឹទ្ធសភា

- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម៖ បន្តពិភាក្សាជាមួយក្រសួងយុត្តិធម៌លើសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ចូលក្នុងកិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ការងារដោះស្រាយវិវាទ និងពិគ្រោះយោបល់ផ្នែកច្បាប់៖ បន្តសកម្មភាពលើការងារដោះស្រាយវិវាទ និងពិគ្រោះយោបល់ផ្នែកច្បាប់ដល់ពាណិជ្ជករ-អាជីវករ ក្នុងការស្នើសុំបញ្ជាក់អនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារ លក្ខន្តិកៈបង្កើតក្រុមហ៊ុន និងការកែប្រែលក្ខន្តិកៈថ្មី និងឯកសារតម្រូវ
- ការងារតម្កល់លិខិតជូនដំណឹង ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា៖ បន្តផ្តល់សេវាកម្មតម្កល់លិខិតជូនដំណឹង ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាជូន អ្នកប្រើប្រាស់សេវាតាមរយៈប្រព័ន្ធអ៊ិនធឺណិត និងគេហទំព័រ www.setfo.gov.kh
- ការងារផ្សព្វផ្សាយច្បាប់៖ បន្តធ្វើការផ្សព្វផ្សាយជាបន្តបន្ទាប់នូវច្បាប់ពាណិជ្ជកម្ម ដែលត្រូវបានប្រកាសឲ្យប្រើនាពេលកន្លងមក តាមរយៈការផ្សព្វផ្សាយលើគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម (www.moc.gov.kh) និងរៀបចំឲ្យមានជាសិក្ខាសាលាផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្មនៅ តាមបណ្តារាជធានី-ខេត្តទូទាំងប្រទេស
- ការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត៖ អនុវត្តវិធានការវាយតម្លៃចំពោះផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តិដែលចេញដោយក្រសួងពាណិជ្ជកម្ម។

## ៣.១២ ការងារអភិវឌ្ឍន៍វិស័យឯកជន

- បន្តរៀបចំបង្កើតសមាគមដំឡូងមី តាមបណ្តាខេត្តមួយចំនួនទៀតដូចជា៖ ខេត្តឧត្តរមានជ័យ, ក្រចេះ, បន្ទាយមានជ័យ, និងខេត្តរតនៈគិរី ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងផលិតកម្ម និងបង្កើនគុណភាពផលិតផល និងជួយគ្នាទៅវិញទៅមកក្នុងចំណោមអ្នកដាំដុះ ដើម្បីជំរុញអាជីវកម្ម ទាំងទីផ្សារក្នុងស្រុក-ក្រៅស្រុក និងឈានទៅដល់ការបង្កើតជាសហព័ន្ធដំឡូងមីកម្ពុជា
- បន្តរៀបចំវេទិកាពិគ្រោះយោបល់ វេទិកាវិស័យឯកជន តាមបណ្តាខេត្តដទៃទៀត ដើម្បីផ្សព្វផ្សាយពីកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងពាណិជ្ជកម្ម និងសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន
- បន្តជំរុញអនុវត្តការងារអភិវឌ្ឍន៍ផលិតផលស្ងួត តាមរយៈការរៀបចំផែនការសកម្មភាព និងអនុវត្តការងារអភិវឌ្ឍន៍ផលិតផលស្ងួត តាមមូលដ្ឋានផលិតកម្មសំខាន់ៗ នៅខេត្តចំនួន៥
- ធ្វើបច្ចុប្បន្នភាពឯកសារផលិតផលសក្តានុពលរបស់រាជធានី-ខេត្តទាំង ២៥ និងបន្តការសិក្សាស្រាវជ្រាវសង្វាក់តម្លៃផលិតផលអាទិភាពដែលកំណត់ដោយរាជរដ្ឋាភិបាល
- បន្តតាមដានសន្និធិទំនិញយុទ្ធសាស្ត្រសំខាន់ៗ និងព័ត៌មានទីផ្សារ តាមរយៈកិច្ចសហការជាមួយមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- បន្តជំរុញការចងក្រង និងបង្កើតសមាគមអាជីវកម្មទូទាំងរាជធានី-ខេត្ត តាមរយៈការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការរៀបចំសមាគម និងប្រកាស ឬច្បាប់ ទាំងឡាយទាក់ទងដល់ការបង្កើតសមាគម និងចុះជួយរៀបចំបង្កើតសមាគមអាជីវកម្មពាណិជ្ជកម្មនៅតាមបណ្តារាជធានី-ខេត្ត
- បន្តចុះតាមដាន និងពិនិត្យនូវស្ថានភាពសភាពាណិជ្ជកម្ម និងជំរុញឲ្យបង្កើតនូវមណ្ឌលសភាពាណិជ្ជកម្មថ្មីៗ និងចុះណែនាំ និងពង្រឹងការងារសភាពាណិជ្ជកម្មគ្រប់មណ្ឌល តាមរយៈការរៀបចំបោះឆ្នោតអាណត្តិថ្មី និងអាណត្តិបន្តរបស់មណ្ឌលសភាពាណិជ្ជកម្មរាជធានី-ខេត្ត
- បន្តផ្តល់ប្រឹក្សាបច្ចេកទេស និងជំរុញការអនុវត្តការងារអោយមានប្រសិទ្ធភាព ដល់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តទាំង២៥។

## ៣.១៣ ផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

- ពង្រឹងការងាររដ្ឋបាល ធ្វើកិច្ចសម្របសម្រួល ការងារបច្ចេកទេសផែនការស្ថិតិ និងព័ត៌មានពាណិជ្ជកម្មនានា ពាក់ព័ន្ធការងារមន្ត្រីក្នុងនាយកដ្ឋាននិងវិស័យពាណិជ្ជកម្ម
- រៀបចំឯកសារ និងលើកគម្រោងចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- កំពុងរៀបចំផែនការសកម្មភាព និងការងារពាណិជ្ជកម្មឆ្នាំ២០១៦ ដាក់ជូនថ្នាក់ដឹកនាំក្រសួងឲ្យទាន់ពេលវេលា
- ត្រៀមអនុវត្តផែនការសកម្មភាពការងាររបស់នាយកដ្ឋាន ដើម្បីឆ្លើយតបទៅនឹងថវិកាកម្មវិធី ដែលបានដាក់ស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅដើមឆ្នាំ២០១៦
- ពង្រាងមាតិកា "ផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មឆ្នាំ២០១៩ - ២០២៣" និងដាក់ជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំការពិនិត្យ និងសម្រេចនៅដើមឆ្នាំ២០១៦
- រៀបចំឲ្យមានយន្តការ និងផែនទីផ្លូវនៃការអនុវត្តការងារលើការ "កសាងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មឆ្នាំ២០១៩-២០២៣" ឲ្យមានប្រសិទ្ធភាពខ្ពស់
- ចងក្រងនូវវឌ្ឍនភាពនៃការកសាង "ផែនការយុទ្ធសាស្ត្រពាណិជ្ជកម្ម" ឲ្យមានលក្ខណៈបច្ចុប្បន្នភាព និងត្រឹមត្រូវសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តប្រសើរជាងមុនក្នុងការធ្វើពាណិជ្ជកម្ម ស្រាវជ្រាវ និងក្នុងគោលបំណងអភិវឌ្ឍន៍
- ខិតខំអភិវឌ្ឍគេហទំព័ររបស់ក្រសួងឲ្យបានល្អបន្ថែមទៀត និងបច្ចុប្បន្នភាពព័ត៌មានពាណិជ្ជកម្មសំបូរបែប
- ខិតខំរកវិធីសាស្ត្រក្នុងការគ្រប់គ្រង Internet របស់ក្រសួង និងដោះស្រាយបញ្ហាប្រព័ន្ធ Internet ទាំងមូល
- ដើម្បីធានាឲ្យបាននូវការប្រើប្រាស់ឲ្យត្រូវទិសដៅ ដោយរកវិធីគ្រប់គ្រងប្រើប្រាស់កម្មវិធីដើម្បីគ្រប់គ្រងអ្នកប្រើប្រាស់ទាំងអស់
- បង្កើនសមត្ថភាពជំនាញមន្ត្រីក្នុងកិច្ចការពារការជ្រៀតចូល និងវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យាពីសំណាក់ជនអនាមិក
- បង្កើត Database សម្រាប់គ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងពាណិជ្ជកម្មទាំងមូលជាប្រព័ន្ធ
- បង្កើនសមត្ថភាពមន្ត្រីព័ត៌មានវិទ្យា(IT) ឲ្យបានច្រើនសម្រាប់គ្រប់គ្រងជំនាញលើព័ត៌មានវិទ្យា
- ខិតខំប្រឹងប្រែងស្រាវជ្រាវបន្ថែមទៀតសម្រាប់បច្ចេកវិទ្យាព័ត៌មានថ្មីៗ
- បង្កើតកម្មវិធីគ្រប់គ្រងទិន្នន័យស្ថិតិពាណិជ្ជកម្មតាមបណ្តាច្រកព្រំដែន និងផែស្ងួតមួយចំនួន
- សិក្សាលើប្រព័ន្ធគ្រប់គ្រងស្កេនមេដៃដែលមានស្រាប់ ឲ្យក្លាយទៅជាប្រព័ន្ធគ្រប់គ្រងវត្តមានមួយមានតម្លាភាពជាក់លាក់ និងជាក់ស្តែង
- សិក្សាលើប្រព័ន្ធគ្រប់គ្រងស្កេនមេដៃដែលមានស្រាប់ ហើយធ្វើកំណែប្រែបើសិនជាអាច។

## ៣.១៤ បណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

- បន្តការងាររៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ កម្មវិធីបណ្តុះបណ្តាល និងគ្រប់គ្រងរដ្ឋបាលរបស់វិទ្យាស្ថាន
- កែលម្អថ្នាក់រៀន បន្ទប់សិក្សាស្រាវជ្រាវ បណ្ណាល័យ របស់វិទ្យាស្ថាន ព្រមទាំងបំពាក់ សម្ភារៈបរិក្ខារភ្ជាប់បណ្តាញ Network កុំព្យូទ័រ និងរៀបចំគម្រោងជួសជុលថែទាំសម្ភារៈបរិក្ខារទាំងនេះ

- រៀបចំវគ្គបណ្តុះបណ្តាលពាណិជ្ជកម្មរយៈពេលខ្លីរួមមាន៖ វគ្គសិក្សាស្តីពី ការប្រាស្រ័យទាក់ទងពាណិជ្ជកម្ម និងជំនាញក្នុងការចរចា ការយល់ដឹងអំពីអង្គការពាណិជ្ជកម្មពិភពលោកនិងអាស៊ាន ការស្នើសុំវិញ្ញាបនបត្រប្រភពដើមទំនិញ ការចុះបញ្ជីពាណិជ្ជកម្ម ការអភិវឌ្ឍសហគ្រាសខាតតូចនិងជំនាញយុទ្ធសាស្ត្រផ្សព្វផ្សាយ ច្បាប់វិនិយោគនិងច្បាប់ធុរកិច្ចសហគ្រិន ច្បាប់ពាណិជ្ជកម្មអន្តរជាតិនិងច្បាប់ស្តីពីកិច្ចសន្យា ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ការងារកស្តុភាពពាណិជ្ជកម្ម សហគមន៍សេដ្ឋកិច្ចអាស៊ាននិងសមាហរណកម្មក្នុងតំបន់ ភាពជាដៃគូរបស់សហគ្រាសធុនតូច និងមធ្យម ការជំរុញពាណិជ្ជកម្មនិងការអភិវឌ្ឍផលិតផល
- រៀបចំវគ្គបណ្តុះបណ្តាលរយៈពេលវែងតាមកម្មវិធីសិក្សាពាណិជ្ជកម្មរួមមាន៖ វគ្គសិក្សាស្តីពីស្ថាប័នពាណិជ្ជកម្មអន្តរជាតិ សេចក្តីផ្តើមនៃស្ថាប័នគាំទ្រពាណិជ្ជកម្ម ហិរញ្ញប្បទានពាណិជ្ជកម្ម និងវិធាននៃការនាំចេញនាំចូល សេចក្តីផ្តើមគោលនយោបាយពាណិជ្ជកម្ម វិធានស្តីពីអនាម័យ និងភូតគាមអនាម័យ ។ល។
- រៀបចំវគ្គបណ្តុះបណ្តាលមូលដ្ឋានរួមមាន៖ វគ្គសិក្សាស្តីពី កុំព្យូទ័រ និងប្រព័ន្ធព័ត៌មានវិទ្យា និងភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម
    - សិក្សាស្រាវជ្រាវដើម្បីផ្តល់ព័ត៌មានអំពីនិន្នាការអនាគតនៃផលិតផល ដែលមានសក្តានុពលរបស់កម្ពុជាដល់ប្រជាកសិករ
    - សិក្សាស្រាវជ្រាវការធ្វើពិពិធកម្មសេដ្ឋកិច្ចក្រៅពីវិស័យទេសចរណ៍នៅខេត្តសៀមរាប
    - ធ្វើការផ្សព្វផ្សាយលទ្ធផលនៃស្នាដៃស្រាវជ្រាវផ្នែកសេដ្ឋកិច្ចផ្សេងៗក្នុងតំបន់
- ចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI), វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់ពាណិជ្ជកម្ម (ERIT) នៃប្រទេសឡាវ វិទ្យាស្ថានអន្តរជាតិសម្រាប់ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (ITD) នៅប្រទេសថៃ ដើម្បីសហការផ្លាស់ប្តូរបទពិសោធន៍ក្នុងការបណ្តុះបណ្តាល និងស្រាវជ្រាវ
- បង្កើតបណ្ណាល័យអេឡិចត្រូនិច (E-Library) និងបំពាក់សៀវភៅ ព្រមទាំងឯកសារផ្សេងៗ នៅក្នុងបណ្ណាល័យ និងបង្កើតបន្ទប់សន្និសីទវីដេអូ (Video Conference Room) របស់វិទ្យាស្ថាន
- រៀបចំប្រព័ន្ធគ្រប់គ្រង ការប្រមូលទិន្នន័យ និងឯកសារសម្រាប់ការបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិច (E-learning)។

## ៣.១៥ ការងារចុះបញ្ជីពាណិជ្ជកម្ម

- បញ្ចូលទិន្នន័យនៃការចុះបញ្ជីពាណិជ្ជកម្មទាំងអស់ដែលមានក្នុងបញ្ជីពាណិជ្ជកម្ម ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្មថ្មី៖
    - រៀបចំប្រកាស ស្តីពី "ការចុះបញ្ជីឡើងវិញចំពោះក្រុមហ៊ុនដែលបានចុះបញ្ជីរួចហើយ"
    - ចុះបញ្ជីឡើងវិញនូវក្រុមហ៊ុនដែលបានចុះបញ្ជីរួចហើយក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម
- កំណត់លិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីទ្រទ្រង់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
    - រៀបចំកែសម្រួលប្រកាស ស្តីពី "ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម" ប្រកាស ស្តីពី "ការចុះបញ្ជីលើការកែប្រែ" និងប្រកាស ស្តីពី "ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ"
    - រៀបចំសេចក្តីជូនដំណឹងពាក់ព័ន្ធការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ស្នើសុំធ្វើវិសោធនកម្មច្បាប់ដែលពាក់ព័ន្ធការងារចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម៖
    - ស្នើសុំធ្វើវិសោធនកម្មច្បាប់ ស្តីពី "វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម"

- ស្នើសុំធ្វើវិសោធនកម្មច្បាប់ ស្តីពី "សហគ្រាសពាណិជ្ជកម្ម"

- ស្នើសុំការអនុម័តលើការកែសម្រួលរចនាសម្ព័ន្ធរបស់នាយកដ្ឋាន៖
  - រៀបចំកែសម្រួលប្រកាស ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជី"
  - រៀបចំវិភាគមុខងារមន្ត្រីតាមរចនាសម្ព័ន្ធថ្មីរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- ធ្វើការផ្សព្វផ្សាយការងារចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម៖
  - ធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំ ស្តីពី "ការចុះបញ្ជីពាណិជ្ជកម្ម"
  - បោះពុម្ពផ្សាយសៀវភៅណែនាំស្តីពី "ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម"
- បណ្តុះបណ្តាលមន្ត្រីដែលត្រូវអនុវត្តការងារចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម៖
  - បណ្តុះបណ្តាលមន្ត្រី នាយកដ្ឋានលើការអនុវត្តការងារ ចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
  - បណ្តុះបណ្តាលមន្ត្រីមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត លើការអនុវត្តការងារចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ពង្រីកការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ៖
  - សហការជាមួយក្រសួង-ស្ថាប័នលើការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម
  - សហការជាមួយស្ថាប័នឯកជនលើការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម
- បន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការសម្របសម្រួលដល់ការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យមក្រោមក្របខណ្ឌដំបូលតែមួយ៖
  - ត្រៀមបញ្ជូនមន្ត្រីទៅបំពេញការងារនៅយន្តការសម្របសម្រួលដល់ការចុះបញ្ជីពាក់ព័ន្ធនឹងសហគ្រាសធុនតូចនិងមធ្យម ក្រោមក្របខណ្ឌដំបូលតែមួយ
  - បំពាក់សម្ភារៈដើម្បីដំណើរការអនុវត្តស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម នៅយន្តការសម្របសម្រួលដល់ការចុះបញ្ជីពាក់ព័ន្ធសហគ្រាសធុនតូចនិងមធ្យមក្រោមក្របខណ្ឌដំបូលតែមួយ
- បន្តផ្តល់សេវាតម្កល់លិខិតជូនដំណឹងស្តីពីប្រតិបត្តិការដែលមានកិច្ចធានាជូនដល់ អ្នកប្រើប្រាស់សេវាតាមរយៈប្រព័ន្ធអ៊ីធឺណិត៖
  - ធ្វើឲ្យកាន់តែប្រសើរឡើង នូវប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជី និងតម្កល់លិខិតជូនដំណឹង ស្តីពី "ប្រតិបត្តិការដែលមានកិច្ចធានា"
  - បន្ថែមមុខងារចុះបញ្ជីភតិសន្យាហិរញ្ញវត្ថុក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បំពាក់សម្ភារៈបច្ចេកវិទ្យាទំនើបនិងរៀបចំបណ្តាញណេតវើក ដើម្បីដំណើរការអនុវត្តស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម។

## ៣.១៦ ការចារកម្មសិទ្ធិបញ្ញា

- ពិនិត្យ និងអនុវត្តឲ្យមានប្រសិទ្ធភាព នូវប្រកាសដែលបានរៀបចំនៅឆ្នាំ២០១៥ ដូចជា៖ (១) ប្រកាសស្តីអំពីនីតិវិធីចុះបញ្ជីម៉ាកសម្គាល់ចរិកលក្ខណៈទំនិញ និងសេវា (២) ប្រកាសស្តីពី នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ (៣) ប្រកាសស្តីអំពី នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (៤) ប្រកាសស្តីអំពីការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ (៥) ប្រកាសស្តីអំពីនីតិវិធីលម្អិតក្នុងការចុះបញ្ជីម៉ាក និងគ្រប់គ្រងម៉ាក (៦) ប្រកាសរួមស្តីអំពីការកែសម្រួលកម្រៃសេវាសាធារណៈពាក់ព័ន្ធនឹងការងារកម្មសិទ្ធិបញ្ញា។

- សហការជាមួយអង្គការ WIPO ដើម្បីបន្តបណ្តុះបណ្តាលគ្រូបង្គោលកម្មសិទ្ធិបញ្ញា សម្រាប់បន្តនិរន្តភាពនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា ដែលគ្រោងនឹងបង្កើតឡើងនៅឆ្នាំ២០១៨
- បង្កើត Technology Innovation Support Center (TISC) ក្នុងគោលបំណងបង្កើនការយល់ដឹងកម្មសិទ្ធិបញ្ញាដល់សាធារណៈជន
- អនុវត្តផែនការការងាររបស់អាស៊ាន ២០១៦-២០២៥ (ASEAN IPR Action Plan 2016-2025) ដែលបានបង្កើតឡើងដោយ AWGIPC
- ជួយសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម ក្នុងការរៀបចំចូលជាសមាជិកនៃ Patent Cooperation Treaty (PCT)
- ជំរុញដោះស្រាយរាល់វិវាទទាក់ទិននឹងការរំលោភបំពាន និងការលុបម៉ាកដែលនៅសេសសល់
- បង្កើនសមត្ថភាពយល់ដឹង លើផ្នែកភាសាអង់គ្លេស កុំព្យូទ័រ និងកម្មសិទ្ធិបញ្ញាដល់មន្ត្រី តាមរយៈការបញ្ជូនទៅសិក្សាទាំងក្នុង និងក្រៅប្រទេស
- រៀបចំទម្រង់ពាក្យស្នើសុំចុះបញ្ជី ម៉ាកបញ្ជាក់ពីចរិកនិងលក្ខណៈទំនិញ និងសេវា Certification Mark
- ជំរុញការចុះបញ្ជី ម៉ាកសមូហភាព Collective Mark
- ជំរុញការសិក្សាបន្ថែម និងស្វែងរកដៃគូរលើផលិតផលដែលបានកំណត់អត្តសញ្ញាណរួចហើយដូចជា អង្ករផ្កាម្លិះតោលបាត់ដំបង ប្រហុកសៀមរាប ក្រូចពោធិសាត់ ត្រីរាំងពោធិសាត់ ស្ករត្នោតស្រុកទឹកឃ្មុំមណ្ឌលគិរី ធូរេនកំពត មៀនប៉ៃលិន អង្ករក្រហមស្វាយរៀង ដើម្បីឈានទៅរកការចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- ជួយសម្របសម្រួលការប្រមូលទិន្នន័យឱសថបុរាណ (Traditional Medicines) ដោយសហការជាមួយក្រសួងសុខាភិបាល
- ពិនិត្យមើលសេចក្តីព្រាងច្បាប់ ស្តីពី "ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម Trade Secrets and Undisclosed Information"
- រៀបចំប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយបណ្តឹង និងនីតិវិធីដោះស្រាយទំនាស់តាមមាត្រា ២៨ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់
- ពិនិត្យ មើលសេចក្តីព្រាងអនុក្រឹត្យ ដើម្បីអនុវត្តច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បន្តកិច្ចប្រជុំចរចា ស្តីពីភាពជាដៃគូពាណិជ្ជកម្មទូលំទូលាយប្រចាំតំបន់ (RCEP) លើផ្នែកកម្មសិទ្ធិបញ្ញាតាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង។

## ៣.១៧ ការងារសេវាពាណិជ្ជកម្ម

- ចូលរួមប្រជុំទាក់ទងនឹងវិធានប្រភពដើមទំនិញ
- សហការ និងចូលរួមចុះធ្វើអង្កេត ប្រភពដើមទំនិញជាមួយគយនៃប្រទេសផ្តល់ភាពអនុគ្រោះពាណិជ្ជកម្ម
- តាមដាន និងស្រាវជ្រាវបទបញ្ញត្តិពាក់ព័ន្ធនឹងវិធានប្រភពដើមទំនិញ និងការអនុវត្តប្រព័ន្ធ GSP របស់ប្រទេសមួយចំនួន

- កែលម្អប្រព័ន្ធព័ត៌មានវិទ្យា និងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មពេញលេញ សម្រាប់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- ដាក់ឲ្យអនុវត្តនូវការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ការប្រមូលកម្រៃសេវាសាធារណៈ និងកម្រៃនានារបស់ក្រសួង
- បន្តអនុវត្តគម្រោងសាកល្បង នៃការប្រើប្រាស់វិក្កយបត្រ សម្រាប់ធ្វើប្រតិវេទន៍ស្វ័យប្រវត្តិកម្មបញ្ជាក់ប្រភពដើមទំនិញក្នុងក្របខណ្ឌអាស៊ាន
- សហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីវឌ្ឍនភាពនៃវិធានប្រភពដើមទំនិញគ្រប់ទិសដៅនាំចេញ
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស រវាងក្រុមការងារក្រសួងពាណិជ្ជកម្ម ក្រុមការងារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមការងារនៃគម្រោងរោងចក្រកាន់តែប្រសើរ (BFC) ក្រុមការងារ GMAC និងរោងចក្រកាត់ដេរ Low Compliance
- បន្តចូលរួម ជាមួយ ILO និងមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះពិនិត្យរោងចក្រដែលអនុវត្តលក្ខខណ្ឌការងារនៅមានកម្រិតទាប
- សហការជាមួយអន្តរក្រសួងក្នុងការទប់ស្កាត់ការនាំចេញឈើខុសច្បាប់ និងចូលរួមប្រជុំរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ថ្នាក់ជាតិបង្ការ ទប់ស្កាត់ និងបង្រ្កាបការកាប់ ការដឹកជញ្ជូន ការប្រមូលការស្តុកទុក និងការនាំចេញឈើក្រញូង
- ពង្រឹងការគ្រប់គ្រងការនាំចូលមុខទំនិញ ស្ថិតក្នុងបញ្ជីមុខទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់របស់រាជរដ្ឋាភិបាល ស្របតាមអនុក្រឹត្យលេខ២០៩ និងលិខិតបទដ្ឋានជាធរមាននានា
- សហការជាមួយប្រទេសសមាជិកនៃអង្គការគីមប៊ែរលី (Kimberly) ដើម្បីធានាការគ្រប់គ្រងការនាំចេញ-នាំចូលត្បូងពេជ្រមិនទាន់កែច្នៃ
- ចូលរួមប្រជុំជាមួយប្រទេសសមាជិកនៃអង្គការគីមប៊ែរលី (Kimberly) ដើម្បីផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មាន
- ពង្រឹងការអនុវត្តការចុះប្រមូលទិន្នន័យ ពីរោងចក្រកាត់ដេរសំលៀកបំពាក់-ស្បែកជើង និងរោងចក្រ-សហគ្រាសផ្សេងទៀត ដើម្បីចងក្រងស្ថិតិផ្លូវការ
- ជំរុញការងារចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិវត្ថុធាតុដើមតាមបណ្តារោងចក្រ ស្របតាមសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម លេខ ០០៥១ MOC/SM 2011 ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១១
- ពង្រឹងការអនុវត្តការប្រមូលចំណូលសេវាសាធារណៈតាមបញ្ញត្តិកំណត់ ជាពិសេស EMF និងពិនិត្យមុខទំនិញថ្មីបន្ថែមទៀត
- បន្តការចុះបញ្ជីប្រើប្រាស់ ប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ចំពោះក្រុមហ៊ុននៅសេសសល់
- កត់ត្រា និងបញ្ចូលទិន្នន័យនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- ចូលរួមសហការ ក្នុងការកសាងបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធផលិតផលម្ហូបឥស្លាម (Halal Food)
- ពង្រឹងការគ្រប់គ្រងការនាំចូលថ្នាំងក្រណាត់ និងវត្ថុធាតុដើមសម្រាប់ផលិតបម្រើការនាំចេញ
- បន្តចុះបញ្ជីសុំសិទ្ធនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

- តាមដានការងារផ្ទួលផលិត (Sub-Contract) តាមប្រកាសអន្តរក្រសួងលេខ៣៨៥៦MOC/SM2011 របស់ក្រសួងពាណិជ្ជកម្ម
- ជំរុញការងារបណ្តុះបណ្តាលបច្ចេកទេសជំនាញដល់មន្ត្រីរាជការ
- តាមដានត្រួតពិនិត្យការក្លែងបន្លំឯកសារនាំចេញឈើទៅក្រៅប្រទេស
- រៀបចំបែបបទពាក់ព័ន្ធ ទៅនឹងការស្នើសុំឆ្លងកាត់ទំនិញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល និងកិច្ចព្រមព្រៀងនានាជាលក្ខណៈទ្វេភាគី និងពហុភាគី
- បន្តចូលរួមកិច្ចប្រជុំក្រុមការងារផ្នែកច្បាប់ និងបច្ចេកទេស នៃក្រុមការងារចម្រុះអន្តររដ្ឋាភិបាលបណ្តោះអាសន្នសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម កាត់បន្ថយការប្រើក្រដាសស្នាម តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃ UNESCAP។

## ៣.១៨ ការទារជំរុញពាណិជ្ជកម្ម

- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស
- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស
- សម្របសម្រួល និងជំរុញឲ្យមានព្រឹត្តិការណ៍ពាណិជ្ជកម្ម
- ចូលរួមសន្និបាតការិយាល័យពិព័រណ៍អន្តរជាតិ (BIE)
- ចូលរួមប្រជុំជាលក្ខណៈបច្ចេកទេសត្រៀមរៀបចំចូលរួមពិព័រណ៍អន្តរជាតិ ឆ្នាំ២០១៧ កាស្សាក់ស្ថង់
- រៀបចំ និងចូលរួមពិព័រណ៍អន្តរជាតិ ឆ្នាំ២០១៧ នៅទីក្រុងអាស្តាណា ប្រទេសកាស្សាក់ស្ថង់
- បន្តការណែនាំ និងចុះពង្រឹងការអនុវត្តន៍ប្រកាសលេខ 162 MOC/SM 2013 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ របស់ក្រសួងនៅទូទាំងប្រទេស
- ពង្រឹងការប្រមូលចំណូលពីការចាត់ចែង និងរៀបចំពិព័រណ៍ជូនរដ្ឋឲ្យមានប្រសិទ្ធភាពសម្រាប់ឆ្នាំបន្តបន្ទាប់
- បន្តរៀបចំនីតិវិធី និងឯកសារគតិយុត្តដើម្បីបញ្ជូនសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងផលិតផលហាឡាលកម្ពុជា
- រៀបចំសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតក្រុមឯកទេសផលិតផលហាឡាលកម្ពុជា ដើម្បីដំណើរការរៀបចំនីតិវិធីសម្រាប់វិនិច្ឆ័យកំណត់ស្តង់ដារផលិតផលហាឡាលកម្ពុជា
- បន្តចុះស្រាវជ្រាវលើផលិតផលម្រេចនៅតាមបណ្តាខេត្តគោលដៅ ដើម្បីកំណត់ពីខ្សែចង្វាក់ផលិតកម្មម្រេច ការផ្គត់ផ្គង់ និងបញ្ហាប្រឈមផ្សេងៗ ដើម្បីកំណត់ទិសដៅ និងដាក់ចេញជាគោលនយោបាយតម្រង់ទិសក្នុងការនាំចេញផលិតផលម្រេចទៅកាន់ទីផ្សារអន្តរជាតិ
- បន្តធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងរៀបចំសន្និសីទថ្នាក់ជាតិពាក់ព័ន្ធនឹងការជំរុញដល់កសិកម្មការផ្សព្វផ្សាយពីច្រកទីផ្សារថ្មី ក៏ដូចជាផ្សព្វផ្សាយអំពីកម្មវិធីកែទម្រង់របស់ក្រសួងឲ្យដល់ភាគីពាក់ព័ន្ធ ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេទទួលបានពត៌មានទីផ្សារថ្មីៗ ក៏ដូចជាកម្មវិធីកែទម្រង់របស់ក្រសួងពាក់ព័ន្ធ និងការសម្រួលពាណិជ្ជកម្ម

- ក្រសួងនឹងបន្តចូលរួមក្នុងវេទិកាជំរុញពាណិជ្ជកម្មរបស់តំបន់ ដើម្បីចែករំលែកនិងទទួលបទពិសោធន៍ថ្មីៗពាក់ព័ន្ធនឹងការងារជំរុញពាណិជ្ជកម្មក៏ដូចជា ដើម្បីជួយជំរុញសហប្រតិបត្តិការរវាងអង្គជំរុញពាណិជ្ជកម្មកម្ពុជាជាមួយស្ថាប័នជំរុញពាណិជ្ជកម្មរបស់ប្រទេសនីមួយៗ ក្នុងតំបន់
- រៀបចំគម្រោងស្នើសុំ ជំនួយបច្ចេកទេសពីដៃគូពាណិជ្ជកម្មអន្តរជាតិ លើការរៀបចំសេចក្តីព្រាងបង្កើតយុទ្ធសាស្ត្រជំរុញពាណិជ្ជកម្ម និងការរៀបចំកម្មវិធីភ្ជាស់សហគ្រាសធុនតូច និងមធ្យម ដើម្បីផ្តល់លទ្ធភាពឱ្យ SMEs អាចពង្រីកខ្លួនសម្រាប់ការប្រកួតប្រជែងក្នុងទីផ្សារ
- ការរៀបចំ និងចាត់ចែងវេទិការ ជំនួបពាណិជ្ជកម្មសម្រាប់ពាណិជ្ជករក្នុងស្រុក វេទិការជំនួបពាណិជ្ជកម្មសម្រាប់ពាណិជ្ជករបរទេស និងពាណិជ្ជករក្នុងស្រុក
- កិច្ចការជំនួបពាណិជ្ជកម្ម ដល់គណ:ប្រតិភូពាណិជ្ជកម្មបរទេសនៅកម្ពុជា តាមរយៈការងារជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន , មជ្ឈមណ្ឌល អាស៊ាន-កូរ៉េ, មជ្ឈមណ្ឌលអាស៊ាន-ចិន,មជ្ឈមណ្ឌលអាស៊ាន-ឥណ្ឌា ប្រទេសវៀតណាម (VIETRADE: Viet Nam Trade Promotion), ប្រទេសថៃ (DITP: Department of Internation Trade Promotion), ហុងកុង (HKTDC: Hong Kong Trade Development Council), ប្រទេសម៉ាឡេស៊ី (MATRADE: Malasia External Trade Department Copperation ), ប្រទេសចិន (CCPIT:China Council for the Promotion of International Trade), ប្រទេសជប៉ុន (JETRO: Japan Internal Trade Organization), ប្រទេស កូរ៉េ (KOTRA: Korea Trade Investment Promotion Agency)សមាគមជំរុញកិច្ចខេត្តយូណាន់ (ECTPA: Association of Economic Cooperation and Trade Promotion Between Yunnan and South-East and South Asia ) សហរដ្ឋអាមេរិក និងស្ថាប័នជំរុញពាណិជ្ជកម្មផ្សេងៗ ទៀត
- សិក្សានិងស្រាវជ្រាវពីព័ត៌មានស្តីពីស្ថានភាពទីផ្សារនៅតាមបណ្តារាជធានី-ខេត្ត និងព្រំដែននាំចេញ
- ស្រាវជ្រាវ និងចងក្រង ផលិតផលថ្មីៗដែលជាសក្តានុពលបម្រើទីផ្សារក្នុងស្រុក និងនាំចេញ។
- សិក្ខាសាលាដើម្បីដាក់និតផ្តួចផ្តើម ក្នុងការរៀបចំយុទ្ធសាស្ត្រទីផ្សារសម្រាប់ទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ
- សិក្សា និងស្រាវជ្រាវព័ត៌មានសំខាន់ស្តីពីទីផ្សារនៅក្រៅប្រទេសដូចជា: ចិន ថៃ វៀតណាម អឺរ៉ុប និងដំទៃទៀត
- សិក្សា និងចងក្រងអត្តសញ្ញាណផលិតផល (Branding) លើផលិតផលសក្តានុពលមួយចំនួនដូចជា: អង្ករ ម្រេច និងកសិផលផ្សេងៗ ដើម្បីផ្សព្វផ្សាយលើទីផ្សារ
- ធ្វើជាចំនុចប្រសព្វ សម្រាប់កិច្ចការពាណិជ្ជកម្មក្នុង និងក្រៅប្រទេស តាមរយ:ស្ថានតំណាងពាណិជ្ជកម្ម
- រៀបចំវេទិកាជំនួបពិភាក្សាដោយផ្ទាល់រវាងធុរជនកម្ពុជា និងអ្នកពាក់ព័ន្ធតាមរយៈ Video Conference
- បង្កើត និងរៀបចំឲ្យមានមណ្ឌលអចិន្ត្រៃយ៍ សម្រាប់តាំងផលិតផលកម្ពុជា ដើម្បីបើកច្រកទីផ្សារក្នុងប្រទេស និងក្រៅប្រទេស មាននៅបណ្តាខេត្តមួយចំនួន និងនៅប្រទេសមួយចំនួន ដែលមានទីតាំងអាចរៀបចំបាន

- រៀបចំ និងចងក្រងព័ត៌មានស្តីពីទីផ្សារក្នុងនិងក្រៅប្រទេស និងព័ត៌មានពាណិជ្ជកម្ម តាមរយៈការរៀបចំឯកសារ បោះពុម្ព និងផ្សព្វផ្សាយដូចជា ខិតប័ណ្ណ និងទស្សនាវដ្តីទីផ្សារ និងផ្សព្វផ្សាយសៀវភៅនីតិវិធីនាំចេញ
- បន្តអនុវត្តគម្រោងសម្រាប់គ្រប់គ្រង និងការសាងសង់ផ្សារព្រំដែនកម្ពុជា-វៀតណាម នៅខេត្តស្វាយរៀង និងខេត្តកែប
- បន្តសហការជាមួយ សមាគម CICC និង ក្រុមហ៊ុនP&T Investmentនៅប្រទេសចិនដើម្បីដាក់តាំងកេទីផ្សារនៅតាមផ្សារទំនើបនៅប្រទេសចិន និងចូលរួមពិនិត្យលើកិច្ចសន្យាប្រគល់ និងទូទាត់ទំនិញរបស់ក្រុមហ៊ុនលក់ និងក្រុមហ៊ុនចែកចាយ
- បន្តរៀបចំចុះអនុស្សរណៈយោគយល់គ្នា MOU រវាងអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មទីក្រុងហុងកុង (HKTDC) ស្តីពីកិច្ចសហប្រតិបត្តិការជំរុញពាណិជ្ជកម្មកម្ពុជា-ហុងកុង។

## ៣.១៤ ការខារគាំគុខគ្រូល

- បន្តដំណើរការគាំទ្រ ការពិនិត្យទិដ្ឋភាពបច្ចេកទេសសេចក្តីព្រាងច្បាប់ស្តីពីម្ហូបអាហារ
- បន្តចូលរួមកសាងសេចក្តីព្រាងច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់
- កសាងសេចក្តីព្រាងអនុក្រឹត្យអំពីស្តង់ដារសុវត្ថិភាពម្ហូបអាហារដោយអនុម័តយកស្តង់ដារជាតិ និងស្តង់ដារកូដិចដែលពាក់ព័ន្ធ
- កសាងសេចក្តីព្រាងប្រកាស អំពីបែបបទនៃការត្រួតពិនិត្យម្ហូបអាហារនាំចូល
- កសាងសេចក្តីព្រាងប្រកាសអំពីការប្រមូលទំនិញពីទីផ្សារ (ផលិតផលមិនសមស្របនិងភាពអនុលោម តាមបទបញ្ញត្តិច្បាប់)
- សិក្សាខ្លឹមសារនៃបទបញ្ញត្តិនៃផលិតផលប្រេងឥន្ធនៈ
- ពង្រឹងប្រសិទ្ធភាពនៃការឃ្លាំពិនិត្យទីផ្សារ (Market Surveillance) ទប់ស្កាត់គ្រោះថ្នាក់សុខមាលភាព សុវត្ថិភាពអ្នកប្រើប្រាស់ពាក់ព័ន្ធនឹងផលិតផល
- ពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យការនាំចេញ-នាំចូលតាមច្រកព្រំដែន ដោយអនុវត្តអភិក្រមនៃការគ្រប់គ្រងហានិភ័យ
- ធ្វើឱ្យប្រសើរនូវកម្រិត ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ: អាស៊ាន , មហាអនុតំបន់ទន្លេមេគង្គ (GMS), តំបន់ពាណិជ្ជកម្មសេរីពាក់ព័ន្ធ ប្រទេសដៃគូសន្ទនា និងការចូលរួមកិច្ចការគណៈកម្មាធិការកូដិចអន្តរជាតិ ។ល។ តាមការអនុវត្តគោលការសមស្រប និងការពង្រឹងសមត្ថភាព
- ពង្រឹងសមត្ថភាពវិភាគរបស់មន្ទីរពិសោធន៍ និងប្រព័ន្ធគ្រប់គ្រង ឲ្យមានលក្ខណៈសម្បត្តិសមស្របតាមការតម្រូវនៃស្តង់ដារអន្តរជាតិ សម្រាប់មន្ទីរពិសោធន៍ ដើម្បីទទួលបានការទទួលស្គាល់ (Accreditation) លើសមត្ថភាពជាក់លាក់(ផ្នែករូបវន្ត, គីមីសាស្ត្រ, និងមីក្រូជីវសាស្ត្រ)
- បង្កើនសមត្ថភាព និងប្រសិទ្ធភាពការគ្រប់គ្រងសកម្មភាពទូទៅ (ក្របខណ្ឌគ្រប់គ្រង ក្របខណ្ឌច្បាប់ និងបច្ចេកទេស)

- បន្តជំរុញប្រសិទ្ធភាពនៃសកម្មភាពគ្រប់គ្រង តាមដានការផ្តល់ព័ត៌មានត្រឹមត្រូវដល់អ្នកប្រើប្រាស់ ជាអាទិ៍ការដាក់ស្លាកសញ្ញាលើផលិតផល ការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផល ការផ្សព្វផ្សាយការលក់ ពិសេស ការផ្សាយពាណិជ្ជកម្មភូតកុហក់ ពង្វាងការពិត ឬធ្វើឱ្យមានការភ័ន្តច្រឡំដល់អ្នកប្រើប្រាស់
- កសាងខ្លឹមសារ និងកម្មវិធីនៃដំណើរការអនុវត្តការលើកកំពស់ការយល់ដឹងសាធារណៈ
- ពង្រឹងកិច្ចដំណើរការទប់ស្កាត់រាល់ការបន្លំ ការប៉ុនប៉ងបន្លំលើផលិតផល ក្រៅអំពីបញ្ហាគុណភាពសុវត្ថិភាពតាមគ្រប់របរភាព និងតាមទីផ្សារទូទាំងប្រទេស។

## ៣.២០ ការធានាសន្តិសុខស្បៀង និងសន្តិធិអាសិអាន

- ក្រុមហ៊ុនខិតខំបណ្តុះបណ្តាលសមត្ថភាពបន្ថែមដល់មន្ត្រីនិយោជិត
- កែសម្រួលបន្ថែមនូវទេនាសម្ពន្ធ័តាមការងារជាក់ស្តែង
- ផែនការអាជីវកម្ម និងស្តុកត្រៀមបម្រុង: ផែនការអាជីវកម្ម ផែនការទិញចូល បរិមាណទិញចូល ៧.០០០តោន០០០ ទឹកប្រាក់សរុប ១១.៦២០.០០០.០០០៛ បើធៀបទៅការអនុវត្តឆ្នាំ២០១៥ នោះការកសាងផែនការទិញឆ្នាំ ២០១៦ បានត្រឹមតែ ៩៥,៦៩% ដោយក្នុងនោះមុខទំនិញអង្ករ និងលក់ចេញដូចខាងក្រោម៖
  - ខេត្ត ព្រៃវែង = ៥.៦០០តោន០០០
  - ខេត្ត ត្បូងឃ្មុំ = ៩០០តោន០០០
  - ខេត្ត កំពង់ធំ = ២០០តោន០០០
  - ខេត្ត សៀមរាប = ៣០០តោន០០០
  - មណ្ឌលឃ្លាំងត.ម៦ = ៥០០តោន០០០
  - បរិមាណគ្រោងទិញចូល = ៧.០០០តោន០០០
  - សរុបទឹកប្រាក់ = ១១.៦២០,០០០,០០០៛
  - លក់ជូនWFP = ១.០០០តោន០០០ = ១.៧២២.០០០,០០០៛
  - លក់ជូនMOC = ១.៣៥៧តោន៩៦៦ = ៣.០០០.០០០.០០០៛
  - លក់នាំចេញ = ៥.០០០តោន០០០ = ៨.៦១០.០០០.០០០៛
  - លក់ផ្សេងៗ = ៥០០តោន០០០ = ១.០០០.០០០.០០០៛
  - បរិមាណលក់ចេញគម្រោង = ៧.៨៥៧តោន៩៦៦
  - សរុបទឹកប្រាក់ = ១៤.៣៣២,០០០,០០០៛
- ផែនការថៃ្លទ្រទ្រង់ថ្លៃ សម្រាប់ស្តុកត្រៀមបម្រុងយុទ្ធសាស្ត្រឆ្នាំ២០១៦ មានទឹកប្រាក់ ៣,០០០ លានរៀល។ ក្នុងនោះក្រុមហ៊ុនមានគម្រោងទិញជូន ក្រសួងពាណិជ្ជកម្មបានចំនួន ១.៣៥៧តោន ៩៦៦។ ថ្លៃលក់នេះត្រូវបានគិតបញ្ចូល VAT ១០% និងពន្ធលើប្រាក់ចំណេញ ១% ផងដែរ
- ខិតខំស្វែងរកទីផ្សារ ដើម្បីបង្កើនទុនក្រុមហ៊ុនក្នុងការបង្កើនជីវភាពមន្ត្រីនិយោជិតក្រុមហ៊ុន

- ធានាស្ថេរភាពតម្លៃអង្ករទីផ្សារក្នុងស្រុក រក្សានូវផលប្រយោជន៍ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីចូលរួមការកាត់បន្ថយភាពក្រីក្រ
- ផែរក្សាស្តុកយុទ្ធសាស្រ្តស្បៀងបម្រុងរដ្ឋ សម្រាប់ចូលរួមអន្តរាគមន៍ដល់គ្រោះមហន្តរាយផ្សេងៗ
- ត្រៀមលក្ខណៈទិញស្រូវ-អង្ករ សម្រាប់បម្រើឲ្យអាជីវកម្មតាមផែនការ ឆ្នាំ២០១៦
- ធ្វើការចរចាពាណិជ្ជកម្មទ្វេភាគី ជាមួយទីផ្សារដែលមានស្រាប់ និងបន្តចរចាជាមួយប្រទេសឥណ្ឌូនេស៊ីលើការធ្វើពាណិជ្ជកម្មអង្ករ រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល
- សហការជាមួយសហព័ន្ធស្រូវ-អង្ករកម្ពុជាក្នុងការនាំចេញអង្ករកម្ពុជា-ចិន (ក្រុមហ៊ុនCOFCO) ដែលបានចុះ MOU កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ នាំអង្ករចេញពីកម្ពុជាចំនួន ១០០,០០០តោន
- ពង្រឹងការផ្សព្វផ្សាយចែករំលែកព័ត៌មាន ដែលពាក់ព័ន្ធនឹងការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករកម្ពុជាដល់សមាគមអ្នកផលិត សមាគមម៉ាស៊ីនកិនកែច្នៃអង្ករ សហព័ន្ធស្រូវ-អង្ករកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១៥

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស្តីទី**

**គីម ស៊ីថន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

# ផែនការសកម្មភាពពាណិជ្ជកម្មឆ្នាំ២០១៦

| ល.រ | សកម្មភាព | អង្គភាពទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|
| **1.ការធានាអធិការកិច្ច និងសវនកម្ម** | | | |
| **1.1.អគ្គាធិការដ្ឋាន** | | | |
| 1.1.1 | អធិការកិច្ចលើការងារគ្រប់គ្រងរដ្ឋបាលបច្ចេកទេស ២០អង្គភាព (នាយកដ្ឋាន/អង្គភាពថ្នាក់កណ្តាល ៥អង្គភាព និងថ្នាក់រាជធានី/ខេត្ត ១៥អង្គភាព) | អគ្គាធិការដ្ឋាន | កុម្ភៈ-វិច្ឆិកា |
| 1.1.2 | អធិការកិច្ចលើការងារគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ១៥អង្គភាព (ថ្នាក់រាជធានី/ខេត្ត) | អគ្គាធិការដ្ឋាន | កុម្ភៈ-វិច្ឆិកា |
| 1.1.3 | អធិការកិច្ចលើការងារគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ ៣៥អង្គភាព (អង្គភាពថ្នាក់កណ្តាល ៥អង្គភាព ថ្នាក់រាជធានី/ខេត្ត ១៥អង្គភាព និងសាខាកាំកុងត្រូល ១៥អង្គភាព) | អគ្គាធិការដ្ឋាន | មករា-វិច្ឆិកា |
| 1.1.4 | តាមដាន និងវាយតម្លៃលទ្ធផលអនុវត្តកែលម្អ តាមអនុសាសន៍របស់ប្រតិភូអធិការកិច្ច/សវនកម្មដែលបានលើកឡើង | អគ្គាធិការដ្ឋាន | មករា-ធ្នូ |
| 1.1.5 | ចុះធ្វើអធិការកិច្ចឆ្មក់ (Spot Check) លើការគោរពវិន័យ ពេលម៉ោងធ្វើការ សណ្តាប់ធ្នាប់ និងសកម្មភាពអវិជ្ជមាននានា ដែលធ្វើឲ្យប៉ះពាល់ដល់គោលនយោបាយកំណែទម្រង់របស់ក្រសួងពាណិជ្ជកម្ម | អគ្គាធិការដ្ឋាន | មករា-ធ្នូ |
| 1.1.6 | តាមដានត្រួតពិនិត្យ និងប្រមូលសរុបការធ្វើរបាយការណ៍របស់បណ្តាអង្គភាព ជុំវិញស្មារតីអនុវត្តការងារ និងរបបប្រជុំ | អគ្គាធិការដ្ឋាន | មករា-ធ្នូ |
| 1.1.7 | បំប៉នសមត្ថភាពមន្ត្រីរាជការនៅនឹងកន្លែងធ្វើការ (Job on Training) ដោយបង្រៀនពីបច្ចេកទេសនានាក្នុងការធ្វើអធិការកិច្ច | អគ្គាធិការដ្ឋាន | មករា-តុលា |
| **1.2.នាយកដ្ឋានសវនកម្មផ្ទៃក្នុង** | | | |
| 1.2.1 | អនុវត្តផែនការសវនកម្មប្រចាំឆ្នាំ២០១៦ | នា-សវនកម្មផ្ទៃក្នុង | មករា-ធ្នូ |
| 1.2.2 | សិក្សាលើហានិភ័យរបស់អង្គភាពត្រូវធ្វើសវនកម្ម ដើម្បីកំណត់វិសាលភាពការងារដែលត្រូវអនុវត្តតាម | នា-សវនកម្មផ្ទៃក្នុង | មករា-ធ្នូ |

| | | | |
|---|---|---|---|
| | បណ្ដាសនេដ្ឋាននីមួយៗ | | |
| 1.2.3 | ចុះធ្វើការងារសវនកម្មនៅតាមអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្មរួមមាន៖ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកដ្ឋានកាំកុងត្រូលនិងសាខា តំបន់សេដ្ឋកិច្ចពិសេស និងមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត | នា-សវនកម្មផ្ទៃក្នុង | មករា-ធ្នូ |
| 1.2.4 | តាមដាន និងវាយតម្លៃនូវការកែលម្អ ដែលអង្គភាពរងសវនកម្មបានអនុវត្តតាមអនុសាសន៍របស់ប្រតិភូសវនកម្ម | នា-សវនកម្មផ្ទៃក្នុង | មករា-ធ្នូ |
| 1.2.5 | បំប៉នសមត្ថភាពមន្ត្រីក្នុងនាយកដ្ឋាននូវជំនាញគណនេយ្យ រដ្ឋបាល ច្បាប់ និងវិធីសាស្ត្រធ្វើសវនកម្ម | នា-សវនកម្មផ្ទៃក្នុង | មករា-មិថុនា |
| **2.អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ** | | | |
| **2.1.នាយកដ្ឋានរដ្ឋបាល** | | | |
| 2.1.1 | ធ្វើការបូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ប្រចាំខែ | នា-រដ្ឋបាល | ថ្ងៃទី២៥ រៀងរាល់ខែ |
| 2.1.2 | ធ្វើការបូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ត្រីមាសទី១ | នា-រដ្ឋបាល | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ |
| 2.1.3 | ធ្វើការបូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឆមាសទី១ | នា-រដ្ឋបាល | ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ |
| 2.1.4 | ធ្វើការបូកសរុបសកម្មភាពការងារពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ៩ខែដើមឆ្នាំ | នា-រដ្ឋបាល | ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ |
| 2.1.5 | ធ្វើការបូកសរុបសកម្មភាពការងារឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម | នា-រដ្ឋបាល | ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ |
| 2.1.6 | រៀបចំសន្និបាតបូកសរុបការងារពាណិជ្ជកម្មប្រចាំឆ្នាំ២០១៦ | នា-រដ្ឋបាល | មករា-មេសា |
| 2.1.7 | រៀបចំពិធីបុណ្យផ្សេងៗ | នា-រដ្ឋបាល | មករា-ធ្នូ |
| 2.1.8 | កែលម្អសោភ័ណភាពខាងក្នុង និងក្រៅអគារទីស្តីការក្រសួង | នា-រដ្ឋបាល | មករា-ធ្នូ |
| 2.1.9 | ពង្រឹងបទបញ្ជាផ្ទៃក្នុងក្រសួង និងរៀបចំឲ្យមន្ត្រីពាក់ផ្លាកសម្គាល់ (អត្តសញ្ញាណប័ណ្ណមន្ត្រី) | នា-រដ្ឋបាល | មករា-ធ្នូ |
| **2.2.នាយកដ្ឋានបុគ្គលិក** | | | |
| 2.2.1 | គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.2 | ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ | នា-បុគ្គលិក | កុម្ភៈ-ឧសភា |
| 2.2.3 | រៀបចំប្រលងជ្រើសរើសបុគ្គលិកថ្មី បុគ្គលិកជាប់កិច្ចសន្យា ពលករអណ្តែត និងផ្លាស់ប្តូរប្រភេទក្របខណ្ឌ | នា-បុគ្គលិក | មករា-កក្កដា |
| 2.2.4 | រៀបចំតារាងបៀវត្ស និងចលនាប្រែប្រួលតាមប្រព័ន្ធព័ត៌មានវិទ្យា | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.5 | លើកគម្រោងផែនការក្របខណ្ឌថវិកា | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.6 | រៀបចំផែនការ និងវាយតម្លៃតម្រូវការបណ្តុះបណ្តាល | នា-បុគ្គលិក | មករា-មិថុនា |
| 2.2.7 | គ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ដែលទាក់ទងនឹងការបណ្តុះបណ្តាល | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.8 | ធ្វើបច្ចុប្បន្នភាពចេនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.9 | រៀបចំវាយតម្លៃ និងផ្តល់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីរាជការ | នា-បុគ្គលិក | មករា-ឧសភា |
| 2.2.10 | ចូលរួមរៀបចំឯកសារជូនសមាគមមន្ត្រីរាជការស៊ីវិល | នា-បុគ្គលិក | កញ្ញា-វិច្ឆិកា |
| 2.2.11 | សិក្ខាសាលាវាយតម្លៃមន្ត្រីកម្មសិក្សាការី ដើម្បីធ្វើការតាំងស៊ប់ក្នុងក្របខ័ណ្ឌ | នា-បុគ្គលិក | មករា-កក្កដា |
| 2.2.12 | សិក្ខាសាលា ស្តីពីការពង្រឹងប្រសិទ្ធភាព នៃដំណើរការអនុវត្តការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការ ថ្នាក់ក្រោមជាតិ | នា-បុគ្គលិក | មីនា-កញ្ញា |
| 2.2.13 | ចុះយកស្នាមមេដៃ និងបំពេញសំណុំបែបបទ សលាគបត្រមន្ត្រីកម្មសិក្សា ដើម្បីបញ្ចូលក្របខ័ណ្ឌពេញសិទ្ធក្នុងតារាងបៀវត្ស | នា-បុគ្គលិក | មីនា-មេសា |

| | | | |
|---|---|---|---|
| 2.2.14 | រៀបចំប្រវត្តិរូបមន្ត្រីរាជការ និងថ្នាក់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.15 | រៀបចំកែសម្រួលរចនាសម្ព័ន្ធរបស់ស្ថាប័នផ្សេងៗ ឲ្យបានសមស្របទៅស្ថានភាពជាក់ស្តែង | នា-បុគ្គលិក | មករា-ធ្នូ |
| 2.2.16 | រៀបចំឯកសារមន្ត្រីចូលនិវត្តន៍ទៅ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាឲ្យទាន់ពេលវេលា | នា-បុគ្គលិក | មករា-ធ្នូ |
| 2.3.នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | | | |
| 2.3.1 | ការកសាងផែនការថវិកា | | |
| 2.3.1.1 | រៀបចំផែនការយុទ្ធសាស្ត្រថវិកា | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មីនា-កក្កដា |
| 2.3.1.2 | លើកគម្រោងផែនការថវិកាក្រសួងឆ្នាំ២០១៧ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មីនា-កក្កដា |
| 2.3.1.2 | ចូលរួមការការពារគម្រោងថវិការបស់ក្រសួងឆ្នាំ២០១៧ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | សីហា-កញ្ញា |
| 2.3.2 | ការអនុវត្តថវិកា | | |
| 2.3.2.1 | រៀបចំប្រកាសអាណាប័កផ្ទេរសិទ្ធិ ថ្នាក់កណ្តាល និងរាជធានី-ខេត្ត | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា |
| 2.3.2.2 | រៀបចំបង់ និងបង្វែរចំណូលថវិកាទៅតាមជំពូក គណនី អនុគណនី | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-ធ្នូ |
| 2.3.2.3 | រៀបចំសំណើរការចំណាយប្រចាំខែ ត្រីមាស | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-ធ្នូ |
| 2.3.2.4 | ពិនិត្យ និងដោះស្រាយសំណើថវិកាតាមបណ្តាអង្គភាព | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-ធ្នូ |
| 2.3.2.5 | រៀបចំប្រកាសអន្តរក្រសួង និងលក្ខខណ្ឌនីតិវិធីសម្រាប់បង្កើតអង្គភាពថវិកា | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-ធ្នូ |
| 2.3.2.6 | រៀបចំរបាយការណ៍ត្រួតពិនិត្យថវិកាពាក់កណ្តាលឆ្នាំ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មេសា-មិថុនា |
| 2.3.2.7 | លើកកម្មវិធីចំណូល-ចំណាយថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា មីនា មិថុនា កញ្ញា |
| 2.3.2.8 | បណ្តុះបណ្តាលមន្ត្រីបច្ចេកទេសពីការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-កុម្ភៈ |
| 2.3.2.9 | ពិនិត្យ និងកែសម្រួលកម្រៃសេវាក្នុងទិសដៅពង្រឹងការប្រមូលចំណូល | នា-គណនេយ្យនិងហិរញ្ញវត្ថុ | កញ្ញា-ធ្នូ |
| 2.3.2.10 | ពិនិត្យឡើងវិញនូវបំណុលចាស់ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា |
| 2.3 | ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | | |
| 2.3.1 | ចូលរួមគណៈកម្មការដើម្បីផ្តល់បញ្ជីសារពើភ័ណ្ឌ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-មេសា |
| 2.3.2 | រៀបចំបញ្ជីសារពើភ័ណ្ឌ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-មីនា |
| 2.3.3 | ធ្វើរបាយការណ៍បូកសរុបបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មេសា |
| 2.3.4 | រៀបចំនីតិវិធីដើម្បីបញ្ចូលអគារដែលទើបសាងសង់ហើយក្នុងបញ្ជីសារពើភ័ណ្ឌ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | កុម្ភៈ |
| 2.3.5 | ចូលរួមត្រួតពិនិត្យ និងតាមដានការបង់ចំណូល និងបំណុលដែលមានភាពយឺតយ៉ាវ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-ធ្នូ |
| 2.3.6 | សិក្សាទងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងទ្រព្យសម្បត្តិរដ្ឋ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា |
| 2.3.7 | សិក្សារៀបចំប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | នា-គណនេយ្យនិងហិរញ្ញវត្ថុ | មករា-មិថុនា |
| 3. អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ | | | |
| 3.1. នាយកដ្ឋានអាស៊ាន់ប៉ាស៊ីហ្វិក | | | |
| 3.1.1 | ការងារសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន | | |
| 3.1.1.1 | សម្របសម្រួល និងចូលរួមអនុវត្តវិធានការនៅសេសសល់នានា នៅក្រោមផែនការមេគំនិតសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥ (AEC Blueprint 2015) ដើម្បីបញ្ចប់ឲ្យបានទាំងស្រុងនៅក្នុងឆ្នាំ ២០១៦ | នា-អាស៊ាន់ប៉ាស៊ីហ្វិក | មករា-ធ្នូ |
| 3.1.1.2 | សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រៀបចំផែនការ និងយុទ្ធសាស្ត្រនានាដើម្បី | នា-អាស៊ាន់ប៉ាស៊ីហ្វិក | មករា-ធ្នូ |

| | | | | |
|---|---|---|---|---|
| | | ចូលរួមអនុវត្តផែនការមេសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៥ (AEC Blueprint 2025) | | |
| | 3.1.1.3 | សម្របសម្រួល និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមនៅក្នុងកិច្ចប្រជុំចរចាកញ្ចប់ទី១០ ឬកញ្ចប់ចុងក្រោយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS) និងចរចាបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាននៅក្នុងឆ្នាំ ២០១៦ (ATISA) | នា-អាស៊ីប៉ាស៊ីហ្វិក | មករា/មិនា/កក្កដា/កញ្ញា |
| | 3.1.1.4 | ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលពាណិជ្ជកម្មទំនិញអាស៊ាន (CCA) និងកិច្ចប្រជុំក្រុមការងារវិធានប្រភពដើមទំនិញអាស៊ាន (ROO) ដើម្បីកែលម្អកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន | នា-អាស៊ីប៉ាស៊ីហ្វិក | មករា/ឧសភា/តុលា |
| | 3.1.1.5 | សម្របសម្រួល និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្រួលពាណិជ្ជកម្មអាស៊ាន (ATFC) | នា-អាស៊ីប៉ាស៊ីហ្វិក | កុម្ភៈ/ឧសភា/តុលា |
| | 3.1.1.6 | ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការចរចាពាណិជ្ជកម្ម ស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងលើកទី៦ (6th AHKFTA TNC) នៅទីក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា | នា-អាស៊ីប៉ាស៊ីហ្វិក | ១-៤ មីនា |
| | 3.1.1.7 | សម្របសម្រួល និងដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមនៅក្នុងកិច្ចប្រជុំចរចាបង្កើនកំរិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូក១: អាស៊ាន-ចិន (ACFTA) អាស៊ាន-កូរ៉េ (AKFTA) អាស៊ាន-ជប៉ុន(AJCEP) អាស៊ាន-ឥណ្ឌា (AIFTA) និងអាស៊ាន-អូស្ត្រាលី- ណូវែលហ្សេឡង់ (AANZFTA) | នា-អាស៊ីប៉ាស៊ីហ្វិក | មករា-ធ្នូ |
| | 3.1.1.8 | ដឹកនាំគណៈប្រតិភូកម្ពុជានៅក្នុងកិច្ចប្រជុំចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា និងចូលរួមកិច្ចប្រជុំចរចាផ្សេងៗទៀតនៃភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) | នា-អាស៊ីប៉ាស៊ីហ្វិក | កុម្ភៈ/មេសា/មិថុនា/កញ្ញា/តុលា |
| | 3.1.1.9 | ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ហុងកុង (AHKFTA TNC) និងកិច្ចប្រជុំក្រុមការងារពាក់ព័ន្ធ ដើម្បីបញ្ចប់នៅក្នុងឆ្នាំ២០១៦ | នា-អាស៊ីប៉ាស៊ីហ្វិក | មីនា/ឧសភា/កញ្ញា/តុលា |
| | 3.1.1.10 | ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវានៅក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន និងចរចាបញ្ចប់ទូរលីតវិធីនានាដើម្បីដាក់ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-ជប៉ុនចុះហត្ថលេខានៅក្នុងខែសីហាឆ្នាំ២០១៦ (AJCEP-TIS) | នា-អាស៊ីប៉ាស៊ីហ្វិក | កុម្ភៈ/កក្កដា/សីហា |
| | 3.1.1.11 | រៀបចំឯកសារ ជំនួយស្មារតី និងចូលរួមកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន (HLTF-EI) ក្រុមការងារទទួលបន្ទុកសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ (AEC 2025 WG) | នា-អាស៊ីប៉ាស៊ីហ្វិក | មករា/កុម្ភៈ/មេសា/កក្កដា |
| | 3.1.1.12 | រៀបចំឯកសារ ជំនួយស្មារតី និងចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់សេដ្ឋកិច្ចអាស៊ាន (SEOM) និងកិច្ចប្រជុំពាក់ព័ន្ធ កិច្ចប្រជុំគណៈកម្មាធិការវិស័យសេដ្ឋកិច្ចទាំងមូល (COW) និងកិច្ចប្រជុំត្រៀមរៀបចំរួមសម្រាប់កិច្ចប្រជុំកំពូលអាស៊ាន (JPM) | នា-អាស៊ីប៉ាស៊ីហ្វិក | មករា/ឧសភា/កក្កដា |
| | 3.1.1.13 | រៀបចំឯកសារ ជំនួយស្មារតី កំណត់សេចក្តី សុន្ទរកថា និងអមដំណើរឯកឧត្តមទេសរដ្ឋមន្ត្រីចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM Retreat) កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន(AEM) និងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចពាក់ព័ន្ធ និងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន (AECC) | នា-អាស៊ីប៉ាស៊ីហ្វិក | កុម្ភៈ/មីនា/មេសា/សីហា/វិច្ឆិកា |
| | 3.1.1.14 | រៀបចំឯកសារ ជំនួយស្មារតី សុន្ទរកថា ស្តីពីសេដ្ឋកិច្ចជូន និងអមដំណើរប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជាចូលរួមកិច្ចប្រជុំកំពូលអាស៊ាន (ASEAN Summit) និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ | នា-អាស៊ីប៉ាស៊ីហ្វិក | មេសា/វិច្ឆិកា |
| | 3.1.1.15 | រៀបចំឯកសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង និងពិធីសារអាស៊ាននានា ដែលទើបចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានក្រោមការទទួលខុសត្រូវរបស់ក្រសួងពាណិជ្ជកម្មដូចជា៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន-ឥណ្ឌា កញ្ចប់សន្យាទី៩ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ពិធីសារទី៣ស្តីពីការធ្វើវិសោធនកម្មនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ ពិធីសារស្តីពីការ | នា-អាស៊ីប៉ាស៊ីហ្វិក | មករា-កក្កដា |

| | | | | |
|---|---|---|---|---|
| | | បង្កើនគម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ជាដើម ដើម្បីដាក់ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាពិនិត្យ និងអនុម័ត | | |
| | 3.1.1.16 | បន្តសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំព័ត៌មានអំពីសេដ្ឋកិច្ច-ពាណិជ្ជកម្មអាស៊ាន និងដៃគូអាស៊ានសម្រាប់ដាក់បញ្ចូលក្នុងនិហិតជ្ឈានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដើម្បីជាព័ត៌មានជូនពាណិជ្ជករ អ្នកវិនិយោគនិងសាធារណជន | នា-អាស៊ីប៉ាស៊ីហ្វិក | មករា-ធ្នូ |
| | 3.1.1.17 | បន្តចូលរួមធ្វើការងារស្តីពីវិធានការមិនមែនពន្ធគយក្រោមពាណិជ្ជកម្មទំនិញអាស៊ាន ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន និងអង្គការអន្តរជាតិពាក់ព័ន្ធដើម្បីកាត់បន្ថយនូវការដាក់វិធានការមិនមែនពន្ធគយរបស់ក្រសួង-ស្ថាប័ននានា លើទំនិញ និងសេវា និងវិនិយោគនានាស្របសមស្របទៅនឹងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ក៏ដូចជា ទប់ស្កាត់នូវការដាក់វិធានការមិនមែនពន្ធគយរបស់ប្រទេសសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក មកលើទំនិញដែលនាំចេញពីកម្ពុជាទៅក្នុងប្រទេសសមាជិកទាំងនោះ | នា-អាស៊ីប៉ាស៊ីហ្វិក | មករា-ធ្នូ |
| | 3.1.1.18 | បន្តសហការរៀបចំការងារស្តីពីការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញដោយអ្នកនាំចេញ (Self-Certification), សិក្សាអំពីការអនុវត្តប្រសើរពីបណ្តាប្រទេសសមាជិកអាស៊ានមួយចំនួន អំពីការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញដោយអ្នកនាំចេញ ដើម្បីចូលរួមកែលម្អការអនុវត្តរបស់កម្ពុជា | នា-អាស៊ីប៉ាស៊ីហ្វិក | មករា-ធ្នូ |
| | 3.1.1.19 | ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការចម្រុះស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA JC) និងកិច្ចប្រជុំពាក់ព័ន្ធ នៅដើមត្រីមាសទី២ ឆ្នាំ ២០១៦ នៅទីក្រុងសៀមរាប | នា-អាស៊ីប៉ាស៊ីហ្វិក | កក្កដា |
